បណ្ឌិត ជា ណោង

# បច្ចេកទេសចិញ្ចឹមជ្រូក



បណ្ឌិត ជា ណេង

នាយកដ្ឋាន ផលិតកម្ម & បសុពេទ្យាបាល
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បណ្ណាល័យកសិកម្ម
10 MAY 1996
CADC
0563 - L01

# បច្ចេកទេសចិញ្ចឹមជ្រូក ជាលក្ខណៈគ្រួសារ

ម.ព.ឯ.ក AIDOC
Code: 241-004
Date:
Donated by:

# អារម្ភកថា

ការចិញ្ចឹមជ្រូកជារបៀបគ្រួសារ ជាទំលាប់ប្រពៃណីមានជាយូរអង្វែងរបស់បងប្អូនប្រជាកសិករយើង ហើយបច្ចុប្បន្ននេះការចិញ្ចឹមជ្រូកមានការរីកចំរើននៅគ្រប់ទិសទីក្នុងទូទាំងប្រទេសតាំងពីជនបទ រហូតដល់ទីក្រុង។

ការចិញ្ចឹមជ្រូកជារបៀបគ្រួសារ បានរួមចំណែកយ៉ាងសកម្មក្នុងការផ្គត់ផ្គង់សាច់ដល់ជីវភាពសង្គម កែលំអ និង ធ្វើឱ្យស្ថេរភាពជីវភាព សំភារៈរបស់ប្រជាកសិករយើង ។

ប្រជាកសិករយើង ក៏មានបទពិសោធន៍ខ្លះហើយក្នុងការចិញ្ចឹមជ្រូក ប៉ុន្តែដើម្បីលើកកំពស់ការយល់ដឹងអំពីជ្រូក ធ្វើឱ្យការចិញ្ចឹមជ្រូករបស់យើងទទួលបានលទ្ធផលល្អ អ្នកចិញ្ចឹមត្រូវអនុវត្តឱ្យបានល្អអំពី បញ្ហាវិទ្យាសាស្ត្រ បច្ចេកទេសក្នុងការចិញ្ចឹម តាំងពីការជ្រើសរើសពូជ ចំណីអាហារ រហូតដល់ការថែរក្សា ការពារ និង ព្យាបាលជំងឺ ។

កូនសៀវភៅនេះ នឹងអធិប្បាយជូនមិត្តអ្នកអានអំពីបញ្ហាបច្ចេកទេសងាយយល់ទាំងនោះ ប៉ុន្តែការចិញ្ចឹមជ្រូកជារបៀបគ្រួសារនៅមានបញ្ហាជាច្រើនទៀតដែលត្រូវបន្តស្រាវជ្រាវ ។

យើងខ្ញុំសង្ឃឹមលើមិត្តអ្នកអាន ឆ្លងបទពិសោធន៍ផ្ទាល់របស់ខ្លួននឹងរួមចំណែកផ្តល់យោបល់ដល់អ្នកនិពន្ធ ។

បណ្ឌិត **ជា ណេង**

CHEA NENG, Ph.D.

CADC

# I - សភាពការណ៍ចិញ្ចឹមជ្រូក

## ១. នៅលើសកលលោក :

ក្នុង ៥0 ឆ្នាំកន្លងមកនេះ ការចិញ្ចឹមជ្រូកនៅបណ្តាប្រទេសនានា នៅលើពិភពលោក មានការវិវត្តន៍ឈានឡើងច្រើន គេបានបង្កើតឡើងនូវពូជជ្រូកដែលមានទិន្នផលខ្ពស់ដូចជា : Yorkshire, Landrace ។ល ។ សំរាប់ប្រទេសគេនិមួយៗ ។ បច្ចេកទេសក្នុងការចិញ្ចឹម និង ព្យាបាល ក៏មានការឈានឡើងច្រើន ។ គេអនុវត្តរបៀបចិញ្ចឹមក្នុងទ្រុងដែលគ្មានមេរោគ អនុវត្តការបង្កាត់ពូជដោយសិប្បនិម្មិត ដែលប្រើស្ពែមរាវ (ស្រស់) ឬ បង្កក អនុវត្តការផ្តាច់ដោះក្នុងអាយុ ១០ ថ្ងៃ ឬ ទើបកើត ។ ដោយសមត្ថភាពបច្ចេកទេសខ្ពស់ អនុវត្តគ្រឿងយន្តស្ទើរតែទាំងអស់ក្នុងការចិញ្ចឹមជ្រូក ទើបទិន្នផលពលកម្មនៅបណ្តាប្រទេសទាំងនោះខ្ពស់ណាស់ ។ មានកសិដ្ឋានខ្លះគេប្រើមនុស្ស តែម្នាក់ ដើម្បីចិញ្ចឹមជ្រូក ៥,000 ក្បាល ។

រហូតដល់ឆ្នាំ ១៩៨៩ (តាមឯកសាររបស់ FAO) បានឱ្យដឹងថា នៅលើពិភពលោកយើងនេះមានជ្រូកចំនួន ៨៤៦,១៧0,000 ក្បាល ។ ក្នុងនោះ :-

- ទ្វីបអាហ្វ្រិក មាន ១២,១៨0,000 ក្បាល
- ទ្វីបអាមេរិក - ១៤៥,៧១៨,000 -
- ទ្វីបអាស៊ី - ៤0៩,៩៨៩,000 -
- ទ្វីបអឺរ៉ុប - ១៨៧,៣៦៥,000 -
- ទ្វីបអូសេអានី - ៥0,១១0,000 -

ហើយចំនួនសាច់ដែលលក់នៅលើផ្សារពិភពលោក ក្នុងឆ្នាំ ១៩៨៧ មាន ១៣៤,៨ លានតោន ក្នុងនោះសាច់ជ្រូកមាន ៥៦ លានតោន ស្មើនឹង ៤០ % ។

ចំនួនទឹកប្រាក់ដែលបានមកពីការលក់ផលិតផលសាច់នៅលើពិភពលោកមានចំនួន ៧៥,០០០ លានដុល្លារ ក្នុងនោះ :-

- គោ ៤០,០០០ លានដុល្លារ
- ជ្រូក ១៤,៤០០ លានដុល្លារ
- សត្វស្លាប ១២,២០០ លានដុល្លារ
- ចៀម ៥,៤០០ លានដុល្លារ

## ២. នៅប្រទេសកម្ពុជា :

រហូតមកដល់ឆ្នាំ ១៩៩៥ នេះ យើងមានជ្រូកចំនួន ២,២ លានក្បាល ដែលប្រជាកសិករយើងចិញ្ចឹមនៅពាសពេញទូទាំងប្រទេស ។

ការចិញ្ចឹមជ្រូករបស់យើង ពិនិត្យជារួមមានការលូតលាស់យឺតបណ្តាលមកពីយើងខ្វះចំណីឧស្សាហកម្ម ហើយគុណភាពចំណីក៏មិនល្អ ។ កូនជ្រូកមានជំងឺច្រើន ហើយបណ្តាញបសុពេទ្យនៅមានកំរិតខ្សោយ ។

## ៣. វិធានការចាំបាច់ដើម្បីរួមចំណែកអភិវឌ្ឍន៍ផ្នែកចិញ្ចឹមសត្វ

មូលហេតុដែលបណ្តាលឱ្យការចិញ្ចឹមជ្រូករបស់យើង រីកលូតលាស់យឺត គឺបណ្តាលមកពីចំណីខ្វះទាំងបរិមាណ ខ្វះទាំងគុណភាព ។ ប៉ុន្តែប្រទេសយើងសំបូរវត្ថុធាតុដើមសំរាប់ធ្វើចំណី ប្រសិនបើមានការរៀបចំ

ឱ្យបានល្អ ក្នុងការប្រមូលទិញ និង គ្រប់គ្រងនោះលទ្ធភាពផលិតចំណី របស់យើងអាចធានាបានក្នុងការចិញ្ចឹមសត្វក្នុងទូទាំងប្រទេស ។

- ជាមួយនេះដែរ ក៏ត្រូវមានការវិនិយោគទុនក្នុងការសាងសង់ រោងចក្រកែច្នៃចំណី តាំងពីទីក្រុងរហូតដល់ជនបទ ។

- ត្រូវរៀបចំបណ្ដាញបសុពេទ្យឱ្យបានទូលាយ រហូតដល់ឃុំ ភូមិ ។ ត្រូវយកចិត្តទុកដាក់ក្នុងការផលិតឱសថ និង ឧបករណ៍បសុពេទ្យ ឱ្យបានគ្រប់គ្រាន់សំរាប់ព្យាបាលជំងឺឱ្យជ្រូក ក្នុងនោះត្រូវបណ្ដុះបណ្ដាល បច្ចេកទេសដល់ភ្នាក់ងារបសុពេទ្យ ឱ្យមានសមត្ថភាពគ្រប់គ្រាន់ ហើយក ត្រូវយកចិត្តទុកដាក់ដល់ជីវភាពរបស់ភ្នាក់ងារទាំងនោះផងដែរ ។

- **កែលំអពូជជ្រូក** : ត្រូវបង្កាត់ពូជក្នុងស្រុក ដូចជាពូជហៃណាំ ជាមួយពូជបរទេសដែលយើងនាំចូល ដើម្បីឱ្យបានពូជមួយដែលឱ្យទិន្នផលខ្ពស់ និង មានគុណភាពសាច់ល្អ ។ ក្នុងនោះត្រូវភ្ជាប់ឱ្យបានអំពីជ្រូកបាពូជល្អទាំងអស់ ពិសេសគឺ Large white និង Landrace ... ត្រូវកសាងតំបន់ជ្រូកបា ពូជសុទ្ធ និង ពូជបង្កាត់នៅក្នុងប្រជាកសិករយើង ។

- ត្រូវរៀបចំជាបន្ទាន់នូវបណ្ដាញបង្កាត់ពូជដោយសិប្បនិម្មិត ត្រូវឱ្យមានឧបករណ៍ និង មធ្យោបាយគ្រប់គ្រាន់ ។



# II- អំពីពូជជ្រូក និង របៀបបង្កាត់ពូជ

## A- ពូជជ្រូកបរទេស :

ពូជជ្រូកបរទេសដែលគេនិយមចិញ្ចឹមច្រើននៅលើពិភពលោកនេះមាន:

### ១: យ៉កស្សៀ (Yorkshire Large White ):

ជ្រូកនេះមានដើមកំណើតនៅតំបន់ Yorkshire ប្រទេសអង់គ្លេស នៅទីនោះគេហៅវាថា Large white ។ នៅចុងសតវត្សទី ១៩ ប្រទេសអាមេរិក និង កាណាដា បាននាំពូជជ្រូកនេះចូល ហើយគេហៅវាថា Yorkshire ។ សព្វថ្ងៃនេះពូជជ្រូក Large white បានក្លាយជាពូជអន្តរជាតិ ដោយសារវត្តមានរបស់វានៅគ្រប់ទិសទីលើភពផែនដីនេះ ។ កាលពីដើមជ្រូក Large white ជាពូជជ្រូកដែលមានជើងខ្ពស់ មាឌអាំ ត្រចៀកធ្លាក់ ទ្រូងសំប៉ែត រោមរឹងពណ៌ស ជួនក៏មានពណ៌ប្រផេះ ឬក៏បែតងស្រោល ។ គេបាន យកវាទៅបង្កាត់ជាមួយពូជ Newleicester ដល់ឆ្នាំ ១៨៥២ ទើបបង្កាត់បាន ជាពូជថ្មីនេះ ។

ជ្រូក Yorkshire Large white មានមាឌធំ ខ្លួនវែង ធំស្មើពីស្មាដល់គូថ ប៉ុន្តែស្រឡះល្អ កំណើនរហ័សរវៃ រោមទន់ពណ៌សមានពន្លឺភ្លៀក ត្រចៀកធំឈរត្រង់រាងធ្លាក់ទៅមុខបន្តិច ក្បាលធំ ថ្ពាសទូលាយ មាត់រាងងើចឡើងលើ ភ្នែករ៉ៃ មុខកោង ខ្នងត្រង់ទូលាយ ពោះសម ទ្រូងជ្រៅទូលាយ ស្រួលក្នុងការដកដង្ហើម ភ្លៅធំវែង ជើងវែង ហើយរឹងមាំ ។

ជ្រូក Yorkshire Large white សាយកូន ពូកែចិញ្ចឹមកូន ទឹក

ដោះច្រើន ជាមធ្យមក្នុងមួយសំបុកមាន ១០-១១ ក្បាល ហើយចិញ្ចឹមរហ័សធំ ។

ជ្រូកនេះពូកែសម្របខ្លួននឹងបរិយាកាសខាងក្រៅ មិនសូវរើសចំណី អាចនឹងនិយាយថាជាពូជមួយដែលសមស្របទៅនឹងលក្ខណៈចិញ្ចឹមនៅស្រុកយើង ។

គុណវិបត្តិរបស់វាគឺ :-

- ទទឹងខ្លួនមិនសូវទូលាយ
- ភ្លៅក្រោយមិនសូវរីក
- កូនកើតមកមិនសូវស្មើគ្នា ។



RACE LARGE WHITE

## ២. ឡេនរ៉េស ( Landrace )

ជួនគេហៅ Danois ជួនគេហៅ Danish Landrace ។

មានប្រភពពីប្រទេសដាណឺម៉ាក ។ ពូជនេះរីកសាយពាសពេញពិភពលោក ។ ជាប្រភេទពូជជ្រូកឱ្យសាច់ក្រហមច្រើន ។ ជ្រូកឡែនរ៉េសមានរោមស ខ្នងវែង ក្បាលតូច មាត់តូចវែងត្រង់ ថ្ពាល់តូច ស្លឹកត្រចៀកធំ ធ្លាក់គ្របភ្នែកទាំងពីរ ខ្នងវែងត្រង់ ភ្លៅរីក ជើងទាំងបួនតូចតែអាចទ្រក្បាលធំហរ បានត្រង់ល្អណាស់ ។

ជ្រូកឡែនរ៉េសសាយកូន កូនម្តង ១០-១១ក្បាល ពូកែចិញ្ចឹមកូន កូនកើតមកចំស្មើគ្នា រហ័សធំ ហើយក៏រហ័សពេញវ័យ ។

- ជ្រូកបា អាយុ ២ ឆ្នាំ ២២០ - ៣០០ គក្រ
- ជ្រូកមេ អាយុ ២ ឆ្នាំ ១៨០ - ២០០ គក្រ



៣. ឌូរ៉ុក (Duroc) :

ជ្រូកឌូរ៉ុកមានកំណើតនៅភូមិភាគឦសាននៃប្រទេសអាមេរិក ។ គេបង្កាត់ចេញពីពូជជ្រូកសម្បុរក្រហមនៅ New York និង New Jersey ។

ជ្រូក New Jersey Red មានមាឌធំ សាយកូន ពូកែធន់ទ្រាំនឹងការផ្លាស់ប្តូរធាតុអាកាស គេបង្កាត់វានៅ New Jersey នៅដើមសតវត្សទី ១៩ ។ ចំណែកជ្រូកឌូរ៉ុកមានតូចជាង តែរឹងមាំ រហ័សរហួន ។ នៅ New York គេមិនអាចដឹងពីប្រភពកំណើតពិតប្រាកដរបស់វាទេ គេឱ្យឈ្មោះវាថាឌូរ៉ុក យកតាមឈ្មោះសេះដ៏ល្បីល្បាញមួយនៅសម័យនោះ។

ជ្រូកឌូរ៉ុកមានពណ៌ក្រហមព្រលែត ជើងវែង ភ្លៅចង្អៀត កូនតិច ពូកែធន់ទ្រាំនឹងការលំបាក អត្រាសាច់ច្រើន ។

នៅអាមេរិក ជ្រូកឌូរ៉ុកក្តោបតួនាទី ទី ១ ក្នុងការនាំចេញ បើប្រៀបធៀបជាមួយនឹងពូជជ្រូកដទៃទៀត ។

ពូជជ្រូកឌូរ៉ុកជាមធ្យមមួយសំបុកមាន ៩ - ១០ ក្បាល ស្រួលចិញ្ចឹម មិនសូវមានជំងឺ គេច្រើនយកពូជឌូរ៉ុក ទៅបង្កាត់នឹងពូជជ្រូកដទៃទៀត ដើម្បីបានកូនកាត់ ចិញ្ចឹមឆាប់ធំហើយឱ្យ សាច់ក្រហមច្រើន ។



### ៥. ហាំសៀ (Hampshire) :

មានប្រភពពីតំបន់ Hampshire ប្រទេសអង់គ្លេស ។ នៅទីនោះមានជ្រូកពណ៌ខ្មៅ ប្រឡេាស គេបង្កាត់វាជាមួយពូជជ្រូក Wetsex Saddle back ។ ហើយពូជថ្មីនេះ ត្រូវបានគេនាំទៅប្រទេសអាមេរិក នៅពាក់កណ្ដាលសតវត្សទី ១៩ ។

ជ្រូកហាំសៀ មានមាឌល្មម រហ័សរហួន ហើយឱ្យសាច់ក្រហមច្រើន។ ចំណុចលេចធ្លោស្រួលចំណាំរបស់ជ្រូកហាំសៀ គឺវង្វង់សពទ្ធ័ជុំវិញស្មា និង ជើងមុខ ។

ជ្រូកហាំសៀ មុខត្រង់វែង ត្រចៀកឈរ គ្រោងឆ្អឹងតូចជាងជ្រូកឌូរ៉ុក ជ្រូកញីសាយកូន និង ពូកែចិញ្ចឹមកូន ក្នុងមួយសំបុកជាមធ្យមមាន ១១ កូន ហើយមេមានទឹកដោះច្រើន ។



ពូជជ្រូកនេះឱ្យអត្រាសាច់សុទ្ធច្រើនគួរសម ឆ្លើយតបបាននឹងសំណូមពរធ្វើសាច់កំប៉ុង ។ ក្រៅពីនេះជ្រូកហាំសៀ ស្រួលចិញ្ចឹម ពូកែធន់ទ្រាំជំងឺ អាចចិញ្ចឹមលែងលើវាលស្មៅ ។

### ៥. ប៊ែកស៊ៀ (Berkshire) :

ជ្រូកប៊ែកសៀមានរាងទាបបន្តិច មានពណ៌ខ្មៅ មានចំណុចស ៦ កន្លែង ( ជើងទាំងបួន ចុងកន្ទុយ និង ថ្ងាស ) មាត់រាង ង ហើយមុខរាងកោង ត្រចៀកឈរងាកទៅមុខបន្តិច ចិញ្ចឹមរហ័សធំគួរសម ។

កូនជ្រូកទើបកើត ទំងន់ ១,១-១,២ គក្រ

ផ្តាច់ដោះ ទំងន់ ១២-១៥ គក្រ

ជ្រូកធំ ទំងន់ ១៨០-២០០ គក្រ

ជ្រូកប៊ែកសៀកូនតិច មួយសំបុក មាន ៧-៨ ក្បាល ។ មិនសូវសំបូរទឹកដោះ មិនពូកែចិញ្ចឹមកូន ហើយមិនសូវពូកែធន់ទ្រាំនឹងអាកាសធាតុក្តៅ សើមទេ ។



### ៦. ឆេសស្ទើវ៉ាយ (Chester White) :

មានដើមកំណើតនៅតំបន់ Chester ប្រទេសអាមេរិក ។ នៅដើមសតវត្សទី ១៩ គេបង្កាត់ពូជនេះ ដោយភាគច្រើនពីពូជជ្រូកដែលមាន

សម្បុរស ដែលគេនាំចូលពីប្រទេសអង់គ្លេស ដូចជា Large white, Lincolnshire និង Cheshire ។

មេជ្រូក Chester white សាយកូន ចូកែចិញ្ចឹមកូន រហ័ស ពេញរូបរាង ហើយសាច់របស់វាមានតម្លៃនៅលើផ្សារអន្តរជាតិ ។

ជ្រូក Chester white មានពណ៌ស ស្លឹកត្រចៀកតូចធ្លាក់ទៅមុខ (តូចជាងជ្រូកយ៉កស៊ែនំស) ប៉ុន្តែមិនគ្របជិតភ្នែកទាំងពីរទេ ។ មុខរាងវែង បន្តិចតែត្រង់ (ក៏មានជ្រូកខ្លះមុខរាងកោង) ខ្នងទូលាយកោងឡើងលើ ភ្លៅធំ ។



ជ្រូកបាមានទំងន់ ២៥០-៣០០ គក្រ

មេជ្រូកមានទំងន់ ១៥០-២០០ គក្រ

៦ ចេីចិញ្ចឹមជ្រូក :

សមស្របនឹងការចិញ្ចឹមលើវាលស្មៅ សាយកូន ចូកែចិញ្ចឹមកូន ទឹកដោះច្រើន ។ នៅអាមេរិកជាមធ្យមក្នុងមួយសំបុកឱ្យ ៩-១០ ក្បាល

ហើយអាចរក្សាទុកធ្វើមេដល់អាយុ ៦.៥ ឆ្នាំ ប៉ុន្តែចាប់ពី ៥.៥ ឆ្នាំឡើងទៅ កូនចុះតិច ។

**ខ ចិញ្ចឹមយកសាច់ :**

ឆាប់ធំធាត់ ពូកែស៊ីចំណី ខ្លួនវែង សាច់ក្រហមច្រើន ខ្លាញ់តិច។

**៧. ពូជប៉ូឡូនឆាយណា (Poland China) :**

ជាពូជជ្រូកដ៏ចំណាស់មួយ មានប្រភពនៅប្រទេសអាមេរិក ។ ពូជនេះមានច្រើននៅតំបន់ Butler និង Warren រដ្ឋ Ohio ។



ជ្រូក Poland China មានពណ៌ខ្មៅ ស្លឹកត្រចៀកធាក់ មានដុំស ៦ កន្លែង ( នៅចុងមុះ កន្ទុយ និង ចុងជើងទាំងបួន ) ។

## B - ពូជជ្រូកក្នុងស្រុក :

ពូជជ្រូកក្នុងស្រុករបស់យើងមាន ជ្រូកកណ្ដុរ ជ្រូកដីរ ជ្រូកហៃណាំ ហើយនិងជ្រូកកំពត ។ លក្ខណៈរួមរបស់វាគឺ ខ្លួនតូចទី ខ្លួងដែន

ពោះធ្លាក់ ស្លឹកត្រចៀកឈរត្រង់តូច ។ សាយកូន ពូកែចិញ្ចឹមកូន ស៊ីមិន រើសចំណី ពូកែធន់ទ្រាំនឹងជំងឺ ងាយចិញ្ចឹម ។

- **ជ្រូកពូជហៃណាំ ( Hainan ) :**

ពូជជ្រូកហៃណាំ មានវត្តមាននៅប្រទេសជាច្រើនក្នុងពិភពលោក។ មានប្រភពដើមកំណើតនៅប្រទេសចិន គេហៅថា ពូជចិន ឬក៏ពូជម្លូង ឬក៏ ពូជយូណាន ។ នៅប្រទេសយើងគេហៅវាថាពូជហៃណាំ ជាឈ្មោះ កោះមួយនៅប្រទេសចិន ។

ពូជជ្រូកហៃណាំ មានក្បាលវែង មុខចង្អៀត ត្រចៀកធ្លាក់ទៅមុខ បន្តិច ច្រមុះទូលាយ ខ្នងអែន ជើងកំពស់ល្មម មានសម្បុរស-ខ្មៅ ឬ ខ្មៅ-ស ឬ ក៏ស ។

- មានទំងន់ ៦០ គក្រ ក្នុងអាយុ ៧-៩ ខែ
- មានទំងន់ ១០០ គក្រ ក្នុងអាយុ ១២-១៥ ខែ

ជាប្រភេទពូជជ្រូកដែលឱ្យខ្លាញ់ច្រើន ។ ជ្រូកហៃណាំពូកែធន់ទ្រាំ នឹងជំងឺ អាចដាក់ឈ្មោលក្នុងអាយុ ៧ ខែ ពេលដែលវាមានទំងន់ ៦០គក្រ ។ ប្រជាកសិករយើងចូលចិត្តចិញ្ចឹមពូជជ្រូកហៃណាំកាត់ ជាមួយ ពូជបរទេស ព្រោះវារហ័សរកឈ្មោល ហើយរយៈពេលពរពោះជាមធ្យម ១១៥ ថ្ងៃ ។

កូនក្នុងមួយសំបុក មានពី ៩-១២ ក្បាល
ទំងន់កូនពេលកើត ៥០០-៦០០ ក្រាម

- **ពូជជ្រូកកំពត Cochon tetrodon :**

មានប្រភពនៅខេត្តកំពត ទើបគេឱ្យឈ្មោះថាពូជកំពត ។ ប៉ុន្តែ ប្រភពពិតប្រាកដរបស់វា គេមិនបានដឹងច្បាស់ទេ ។ គេក៏ឃើញពូជជ្រូក

កំពតមាននៅតាមខេត្តជាប់ព្រំប្រទល់ប្រទេសវៀតណាម ដូចជាខេត្តកំពត តាកែវ កណ្ដាល ព្រៃវែង ស្វាយរៀង កំពង់ចាម ។ ល ។

ដើមកំណើតនៃពូជជ្រូកនេះ ប្រហែលជាគេនាំមកពីកូសាំងស៊ីន ប៉ុន្តែយើងគ្មានឯកសារបញ្ជាក់ពីបញ្ហានេះទេ ។

ពូជជ្រូកកំពតនេះក៏មានចិញ្ចឹមផងដែរនៅក្នុងកសិដ្ឋានរដ្ឋ នៅទួលព្រះវិហារ ខេត្តកំពង់ចាម ក្នុងឆ្នាំ ១៩៧០ ។ ពូជជ្រូកកំពត មានរាងដូចជ្រូកកណ្ដុរ ខ្នងអែនខ្លាំង ក្រចកជើងទាំងពីរខាងក្រោយប៉ះដី ហើយមានរោមពណ៌ ខ្មៅ ។

- មានទំងន់ ៦០ គក្រ ក្នុងអាយុ ៨ - ៩ ខែ
- មានទំងន់ ១០០គក្រ ក្នុងអាយុ ១៣ - ១៦ ខែ ។

## ~ ពូជជ្រូកកណ្ដុរ ( Cochon Souris ) :

ពូជជ្រូកកណ្ដុរជាពូជជ្រូកអាស៊ីសុទ្ធសាធ មានមាឌតូច ហើយ ក្បាលស្រួចដូចក្បាលកណ្ដុរ ខ្លួនខ្លីតែក្រាស់ ខ្នងអែន ពោះប៉ោងកិតដី សម្បុរប្រែប្រួលពី ខ្មៅ ទៅប្រផេះ ។

ចិញ្ចឹមក្រធំ មានទំងន់ ៦០ គក្រ ក្នុងអាយុ ១២ ខែ ។ រយៈពេលធើមជាមធ្យម ១១៣ ថ្ងៃ ។ កូនក្នុងមួយសំបុកអាចមានដល់ ២៤ ក្បាល កាមធ្យម ១៤ ក្បាល ។

## ៸ ពូជជ្រូកដីរ ( Cochon Eléphant ) :

ពូជជ្រូកដីរជាពូជចំណាស់ជាងគេក្នុងចំណោមពូជជ្រូកនៅប្រទេស យើង ។

គេឱ្យឈ្មោះថាដរី ព្រោះវាមានស្បែកជ្រីវជ្រួញនៅម្តុំភ្នែក មានស្លឹកត្រចៀកធំ និងមានដំណើរដូចដំណើរដរី ។

ពូជជ្រូកដរីមាននៅម៉ាន់ឈូរី ( Mandchourie ) នៅចិន និងនៅឥណ្ឌូចិន ។

ពូជជ្រូកដរីមានក្បាលធំ ខ្លួនក្រាស់ ជើងមាំតែខ្លី មានរោមតិចនៅពោះ និង នៅកៀនភ្លៅ ប្រជាកសិករយើងច្រើនគ្រៀវវាក្នុងអាយុ ២ ខែ ដើម្បីចិញ្ចឹមយកសាច់ ។

បច្ចុប្បន្ននេះពូជជ្រូកដរី មាននៅសល់តិចតួចណាស់ក្នុងប្រទេសយើង។ ក្នុងអាយុ ៦-៧ ខែ អាចមានទំងន់ ៦0 គក្រ ។

ក្នុងមួយសំបុកមានពី ៨-១០ ក្បាល ជួនកាលមាន១៥ ក្បាល។

# ការបង្កាត់ពូជ

**បង្កាត់ពូជសុទ្ធ :**

ការបង្កាត់របៀបនេះ គឺគេយកជ្រូកឈ្មោល និង ជ្រូកញីពូជតែមួយមកបង្កាត់ជាមួយគ្នា ។ ឧទាហរណ៍ : យកជ្រូកហៃណាំ មកបង្កាត់ជាមួយជ្រូកហៃណាំ ឬ ក៏យកជ្រូកឈ្មោលយ៉កសៀ បង្កាត់នឹងជ្រូកញីយ៉កសៀ ។

**បង្កាត់ពូជក្លាយ :**

របៀបនេះគឺគេប្រើពូជពីរផ្សេងគ្នាយ៉ាងតិច ។ ការបង្កាត់របៀបនេះមានគោលបំណងលើកកំពស់លទ្ធភាពប្រឆាំងជំងឺ និង លទ្ធភាពផលិតរបស់ជ្រូក បន្ថយអត្រាងាប់ លើកកំពស់គុណភាពសាច់ ធ្វើឱ្យជ្រូកបង្កាត់នេះមាន លទ្ធភាពសំរបខ្លួនល្អជាមួយនឹងលក្ខណៈចិញ្ចឹមនៅជនបទ ។

# របៀបបង្កាត់ពូជ

**របៀបទី ១: បង្កាត់ឧស្សាហកម្ម**

បង្កាត់រវាងពូជពីរផ្សេងគ្នា ដើម្បីបានកូនកាត់លើកទី ១ ដែលគេហៅថា $F_1$ ។ កូនកាត់ $F_1$ នេះមិនរក្សាទុកធ្វើពូជទេ គេចិញ្ចឹមវាយកសាច់ បានជាគេហៅថាបង្កាត់ឧស្សាហកម្ម ។ តាមធម្មតាកូនកាត់ $F_1$ មាន លទ្ធភាពផលិតខ្ពស់ជាងជ្រូកដែលមិនទាន់បង្កាត់ ។




F1 ចិញ្ចឹមយកសាច់

( អត់ទុកធ្វើពូជទេ )

**របៀបទី ២ : បន្លាត់ពូជបី**

ខុសពីរបៀបទី ១ ដោយសារគេប្រើពូជបី គេមិនឈប់ត្រឹម F1 ទេ ប៉ុន្តែគេបន្តបង្កាត់ជាមួយឈ្មោលផ្សេងទៀត រហូតទទួលបានកូនកាត់សមតាមបំណង មេណាល្អគេបន្តបង្កាត់ ជ្រូកមិនល្អគេចិញ្ចឹមយកសាច់ ។



## មេរៀនទី ៣ : បង្កាត់កែចំរើន

ក្នុងពូជជ្រូកនិមួយៗ ទោះបីជាមានចំណុចល្អច្រើនហើយក៏ដោយ ក៏ចាំបាច់ត្រូវបន្ថែមនូវលក្ខណៈពិសេសៗផ្សេងទៀត ដោយវិធីបង្កាត់កែចំរើននេះ ។

ក្នុងរបៀបបង្កាត់កែចំរើន ជ្រូកឈ្មោលរបស់ពូជដែលបានបង្កាត់ហើយនេះសំខាន់ណាស់ ព្រោះវាត្រូវបន្តនូវលក្ខណៈពិសេសដែលយើងចង់បាន ដូចជាលទ្ធភាពផ្តល់សាច់ជាដើម ។

ពូជជ្រូកស្រុកយើងមានលក្ខណៈពិសេសល្អច្រើនដូចជា : រហ័សពេញវ័យ កូនច្រើន ពូកែទ្រាំទ្រការអត់ឃ្លាន មិនរើសចំណី ។ ល ។

ប៉ុន្តែលក្ខណៈផលិតខ្សោយ ដូច្នេះអាចប្រើរបៀបទីបីនេះ ដើម្បីលើកកំពស់ការផលិត ។



## មេរៀនទី ៥ ៖ បន្ទាត់កែលំអ

គោលបំណងនៃការបង្កាត់របៀបនេះ គឺដើម្បីកែលំអពូជជ្រូក ដែលឱ្យទិន្នផលខ្ពស់ ឬ ក៏ក្នុងលក្ខណៈជ្រូកដែលឱ្យទិន្នផលខ្ពស់នេះ មិនអាចចិញ្ចឹមជាពូជសុទ្ធបាន ព្រោះពិបាកសំរបខ្លួនទៅនឹងលក្ខណៈនៅជនបទ។

ជាមួយនឹងការបង្កាត់របៀបនេះ គឺថាមួយជំនាន់ៗនៃការបង្កាត់ លក្ខណៈរបស់ពូជជនបទបាត់អស់ ៥០ % ។ ដើម្បីនឹងរក្សាឱ្យបាននូវលក្ខណៈពិសេសនៃជ្រូកនៅជនបទ ត្រូវជ្រើសរើសឱ្យបានជិតដល់ក្នុងមួយជំនាន់ៗ តាមកំរិតដែលយើងចង់បាន ។

ឧទាហរណ៍ ៖ យើងចង់បានពូជជ្រូកយ៉កសៀ ដើម្បីចិញ្ចឹមក្នុងស្រុកយើង ។



## មេរៀនទី ៥ : បន្ទាត់ពូជថ្មី

គេបង្កាត់ពូជច្រើន ដើម្បីបានពូជថ្មីមួយ ។ អនុវត្តរបៀបបង្កាត់បែបនេះ លុះត្រាតែយើងមានសមត្ថភាព និង មានមធ្យោបាយគ្រប់គ្រាន់ ។ ពូជថ្មីដែលគេបង្កើតឡើងនៅលើពិភពលោកនេះ គឺអនុវត្តតាមរបៀបបង្កាត់បែបនេះ ។

# III - ចំណីសំរាប់ជ្រូក

ដើម្បីឱ្យការចិញ្ចឹមជ្រូកទទួលបានលទ្ធផលល្អ ត្រូវអនុវត្តវិធានការបច្ចេកទេសអំពី : ចំណីអាហារ និង កិច្ចការពារ ព្យាបាលជំងឺ ។ល ។ ក្នុងនោះចំណីអាហារ ជាវិធានការចំបង និង មានលក្ខណៈ កំណត់ ។ ចំណីល្អ ជ្រូកមានសុខភាពល្អ អាចប្រឆាំងនឹង ជំងឺនានា ជ្រូកស៊ីចំណីល្អឆាប់ធំ បង្កើតកូនល្អ ព្រមទាំងអាចសន្សំសំចៃចំណីបាន ទៀតផង ។

ចំណីផ្គត់ផ្គង់សារជាតិគ្រប់បែបយ៉ាងដល់ជ្រូកដូចជា : ជាតិទឹក ជាតិសាច់ ជាតិស្ករ ជាតិខ្លាញ់ ជាតិរ៉ែ និង វីតាមីន ។ ក្នុងចំណីសារជាតិទាំងនោះ ភាគធំនៅជាការរួមផ្សំស្មុគស្មាញ ត្រូវរំលាយឱ្យទៅជាជាតិសាមញ្ញ ទើបជ្រូកអាចបឺតយកសារជាតិទាំងនោះបាន ។

## A - ជាតិសាច់ ( Protide )

### ១. សារៈសំខាន់នៃជាតិសាច់ :

គ្រប់សារជាតិក្នុងចំណីអាហារ សុទ្ធតែជាការចាំបាច់ចំពោះជ្រូក យើងមានការលំបាកក្នុងការបែងចែកឱ្យច្បាស់ថា តើជាតិណាសំខាន់ ជាតិណាមិនសូវសំខាន់ ប៉ុន្តែឈរលើអត្ថន័យសេដ្ឋកិច្ច និង សារជាតិ គេត្រូវតែកំណត់ថា ជាតិសាច់សំខាន់ និង ចាំបាច់នៅគ្រប់តំណាក់កាលនៃការរស់នៅរបស់ជ្រូក ដូចជាការទ្រទ្រង់ជីវិត ( រំលាយអាហារ ឈាមរត់ ដកដង្ហើម ) ធំធាត់ (បង្កើតសាច់ និង គ្រប់អង្គធាតុដទៃទៀត ) ការផលិតៈ ( កូន និង ទឹក ដោះ ) ។ ល ។ ចំណីដែលកសិករយើងនិយមប្រើ

ដើម្បីចិញ្ចឹមជ្រូកមាន : បាយ កន្ទក់ ពោត ដំឡូងមី ដំឡូងជ្វា ដើមចេក ។ ល ។ ចំណីទាំងនេះ មិនអាចផ្គត់ផ្គង់ជាតិសាច់គ្រប់គ្រាន់ និងមានគុណភាពល្អទេ ។

## ២_ គុណភាព :

ជាតិសាច់ជាជាតិដែលរួមផ្សំឡើងដោយការរួមផ្គុំនៃអាស៊ីដអាមីណេជាច្រើន ។ ជ្រូកត្រូវការអាស៊ីដអាមីណេ ១០ មុខជាចាំបាច់ ( គេហៅថាអាស៊ីដអាមីណេដែលមិនអាចជំនួសបាន ) មានន័យថា ជ្រូកមិនអាចបង្កើតបានទេ ត្រូវតែផ្តល់តាមរយៈចំណីអាហារ ។ ក្នុង ១០ មុខនោះមាន បីជាអាស៊ីដអាមីណេ សំខាន់ចាំបាច់គឺ : Lysine, Méthionine និង Tryptophane ។ ប្រសិនបើក្នុងចំណីខ្វះអាស៊ីដអាមីណេសំខាន់ណាមួយនោះ ទោះបីជាចំណីនោះមានសារជាតិគ្រប់គ្រាន់ក៏ដោយ ក៏ជ្រូកមិនអាចបឺតយកជាតិសាច់នោះបានល្អដែរ ។ ដូចនេះក្នុងការឱ្យចំណីជ្រូកគេមិនគ្រាន់តែត្រូវធានាឱ្យមានជាតិសាច់គ្រប់គ្រាន់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវគិតដល់គុណភាពនៃជាតិសាច់ទាំងនោះទៀតផង ។ មានន័យថាចំណីអាហារត្រូវមានបរិមាណជាតិសាច់គ្រប់គ្រាន់ និង មានអាស៊ីដអាមីណេសំខាន់គ្រប់គ្រាន់ចំពោះសេចក្តីត្រូវការរបស់ជ្រូកទៀតផង ។

ដើម្បីលើកកំពស់គុណភាពជាតិសាច់ក្នុងចំណីអាហាររបស់ជ្រូកគេត្រូវឱ្យចំណីឱ្យបានច្រើនមុខ ព្រោះថាចំណីណាមួយក៏ដោយ ក៏សុទ្ធតែខ្វះអាស៊ីដអាមីណេមួយចំនួន ។ ដូចនេះត្រូវលាយឱ្យច្រើនមុខ ទើបវាបង្គ្រប់គ្នាទៅវិញទៅមក ។

ឧទាហរណ៍ : ពោត ខ្វះ Lysine,
សណ្តែកសៀង មាន Méthionine តិច
ម្សៅត្រី សំបូរទាំង Lysine ទាំង Méthionine

ដូចនេះបើលាយទាំងបីមុខចូលគ្នា នោះនឹងធ្វើឱ្យជាតិសាច់មានគុណភាពល្អ ។

### ៣_ សេចក្តីត្រូវការ :

ចំពោះជ្រូក សេចក្តីត្រូវការជាតិសាច់ ប្រែប្រួលទៅតាមអាយុ និងប្រភេទជ្រូក ។ កូនជ្រូកត្រូវការជាតិសាច់ច្រើនជាងជ្រូកធំ មេជ្រូកចិញ្ចឹមកូន ត្រូវការជាតិសាច់ច្រើនជាងមេជ្រូកពរពោះ ។ ល ។

គប្បីផ្គត់ផ្គង់ជាតិសាច់ដល់ជ្រូកឱ្យបានគ្រប់គ្រាន់ ព្រោះបើក្នុងចំណីខ្វះជាតិសាច់ នោះនឹងបណ្តាលឱ្យជ្រូកក្រធំ ។ ចំពោះកូនជ្រូកគឺខ្ជិលស៊ី រោមបះហើយស្គម លទ្ធភាពប្រឆាំងនឹងជំងឺខ្សោយ ងាយកើតជំងឺ ។ ចំណែកមេជ្រូក កាលណាខ្វះជាតិសាច់នឹងបណ្តាលឱ្យចុះស្គម កូនតិច ទឹកដោះតិច ។

### ៤_ ចំណីផ្តល់ជាតិសាច់ :

ទៅតាមប្រភពចំណី គេបែងចែកជាពីរប្រភេទ : ចំណីផ្តល់ជាតិសាច់ មានដើមកំណើតពីសត្វ និងពីរុក្ខជាតិ ។

* **ចំណីផ្តល់ជាតិសាច់មានដើមកំណើតពីសត្វ :**

ចំណីប្រភេទនេះមិនគ្រាន់តែផ្តល់ជាតិសាច់មានគុណភាពខ្ពស់ទេ តែ នៅផ្តល់វីតាមីន ជាតិរ៉ែ និង ជាតិសំខាន់ចាំបាច់ដទៃទៀតដល់ជ្រូកផងដែរ ។

### ក_ ម្សៅត្រី :

ប្រទេសយើងសំបូរត្រីទឹកសាប ដែលជាប្រភពផ្តល់ជាតិសាច់យ៉ាងធំធេងសំរាប់ចិញ្ចឹមជ្រូក។ អាចយកប្រភេទកូនត្រី (ត្រីប្រហុក) ហាលឱ្យស្ងួត ឬក៏កៀបយកខ្លាញ់ចេញ រួចបញ្ចូលក្នុងម៉ាស៊ីនឆ្អើរឱ្យស្ងួតហើយកិនឱ្យហ្មត់។

គុណភាពរបស់ម្សៅត្រី ប្រែប្រួលទៅតាមប្រភេទត្រី របៀប កែច្នៃ និង ជាតិ ដទៃទៀតដែលនៅលាយឡំជាមួយត្រី ។ ជាតិសាច់ក្នុង ម្សៅត្រីអាចមានពី ៤៥- ៦០ % ។ ម្សៅត្រីដែលល្អមានក្លិនឈ្ងុយ មាន ជាតិប្រៃ ( អំបិល ) តិចជាង ៥ % ។

ម្សៅត្រីទឹកសមុទ្រមានជាតិប្រៃខ្ពស់ ហើយជាតិសាច់ក៏ទាប ។ ដូចនេះកាលណាយកត្រីទឹកសមុទ្រមកលាយជាចំណី ជ្រូកត្រូវប្រុងប្រយ័ត្ន ចំពោះកំរិតជាតិអំបិល ។

ជាតិសាច់ក្នុងម្សៅត្រីមានគុណភាពល្អ មានអាស៊ីដអាមីណេសំខាន់ គ្រប់គ្រាន់ និង មានកាល់ស្យូម (Ca) ផូស្វ័រ (P) និង វីតាមីន $B_{12}$ ច្រើន ។

ម្សៅត្រីជាចំណីផ្តល់ជាតិសាច់ មានគុណភាពល្អចំពោះជ្រូក ពិសេសគឺចំពោះកូនជ្រូកទើបផ្តាច់ដោះ និង មេជ្រូកចិញ្ចឹមកូន ។ ទៅតាម អាយុ និង តំណាក់កាលធំធាត់របស់ជ្រូក អាចលាយពី ៣-១០ % ។

**ខ. ម្សៅបង្កង បង្គា :**

នៅប្រទេសយើងមិនទាន់មានទេ ប៉ុន្តែនៅប្រទេសដែលមាន ឧស្សាហកម្មកែច្នៃបង្កងបង្គា គេអាចធ្វើម្សៅបង្កងបង្គា ដែលខូចគុណភាព សំណល់ពីរោងចក្រ ។ រស់ជាតិរបស់ម្សៅបង្កងបង្គា ប្រែប្រួលទៅតាមវត្ថុ ធាតុដើម និង របៀបកែច្នៃ ។ គេអាចធ្វើពីកំពឹសក៏បានដែរ ប៉ុន្តែ គុណភាពវាទាបជាងបង្កងបង្គា ។

**គ. ម្សៅសាច់ :**

អាចប្រើសាច់សំណល់ពីកន្លែងសត្តឃាដ សត្វងាប់ ។ ល ។ ម្សៅសាច់មានគុណភាពខ្ពស់ មានជាតិសាច់ពី ៤០-៥០ % ។

គប្បីកែច្នៃសាច់សំណល់ និង សាច់សត្វដែលងាប់ ដែលមនុស្សប្រើប្រាស់មិនបានយកមកធ្វើជាចំណីឱ្យជ្រូក ។

*** ចំណីផ្តល់ជាតិសាច់មានដើមកំណើតពីរុក្ខជាតិ :**

**ក. កាកសណ្តែកដី** ( ដែលគាបយកប្រេងរួចហើយ )

គេនិយមប្រើច្រើនក្នុងការចិញ្ចឹមជ្រូក ប៉ុន្តែស្តាយណាស់ថា យើងមិនទាន់មានរោងចក្រគាបប្រេង ប៉ុន្តែទៅអនាគតយើងប្រាកដ ជាមាន ។

ជាតិសាច់អាចមានពី ៤០-៤៥ % ប៉ុន្តែបើគាបទាំងសំបកជាតិសាច់មានមិនដល់ ៣០ % ទេ ។ ទោះបីជាមានជាតិសាច់ខ្ពស់ ប៉ុន្តែកាកសណ្តែកដីខ្វះអាស៊ីដអាមីណេសំខាន់មួយចំនួន ។ កាកសណ្តែកដីសំបូរ Niacine (វីតាមីន PP) និង Acide Pantoténic ($B_3$ ) មានរស់ជាតិ ឈ្ងុយឆ្ងាញ់ ជ្រូកចូលចិត្តស៊ី ។

បើគាបសណ្តែកដីសល់ប្រេងច្រើន នោះទុកយូរអាចដុះផ្សិត ពិសេសគឺផ្សិតពណ៌លឿង (Aspergillus flavus) ដែលមានជាតិពុលម្យ៉ាងឈ្មោះ (Aflatoxin ) ពុលកាលណាជ្រូកស៊ី ។ ពុលតិចជ្រូកក្រធំ ចុះទំងន់ ពុលខ្លាំងអាចងាប់ ។

**ខ. កាកសណ្តែកសៀង :**

មានជាតិសាច់ពី ៤០-៥០ % ។ ជាតិសាច់ក្នុងសណ្តែកសៀងមានគុណភាពខ្ពស់ជាងសណ្តែកដទៃទៀត ។ ក្នុងគ្រាប់សណ្តែកសៀងស្រស់មានជាតិម្យ៉ាងប្រឆាំងនឹងអង្គជាតិ ( Diastase ) រំលាយជាតិសាច់ឈ្មោះថា Tripsine ប៉ុន្តែជាតិនេះអាចនឹងកំចាត់បានដោយកំដៅ ។ ហេតុនេះបើមិនគាបយកប្រេងទេ នោះចាំបាច់ត្រូវលីងគ្រាប់សណ្តែកសៀងឱ្យឈ្ងុយ មុននឹងឱ្យជ្រូកស៊ី ។ ជ្រូកចូលចិត្តស៊ីកាកសណ្តែកសៀងណាស់ ។

**គ. កាកដូង :**

កាកដូងមានជាតិសាច់ទាប ប្រហែល ២០ % ហើយគុណភាពជាតិសាច់ក៏អន់ មានសែលុយឡូសច្រើន ១០-១៤ % ដូចនេះមានឥទ្ធិពលមិនល្អ ដល់ការរំលាយអាហារ បើលាយធ្វើចំណីមិនត្រូវលាយច្រើនពេកទេ ។ ចំពោះជ្រូកធំអាចលាយក្រោម ៨ % ។

**ឃ. កាកគ្រាប់កប្បាស :**

កាកគ្រាប់កប្បាសដែលចំរាញ់យកប្រេងរួចហើយ មានជាតិសាច់ខ្ពស់ គឺ ៣៥-៤០ % ប៉ុន្តែគុណភាពអន់ ដោយសារក៏រិត Lysine និង Tryptophane ទាប ។ ត្រូវលាយជាមួយចំណីណា ដែលសំបូរជាតិទាំងពីរខាងលើនេះ ។ កាកគ្រាប់កប្បាសមានជាតិពុលម៉្យាងឈ្មោះ Gossipol ។ ជាតិពុលនេះអាចបណ្តាលឱ្យជ្រូកងាប់ ប៉ុន្តែយើងអាចប្រើជាតិដែកលាយក្នុងចំណី ដើម្បីប្រឆាំងនឹងជាតិពុលនេះ ។

**សង្ខេបមកវិញ :**

ជាតិសាច់មានសារៈសំខាន់ណាស់ចំពោះជ្រូក ត្រូវឱ្យជ្រូកស៊ីចំណីណាដែលមានជាតិសាច់គ្រប់គ្រាន់ ។ ជាតិសាច់ដែលមានដើមកំណើតពីរុក្ខជាតិ មានគុណភាពអន់ជាងជាតិសាច់ដែលមានដើមកំណើតពីសត្វ ដូចនេះក្នុងការលាយចំណី ត្រូវធ្វើយ៉ាងណាឱ្យជាតិសាច់មានគុណភាពខ្ពស់ និងចំណាយលើថ្លៃដើមអស់តិច ។

**B - ជាតិស្ករ** ( Glucide )

ជាតិស្ករមានច្រើននៅក្នុងចំណីពីប្រភេទរុក្ខជាតិ ។ ជាតិស្ករជាប្រភពផ្តល់កំដៅជាសំខាន់ក្នុងចំណីរបស់ជ្រូក ។

កំដៅចាំបាច់ក្នុងការទ្រទ្រង់គ្រប់សកម្មភាពទាំងអស់ក្នុងខ្លួនរបស់ជ្រូក រក្សាកំដៅក្នុងខ្លួន ធំធាត់ និង ផលិតកូន ។

ខ្វះកំដៅបណ្តាលឱ្យជ្រូកស្គម ចុះខ្សោយ បាត់បង់លទ្ធភាពប្រឆាំងនឹងជំងឺ ហើយមានឥទ្ធិពលដល់ការផលិតរបស់ជ្រូក ។ បើក្នុងចំណីលើសកំដៅនោះ ខ្លួនរបស់ជ្រូកនឹងប្រែក្លាយកំដៅនេះឱ្យទៅជាជាតិខ្លាញ់ ។ ដូចនេះបើឱ្យជ្រូកស៊ីជាតិស្ករច្រើន នោះជ្រូកនឹងធាត់កកខ្លាញ់ ហើយនៅលើទីផ្សារគេមិនចូលចិត្តជ្រូកប្រភេទនេះទេ ។ ចំណីផ្តល់កំដៅ មាន :

១. ពោត :

មានពីរយ៉ាង គឺពោតក្រហម និង ពោតស ។ ពោតទាំងពីរយ៉ាងនេះមានរស់ជាតិប្រហាក់ប្រហែលគ្នា ។ មានជាតិសាច់ពី ៨-៩ % ហើយគុណភាពអន់ដោយសារខ្វះ Lysine និង Tryptophane ។

ក្នុងពោតសំបូរវីតាមីន B ដូចជា $B_1$, $B_3$ និង $B_5$ ។ ពោតក្រហមមានជាតិ Carotène ច្រើនជាងពោតស ( ជាតិ Carotène ជាប្រភពដើមនៃវីតាមីន A ) ។ ពោតខ្វះជាតិកាល់ស្យូម តែសំបូរជាតិផូសស្វ័រ ប៉ុន្តែជាតិផូសស្វ័រនេះភាគច្រើននៅជាជាតិរួមផ្សំ ពិបាកក្នុងការបំបែកយកជាតិនេះ ។

ពោតមានជាតិសែលុយឡូសតិច ( ២%) ស្រួលរំលាយ ឆ្ងាញ់ជ្រូកចូលចិត្តស៊ី ។ គេចាត់ទុកថាពោតជាប្រភពចំណីផ្តល់កំដៅជាសំខាន់

ចំពោះជ្រូក ។ ក្នុងការលាយចំណីត្រូវបន្ថែមជាតិសាច់ និង ជាតិរ៉ែ ឱ្យគ្រប់គ្រាន់ទៅនឹងសេចក្ដីត្រូវការនៃប្រភេទជ្រូកនិមួយៗ ។

ក្នុងចំណីជ្រូកធំ អាចប្រើពោត ៨៥ % ( J.A. Eusebio, 1988) តែចំពោះមេជ្រូកពរពោះ គេប្រើក្នុងកំរិតទាបជាងនេះ ។

**២. ស័ក្ខរោ ( Sorgho ) :**

មានជាតិសាច់ច្រើនជាងពោត ( ១១ %) ។ រស់ជាតិប្រហាក់ប្រហែលគ្នា ដូចនេះអាចផ្លាស់ប្ដូរគ្នាបានក្នុងការធ្វើចំណីឱ្យជ្រូក ។ ប៉ុន្តែ Sorgho ស៊ីមិនសូវឆ្ងាញ់ ហើយមាន Carotène តិច ( តិចជាងពោតក្រហម ២០ ដង ) ។

**៣. ចុងអង្ករ :**

ឱ្យកុំដេរពី ៩០-១១៥ % ប្រៀបធៀបនឹងពោត ។ ចំពោះជ្រូកសាច់អាចលាយ ៦០ % ( J.A. Eusebio, 1988; Payne 1990 ) ។ ជ្រូកអាចរំលាយចុងអង្ករល្អិតដោយស្រួល ប៉ុន្តែបើចុងអង្ករគ្រាប់ធំ ត្រូវកិនឱ្យល្អិត ឬ ក៏ ត្រាំទឹក ៣-៤ ម៉ោងសិន សឹមឱ្យវាស៊ី ឬ ក៏យកទៅស្ងោរឱ្យឆ្អិន ។

**៤. កន្ទក់ :**

កន្ទក់អង្ករមានតម្លៃរស់ជាតិគួរសម ។ តម្លៃរស់ជាតិនេះប្រែប្រួលទៅតាមរបៀបកិនអង្ករ និង អត្រាអង្កាមនៅក្នុងកន្ទក់ ។

កន្ទក់លេខ ១ មានអត្រាជាតិសាច់ ១២,៩ % និងជាតិសែលុយឡូស ៨,៦ % ។ កន្ទក់លាយអង្កាមមានជាតិសែលុយឡូសរហូតដល់ ៣0% ។ ចំពោះកូនជ្រូកអាចលាយត្រឹម ៣0 % ចុះ ប៉ុន្តែចំពោះជ្រូកធំអាចលាយ ៥0 % ។

កន្ទក់មានជាតិប្រេងច្រើន ទុកយូរខូច ដុះផ្សិត កកជាដុំៗ ។ កន្ទក់ដែលកកជាដុំៗ ដុះផ្សិតនេះ ជ្រូកមិនចូលចិត្តស៊ី ព្រោះមិនឆ្ងាញ់ ហើយគ្មានរស់ជាតិ ។

## ៥. ដំឡូងមី :

ដំឡូងមីមានជាតិស្ករច្រើន ។ ដំឡូងមីក្រៀមឱ្យកំដៅច្រើន តែជាតិសាច់តិច ( ២ % ) ហើយគុណភាពមិនសូវល្អ ។ បើឱ្យជ្រូកស៊ីត្រូវប្រយ័ត្នជាតិពុល ( Acide Cyanhydrique ) ។ ជាតិពុលនេះមានច្រើននៅក្នុងសំបកមើម បើឱ្យស៊ីឆៅអាចឱ្យកូនជ្រូកងាប់ មេជ្រូករលូតកូន ។ ដូច្នេះដើម្បីការពារកុំឱ្យពុល ត្រូវបកសំបក រួចចិតឱ្យស្តើង ហាលឱ្យស្ងួត ឬក៏ស្ងោរឱ្យឆ្អិន ។ ចំពោះកូនជ្រូក និង មេជ្រូកពរពោះអាចឱ្យស៊ី៣០ % តែចំពោះជ្រូកសាច់ អាចឱ្យរហូតដល់ ៥០ % ក្នុងចំណី ។

## ៦. ដំឡូងជ្វា :

ដំឡូងជ្វាក៏ជាចំណីដ៏ល្អចំពោះជ្រូក ប៉ុន្តែជាតិសាច់មានត្រឹមតែ ២-២,៥ %, ជាតិសែលុយឡូសតិច សំបូរជាតិស្ករ ។ ជ្រូកអាចស៊ីច្រើនបាន អាចប្រើជាប្រភពផ្តល់កំដៅដល់ជ្រូកល្អ ។

ប្រើដំឡូងជ្វាឆៅ មិនមានមហន្តរាយដល់ជ្រូកទេ ប៉ុន្តែបើស្ងោរឱ្យឆ្អិនវាឆ្ងាញ់ជាង ។ ក្នុងការលាយចំណីឱ្យជ្រូក គេច្រើនចិតហាលឱ្យស្ងួតមុននឹងយកទៅកិនលាយជាចំណី ។

### ៧. កាកស្រា :

គុណភាពរបស់វាប្រែប្រួលទៅតាមវត្ថុធាតុដើម សំរាប់ធ្វើស្រា ។ កាកស្រាជាប្រភពផ្ដល់កំដៅដ៏ល្អ ក្រៅពីនេះក៏មានជាតិសាច់ និង វីតាមីន មួយចំនួន ។ មិនអាចទុកកាកស្រាបានយូរទេ ព្រោះងាយឡើងផ្សិត ។ ក្នុងចំណីឱ្យជ្រូក មិនត្រូវប្រើច្រើនលើសពី ៣០ % ។

### ៨. កាកស្ករ :

ជាសំណល់ពីរោងចក្រធ្វើស្ករ ។ ប្រើជាប្រភពផ្ដល់កំដៅល្អ ប៉ុន្តែត្រូវប្រយ័ត្ន ព្រោះអាចបណ្ដាលឱ្យជ្រូករាគ ។ ដូចនេះមិនគប្បីប្រើឱ្យលើសពី ១០ % ទេ ។

### ៩. កាកសំណល់ពីចង្ក្រានបាយ :

នៅតាមផ្ទះ ភោជនីយដ្ឋាន តៀមលក់បាយ លក់គុយទាវ សុទ្ធតែមានសំណល់ ដូចជាទឹកលាងអង្ករ បាយ សម្ល ទឹកលាងចាន ។ល ។ ដែលអាចយកទៅចិញ្ចឹមជ្រូកបានផលល្អ មានរស់ជាតិច្រើន ។

គួរកត់សំគាល់ថា កាកសំណល់ទាំងនេះជាកន្លែងងាយស្រួលឱ្យមេរោគរីកដុះដាល ។ ដូចនេះត្រូវស្ងោរវាឱ្យឆ្អិន ហើយក៏ត្រូវបន្ថែមចំណីមួយចំនួនទៀត ដើម្បីធានាការធំធាត់របស់ជ្រូក ។

សរុបមក ចំណីដែលផ្ដល់កំដៅ សុទ្ធតែជាចំណីដែលក្រជាតិសាច់ ជាតិរ៉ែ និង វីតាមីន បើមិនមានចំណីដទៃទៀតលាយផ្សំជាមួយទេ មិនអាចចិញ្ចឹមជ្រូកឱ្យឆាប់ធំសមតាមបំណងឡើយ ។

ទៅតាមអាយុ និង តំណាក់កាលធំធាត់របស់ជ្រូក អាចប្រើចំណីផ្ដល់កំដៅពី ៧០-៩០ % .

## C- ជាតិរ៉ែ :

ជាតិរ៉ែជាចំណែកដ៏សំខាន់ក្នុងការបង្កើតឆ្អឹង ធ្មេញ ។ ជាតិរ៉ែចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្លាស់ប្តូរជាតិនានានៅក្នុងខ្លួន ។ គេបែងចែកជាតិរ៉ែជាពីរប្រភេទធំៗ ដូចតទៅនេះ :-

**ធាតុរ៉ែអង្គធាតុធំ** ( Macroélément ) :

ជាជាតិដែលសរីរាង្គត្រូវការជាចំនួនច្រើនដូចជា Ca, P, Mg, Cl, Na, K.

**ធាតុរ៉ែអង្គធាតុតូច** ( Microélément ) :

ជាជាតិរ៉ែដែលជ្រូកត្រូវការជាចំនួនតិចដូចជា Fe, Cu, Zn, Mn, Co, I .

ទោះបីជា ជាតិរ៉ែមានចំនួនតិចនៅក្នុងចំណី ប៉ុន្តែបើខ្វះនោះវានឹងបង្ហាញនូវរោគសញ្ញាខាងក្រៅភ្លាម ។

### ១- ជាតិកាល់ស្យូម និង ផូស្វ័រ ( Ca & P ) :

ជាតិកាល់ស្យូម និង ផូស្វ័រ ជាជាតិពីរយ៉ាងសំខាន់មានទំនាក់ទំនងគ្នាយ៉ាងសំខាន់ ។ ជាតិទាំងពីរនេះសំខាន់ចំពោះការបង្កើតឆ្អឹង ។ ចំណីសំរាប់ចិញ្ចឹមជ្រូក ត្រូវមានជាតិកាល់ស្យូម និង ផូស្វ័រគ្រប់គ្រាន់ ហើយត្រូវមានសមភាពនឹងគ្នា $\frac{Ca}{P}$ អាចប្រែប្រួលពី $\frac{1}{1}-\frac{2}{1}$ ទៅតាមអាយុ និង ប្រភេទជ្រូក ។ ក្រៅពីនេះត្រូវមានវីតាមីន D សំរាប់ជួយដល់ការបឺតយកជាតិរ៉ែទាំងពីរនេះ ។

ចំពោះកូនជ្រូកខ្វះ Ca បណ្តាលឱ្យឆ្អឹងមិនរីកធំ ជ្រូកក្រិនក្រធំ ។ ចំពោះមេជ្រូកពរពោះ និង ចិញ្ចឹមកូន បើខ្វះជាតិ Ca នោះវានឹង

យកជាតិ Ca ពីឆ្អឹងរបស់វា ដើម្បីចិញ្ចឹមកូនក្នុងពោះ និង បញ្ចេញទឹកដោះ ជាហេតុបណ្តាលឱ្យមេជ្រូកខ្សោយជើង ស្ពឹក· ងាយបាក់ឆ្អឹង ទឹកដោះមិនសូវចេញ ឬ ក៏គ្មានទឹកដោះតែម្តង ។

*** ចំណីផ្តល់ Ca និង P :**

នៅប្រទេសយើង ជាទូទៅគេនិយមប្រើសំបកខ្យងខ្មៅ សំបកគ្រែង (ងាវ) ក្នុងការផ្គត់ផ្គង់ Ca និងប្រើម្សៅឆ្អឹងក្នុងការផ្គត់ផ្គង់ទាំង Ca ទាំង P ។

**ចំណីដែលសំបូរ Ca និង P**

| ប្រភេទចំណី | Ca (%) | P (%) |
|---|---|---|
| ម្សៅខ្យងខ្មៅ លៀស គ្រែង | ៣៨ | - |
| កំបោរ | ៣៨ | - |
| ម្សៅឆ្អឹង | ២៤-២៩ | ១២-១៤ |
| ម្សៅ Dicalci phosphate | ២៣-២៦ | ១៨-២១ |

## ២. អំបិល ( NaCl )

អំបិលជាចំណីដែលផ្តល់រសជាតិផង ជំរុញឱ្យស៊ីឆ្ងាញ់ផង ។ ចំណីខ្លះជាតិអំបិល ជ្រូកមិនសូវស៊ី ព្រោះមិនឆ្ងាញ់ ( សាប ) ។ ចំពោះជ្រូកគេច្រើនលាយ ០,៥ % ។ បើលាយរហូត ២ % នោះអាចបណ្តាលឱ្យជ្រូកពុល ប្រសិនបើគ្មានទឹកផឹកគ្រប់គ្រាន់ទេ ។ ប្រសិនបើយើងប្រើម្សៅត្រីទឹកប្រៃជាចំណីជ្រូកនោះ ត្រូវប្រយ័ត្នចំពោះជាតិអំបិល ។

## ៣. ជាតិដែក ( Fe )

កូនជ្រូកក្នុងអាយុ ៣ អាទិត្យចុះ ច្រើនខ្វះជាតិដែក ។ ក្នុងរយៈកាលនេះបើមិនបានផ្តល់ជាតិដែកគ្រប់គ្រាន់ទេ នោះនឹងបណ្តាលឱ្យកូនជ្រូកមានជំងឺខ្វះឈាម អន់ចំណី ក្រិន រាគអាចម៍ និង ងាយកើតជំងឺដទៃទៀត។

ហេតុអ្វីត្រូវបន្ថែមជាតិដែកដល់កូនជ្រូកអាយុ ៣ អាទិត្យចុះ ?

ព្រោះថាជាតិដែកចូលរួមក្នុងការបង្កើតឈាម ហើយក្នុងទឹកដោះមេជ្រូកមានជាតិដែកតិច មិនអាចឆ្លើយតបនឹងសេចក្តីត្រូវការរបស់កូន ជ្រូក ។ ធម្មតាពេលកើត កូនជ្រូកមានជាតិដែក ៥០ មក្រ ក្នុងខ្លួន ហើយក្នុងមួយថ្ងៃ កូនជ្រូកត្រូវការជាតិដែក ៧ មក្រ ។ ក្នុងទឹកដោះដែលកូនជ្រូកបៅអាចមានត្រឹម ១ មក្រ ។ ដូចនេះក្នុងមួយអាទិត្យនឹងអស់ជាតិដែកពីក្នុងខ្លួន ។ យ៉ាងនេះបានជាយើងត្រូវផ្តល់ជាតិដែកដល់កូនជ្រូកដោយ :

- ចាក់ថ្នាំដែលមានជាតិដែក ដូចជា Ferdextran ឬ Ferrodex
- ឱ្យផឹកថ្នាំ Syrop ដែក
- ប្រើដីឥដ្ឋស្អាត បោះទៅក្នុងទ្រុងឱ្យវាទំពារ ផ្សំនឹងការលែងឱ្យវាដើរក្នុងវាលស្មៅ ។
- ពេលវាចេះស៊ីចំណី នោះក្នុងចំណីមានជាតិដែកគ្រប់គ្រាន់ហើយ។

## ៤. ស័ង្កសី (Zn)

ជាតិស័ង្កសីនេះក៏មានសារៈសំខាន់ចំពោះជ្រូក ។ ខ្វះជាតិស័ង្កសីជ្រូកមានជំងឺម្យ៉ាងឈ្មោះ Parakératosis ធ្វើឱ្យស្បែកឡើងហើម ជ្រូកអន់ចំណី ក្រពុំធាត់ ។

កង្វះជាតិសង្កសី អាចបណ្ដាលមកពីចំណីខ្វះជាតិនេះ ឬក៏បណ្ដាលមកពីក្នុងចំណីសំបូរជាតិ Ca. Fe. ជាតិខ្លាញ់ដែលធ្វើឱ្យជ្រូកបឺតយកជាតិ Zn នេះមិនបាន ។ ចំពោះកូនជ្រូកខ្វះជាតិ Zn មានរោគសញ្ញាដូចតទៅនេះ ដំបូងនៅកន្លែងស្បែកស្តើង ដូចជានៅពោះ ក្រលៀនភ្លៅក្រោយ ស្លឹកត្រចៀកមានចំណុចក្រហម ។ ចំណុចក្រហមនេះក្រោយមករាលដាលពេញខ្លួន ។ ចំណុចពិសេសនៃចំណុចក្រហមគឺមានទាំងសង្ខាងខ្លួន រួចធំឡើងៗ ចេញជាក្រមរ ហើយអាចមានជំងឺប៉ារ៉ាស៊ីតដែលបណ្ដាលឱ្យជ្រូករមាស់ ពិបាកទ្រាំ ។

## D - វីតាមីន :

### ១. វីតាមីន A ( Rétinol ) :

ជាជីវជាតិបង្កើនការលូតលាស់ ការពារស្បែក ។ ល ។

ក្នុងចំណីជ្រូក ខ្វះវីតាមីន A អាចបណ្ដាលឱ្យជ្រូកក្រពំ ហើមភ្នែក មេជ្រូកអាចរលូតកូន កូនជ្រូកកើតឡើងខ្វាក់ភ្នែក ។

បន្លែស្រស់ ពោតក្រហម ល្ពៅ ដំឡូងផ្កាក្រហម ការ៉ុត សំបូរការ៉ូតែន ។ ជាតិការ៉ូតែនក្នុងខ្លួនជ្រូក បំលែងទៅជាវីតាមីន A ។ ខ្លាញ់ថ្លើមត្រីសំបូរវីតាមីនអា ។ ចំណីដទៃទៀតក្រៅពីនេះ សុទ្ធតែខ្វះវីតាមីន A។

### ២. វីតាមីនដេ D ( Calciférol ) :

វីតាមីន D ជាវីតាមីនប្រឆាំងជំងឺក្រិន ព្រោះវាចាំបាច់ក្នុងការបឺតយកជាតិ Ca និង P ។ នៅក្រោមស្រទាប់ស្បែកសត្វ មានប៉ុវីតាមីន Provitamine D ច្រើន កាលណាមានពន្លឺថ្ងៃជះចំ ជាតិនេះក៏ក្លាយទៅ

ជាវីតាមីន D ។ វីតាមីន D មាននៅក្នុងខ្លាញ់ត្រី ម្សៅត្រី លឿងស៊ុត ទឹកដោះគោ និង ក្នុងចំណីដែលមានដើមកំណើតពីសត្វ ។

### ៣. វីតាមីន E ( Tocopherol ) :

កង្វះវីតាមីន E លទ្ធភាពផលិតរបស់ជ្រូកខ្សោយ រលូតកូន កូនងាប់ក្នុងពោះ គ្មានតណ្ហា ។ វីតាមីន E មានច្រើននៅក្នុងពន្លកគ្រាប់ធញ្ញជាតិ ប្រេងគ្រាប់ធញ្ញជាតិ សាច់ជ្រូក សាច់គោ សាច់ចៀម លឿងស៊ុត ។ ល ។

### ៤. វីតាមីន $B_2$ ( Riboflavine , Lactoflavin )

កង្វះវីតាមីននេះជ្រូកក្រពំ អន់ចំណី បណ្តាលឱ្យមានជំងឺហើមស្បែករង្គោះរោម រាគអាចម៍ ក្អួតចង្អោរ ខ្វាចពន្លឺថ្ងៃ កូនងាប់ក្នុងពោះ ឬក៏កើតមកគ្មានរោម ឬក៏មានដែរ តែរង្គោះអស់ ។

ចំណីដែលសំបូរវីតាមីន $B_2$ : បន្លែស្រស់ ម្សៅត្រី ម្សៅសាច់ ម្សៅឆ្អឹង ម្សៅទឹកដោះគោ ។ ល ។

### ៥. វីតាមីន $B_3$ ( Acide pantotenic )

កង្វះវីតាមីន $B_3$ បណ្តាលឱ្យជ្រូកថយការធំធាត់ប្រចាំថ្ងៃ អន់ចំណី រាគ រលាកស្បែក រង្គោះរោម ពិបាកដើរ ដើរដួចលោត ទន់ជើងក្រោយ រលាកផ្លូវរំលាយអាហារ មេជ្រូកអត់រកឈ្មោល ជួនរកឈ្មោលតែគ្មានកូន ជួនមានកូនតែកូនខ្សោយ ។

វីតាមីន $B_3$ មាននៅក្នុងថ្លើម លឿងស៊ុត ដំបែ មើមរុក្ខជាតិ ។

**៦. វីតាមីន PP = $B_5$ ( Niacine , Nicotinamide, Antipellagreux ) :**

កង្វះវីតាមីន PP ជ្រូកក្រធំ មានជំងឺសើរស្បែក ជ្រុះរោមនៅត្រចៀក រោមបះ ហើមពោះវៀន រាគ ។ ចំណីដែលសំបូរវីតាមីន PP មានកាកស្រា កាកប្រេងសណ្តែកដី កន្ទក់ គ្រាប់ស្មៅ Gramen ។

**៧. វីតាមីន $B_{12}$ ( Cobalamin, Antianémique )**

កង្វះវីតាមីន $B_{12}$ បណ្តាលឱ្យជ្រូកខ្វះឈាម រាគ ក្អួក ខូចក្រលៀន ខ្វិនជើងក្រោយ ។ លទ្ធភាពផលិតរបស់មេជ្រូកចុះខ្សោយ ។ ចំណីសំបូរវីតាមីន B12 មានម្សៅត្រី ម្សៅសាច់ ម្សៅទឹកដោះគោ ។

**សង្ខេប :**

ត្រូវធ្វើយ៉ាងណាលាយចំណីឱ្យមានវីតាមីនគ្រប់សព្វ ។ ក្រៅពីនេះក្នុងការចិញ្ចឹមជ្រូកគេច្រើនប្រើ Prémix ព្រោះថាក្នុង Prémix មានវីតាមីនគ្រប់មុខ ។

## E - ជាតិសែលុយឡូស ( Cellulose )

លទ្ធភាពប្រើប្រាស់សែលុយឡូសរបស់ជ្រូកមានកំរិត ។ ជ្រូកធំមានលទ្ធភាពប្រើប្រាស់ខ្ពស់ជាងកូនជ្រូក ។ ចំណីដែលមានជាតិសែលុយឡូសច្រើនគឺ មានគុណភាពអន់ ព្រោះមានឥទ្ធិពលដល់ការំលាយអាហារ។

ចំពោះកូនជ្រូកទើបផ្តាច់ដោះ ក្នុងចំណីមិនត្រូវឱ្យមានជាតិសែលុយឡូសលើសពី ៧ % ទេ តែចំពោះមេជ្រូកអាចប្រើដល់ ១០-១៣ % ។ ក្នុងចំណីរបស់ជ្រូកត្រូវមានជាតិសែលុយឡូសគ្រប់គ្រាន់ ដើម្បីធានាឱ្យជ្រូក

មានអារម្មណ៍ថាវាបានស៊ីឆ្អែត ។ ជាតិសៃលុយឡូសជួយក្នុងការរំលាយអាហារ ប្រឆាំងនឹងជំងឺទល់លាមក ។ ជាតិសៃលុយឡូសជួយមេជ្រូកមិនឱ្យធាត់កកខ្លាញ់ ដែលអាចបំបាត់ជំងឺរលាកដោះ រលាកស្បូន និង អត់ទឹកដោះ ។

បន្លែស្រស់មានជាតិសៃលុយឡូស និង សំបូរវីតាមីន ។ ដូចនេះត្រូវបន្ថែមបន្លែស្រស់ដល់ជ្រូក ។

**សង្ខេប :**

ដើម្បីឱ្យការចិញ្ចឹមជ្រូកទទួលបានលទ្ធផលល្អ ពេលលាយចំណីត្រូវយកចិត្តទុកដាក់ចំពោះចំណុចដូចតទៅ :-

១- ត្រូវធានាឱ្យបានគ្រប់គ្រាន់ទាំងគុណភាព ទាំងបរិមាណ ។ មានន័យថាត្រូវឱ្យជ្រូកស៊ីឱ្យឆ្អែត ហើយឱ្យមានរស់ជាតិ ។

២- ចំណីត្រូវតែល្អ ឆ្ងាញ់ មិនត្រូវឱ្យស៊ីតែមួយមុខទេ ព្រោះថាចំណីច្រើនមុខ មានជីវជាតិច្រើនយ៉ាងដែលជ្រូកចូលចិត្ត ។

៣- ចៀសវាងកុំប្រើចំណីដែលមានឥទ្ធិពលមិនល្អដល់សុខភាពដល់ការរំលាយអាហារ ដូចជាពពួកចំណីដែលមានជាតិពុល មានជាតិប្រឆាំងនឹងអង្គធាតុរំលាយអាហារ ។

៤- គប្បីប្រើប្រាស់ចំណីដែលមានតម្លៃថោក ដែលនៅមូលដ្ឋានរបស់យើងមានស្រាប់ ។

៥- មិនត្រូវផ្លាស់ប្តូរចំណីភ្លាមៗទេ តែត្រូវផ្លាស់ប្តូរបន្តិចម្តងៗ ។

# តម្លៃសារជាតិចំណីមួយចំនួនសំរាប់ជ្រូក

| ឈ្មោះចំណី | ថាមពល ME (Kcal) ក្នុងចំណី 1 Kg | ចំនួនសារជាតិ g/kg | | | | | |
|---|---|---|---|---|---|---|---|
| | | ជាតិសាច់ Protein | ជាតិខ្លាញ់ Lipide | ជាតិស្ករ Glucide | ជាតិសែលុយឡូស Cellulose | ជាតិកាល់ស្យូម (Ca) | ជាតិផូស្វ័រ (P) |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| **ប្រភេទចំណីស្រស់** | | | | | | | |
| ដើមព្រលិត | 150 | 8 | 3 | 36 | 15 | 1,60 | 0,40 |
| ដើមពោតខ្ចី | 282 | 14 | 4 | 67 | 34 | 0,80 | 0,30 |
| ស្មៅជីវ (ដើមនិងស្លឹក) | 241 | 22 | 4 | 43 | 32 | 0,40 | 0,20 |
| ទងដំឡូងជ្វា | 311 | 24 | 7 | 68 | 24 | 1,30 | 0,60 |
| ត្រកួន | 267 | 21 | 7 | 47 | 16 | 1,20 | 0,50 |
| ដើមចេកកាប់ផ្លែហើយ | 93 | 6 | 2 | 23 | 20 | 0,50 | 0,10 |
| **ប្រភេទមើម** | | | | | | | |
| ដំឡូងជ្វា | 970 | 9 | 5 | 234 | 9 | 0,80 | 0,40 |
| ដំឡូងជ្វាក្រៀម | 3192 | 32 | 17 | 771 | 22 | 1,70 | 1,60 |
| ដំឡូងមីអត់សំបក | 1131 | 9 | 6 | 286 | 7 | 0,80 | 0,50 |
| ដំឡូងមីក្រៀម | 3097 | 29 | 17 | 772 | 34 | 0,50 | 1,60 |

| (1) | (2) | (3) | (4) | (5) | (6) | (7) | (8) |
|---|---|---|---|---|---|---|---|
| ប្រភេទគ្រាប់, កន្ទក់ : | | | | | | | |
| ពោតក្រហម | 3242 | 93 | 42 | 702 | 31 | 0,90 | 1,40 |
| អង្ករខ្សាយ | 3329 | 84 | 15 | 758 | 6 | 1,10 | 2,0 |
| ចុងអង្ករខ្សាយ | 2976 | 95 | 19 | 726 | 8 | 1.30 | 3.40 |
| ស្រូវខ្សាយ | 2701 | 74 | 22 | 640 | 105 | 2.20 | 2,70 |
| គ្រាប់សណ្តែកសៀង | 3757 | 370 | 163 | 239 | 64 | 2,90 | 5,60 |
| គ្រាប់សណ្តែកដី | 5041 | 279 | 446 | 148 | 27 | 1,20 | 3,80 |
| កន្ទក់លេខមួយ | 2527 | 131 | 121 | 462 | 78 | 1,70 | 16,50 |
| កន្ទក់លេខពីរ | 1782 | 98 | 68 | 398 | 187 | 3,20 | 5,40 |
| ប្រភេទកាកប្រេង | | | | | | | |
| កាកសណ្តែកដីគាបទាំងសំបក | 2416 | 306 | 84 | 221 | 230 | 3,70 | 4,40 |
| កាកសណ្តែកដីអត់សំបក | 3306 | 454 | 70 | 266 | 53 | 1,70 | 5,30 |
| កាកដូង | 2647 | 193 | 68 | 457 | 120 | 2,90 | 3,40 |
| កាកគ្រាប់កប្បាស | 2526 | 329 | 60 | 288 | 183 | 2,0 | 10,0 |
| កាកសណ្តែកសៀង | 3342 | 425 | 74 | 243 | 59 | 2,60 | 6,70 |
| ប្រភេទម្សៅ | | | | | | | |
| ម្សៅត្រីទឹកសាបលេខ១ | 3341 | 593 | 83 | - | - | 51,41 | 28,0 |

| (1) | (2) | (3) | (4) | (5) | (6) | (7) | (8) |
|---|---|---|---|---|---|---|---|
| ម្សៅត្រីទឹកសាប លេខ២ | 3223 | 535 | 104 | - | - | 51.0 | 29.0 |
| ម្សៅក្បាលនិងស្រកាត្រីស្រស់ | 2434 | 407 | 101 | 23 | - | 57.50 | 32.0 |
| ម្សៅឈាម | 3383 | 801 | 38 | 20 | - | 3.20 | 2.50 |
| ម្សៅខ្ទងខ្ចៅទាំងសំបក | 190 | 29 | 8 | 128 | - | 89 | 4 |
| ម្សៅឆ្អឹង | 1501 | 281 | 47 | 82 | 20 | 187.0 | 105.0 |
| កំបោររស់ | - | - | - | - | - | 300 | - |
| ម្សៅ Phosphate Dicalcique | - | - | - | - | - | 248 | 174 |
| ម្សៅPhosphate Tricalcique | - | - | - | - | - | 328 | 162 |

# សេចក្តីត្រូវការរសជាតិសំរាប់ជ្រូក

## បរិមាណរសជាតិក្នុងចំណី ១ គក្រ

តាមប្រភពឯកសារ : NRC 1988

| រសជាតិ | ទំងន់ជ្រូក | | | | | ជ្រូកបានិង មេជ្រូក | មេជ្រូក បំបៅកូន |
|---|---|---|---|---|---|---|---|
| | 1-5 | 5-10 | 10-20 | 20-50 | 50-110 | | |
| ថាមពល ME Kcal ក្នុងមួយថ្ងៃ | 805 | 1490 | 3090 | 6200 | 10185 | 3200 Kcal ក្នុងចំណី ១ គក្រ | 3210 Kcal ក្នុងចំណី ១គក្រ |
| ជាតិសាច់ (CP) % | 24 | 20 | 18 | 15 | 13 | 12 | 13 |
| Lysine % | 1.40 | 1.15 | 0.95 | 0.75 | 0.60 | 0.43 | 0.60 |
| Meth + Cystine % | 0.68 | 0.58 | 0.48 | 0.41 | 0.34 | 0.23 | 0.36 |
| Trypto-phane % | 0.20 | 0.17 | 0.14 | 0.12 | 0.10 | 0.09 | 0.12 |
| acide Li-noleic % | 0.10 | 0.10 | 0.10 | 0.10 | 0.10 | 0.10 | 0.10 |
| កាល់ស្យូម (Ca) % | 0.90 | 0.80 | 0.70 | 0.60 | 0.50 | 0.75 | 0.75 |
| ផូស្វ័រសរុប (P) % | 0.70 | 0.65 | 0.60 | 0.50 | 0.40 | 0.60 | 0.60 |
| វីតាមីន A (UI) | 2200 | 2200 | 1750 | 1300 | 1300 | 4000 | 2000 |
| វីតាមីន D (UI) | 220 | 220 | 200 | 150 | 150 | 200 | 200 |
| វីតាមីន E (UI) | 16 | 16 | 11 | 11 | 11 | 22 | 22 |

# IV - របៀបចិញ្ចឹមមេជ្រូក

## A- របៀបចិញ្ចឹមមេជ្រូកមុនពេលដាក់ឈ្មោល :

ការចិញ្ចឹមមេជ្រូកមានសារៈសំខាន់ ដោយត្រូវផ្គត់ផ្គង់ពូជជ្រូកឱ្យបានច្រើន និង មានគុណភាពល្អ ។

ដើម្បីឱ្យបានកូនល្អ ត្រូវមានបាពូជល្អ និង មេពូជល្អ ហើយត្រូវថែទាំ និង ចិញ្ចឹមវាឱ្យបានល្អ ដើម្បីឱ្យវាបន្តលក្ខណៈល្អនេះដល់កូនចៅជំនាន់ក្រោយ ។

មេជ្រូករកឈ្មោលក្នុងអាយុ ៦-៧ ខែ ។ ចំណែកពូជក្នុងស្រុករហ័សជាងនេះ ។ អំពីវិស័យសេដ្ឋកិច្ច មេជ្រូករហ័សរកឈ្មោលកាលណាល្អកាលនោះ ។ ប៉ុន្តែដើម្បីឱ្យបានកូនក្នុងមួយសំបុកច្រើន កូនជ្រូកមានសុខភាពល្អ ចិញ្ចឹមឆាប់ធំ ។ ល ។ ត្រូវរង់ចាំឱ្យខ្លួនមេជ្រូកធំពេញរូបរាងសិន ។ ដូចនេះការដាក់ឈ្មោលឱ្យមេជ្រូកណាមួយជាលើកដំបូង គឺអាស្រ័យលើអាយុ និង មាឌរបស់វា ។

### a)- កត្តាមានឥទ្ធិពលដល់អាយុពេញវ័យរបស់ជ្រូកញី :

#### ពូជ :

ពូជក្នុងស្រុកឆាប់ពេញវ័យជាងពូជបរទេស ។ ពូជជ្រូកកណ្ដុរ ៣-៤ ខែ រកឈ្មោល ចំណែកពូជបរទេសដូចជា យ៉កសៀ និង ឡែនរីស អាយុ ៦-៧ ខែទើបរកឈ្មោល ។

## - ការចិញ្ចឹម និង ថែទាំ :

ចិញ្ចឹមមិនសមស្រប ធ្វើឱ្យជ្រូកធាត់ពេក ឬ ស្គមពេក សុទ្ធតែមានឥទ្ធិពលដល់អាយុពេញវ័យរបស់ជ្រូក ។ ចិញ្ចឹមក្នុងទ្រុងចង្អៀត ចង្អៀតមេជ្រូកក្ររកឈ្មោល ព្រោះប្រដាប់បន្តពូជមិនរីកចំរើន ។

- ជ្រូកដែលកើតចេញពីមេ ឋា យកបងប្អូនឯង ក្រពេញវ័យជាងជ្រូកដែលកើតចេញពីមេ ឋា ដែលមានឈាមឆ្ងាយពីគ្នា ។

ដូចនេះក្នុងការចិញ្ចឹមជ្រូកញី ត្រូវធ្វើយ៉ាងណាកុំឱ្យវាធាត់ពេក ឬស្គមពេក ។ ត្រូវឱ្យចំណីដែលមានរសជាតិគ្រប់គ្រាន់ ត្រូវចិញ្ចឹមក្នុងទ្រុងធំទូលាយ មានខ្យល់អាកាសចេញចូលគ្រប់គ្រាន់ ដើម្បីឱ្យប្រដាប់បង្កើតកូនរបស់ជ្រូកញីមានសកម្មភាពជាធម្មតា ។

ទោះបីជាជ្រូកញីពេញរូបរាងខាងសរីរាងហើយក៏ដោយ ក៏យើងត្រូវរង់ចាំឱ្យវារកឈ្មោលជាលើកទី ៣ ឬ ទី ៤ សិន ។ ធ្វើយ៉ាងនេះនឹងបាន កូនច្រើន កូនល្អ ហើយអត្រាងាប់តិច ។

ការដាក់ឈ្មោលយឺតពេកក៏មិនល្អដែរ ព្រោះម្យ៉ាងយើងត្រូវខាតបង់ចំណីច្រើន ម្យ៉ាងទៀតជ្រូកធាត់ ដុះខ្លាញ់ពិបាកដាក់ឈ្មោល ហើយកូនកើតឡើងតិច ។

ផ្ទុយទៅវិញបើយើងដាក់ឈ្មោលឱ្យវា តាំងពីពេលរកឈ្មោលជាលើកដំបូង ក្នុងពេលដែលខ្លួនវានៅតូច នោះនឹងបានកូនតិច ហើយអត្រាងាប់ក៏ខ្ពស់ ខ្លួនមេជ្រូកនោះក៏លែងធំធាត់ ។ ក្រោយពេលកើតកូនលើកទី១ ត្រូវឱ្យមេជ្រូកសំរាកបានយូរបន្តិចសិន សឹមដាក់ឈ្មោល ទៀត ។

## ៦)- របៀបដាក់ឈ្មោលឱ្យជ្រូកញី និង ពេលវេលាដាក់ឈ្មោលសមស្រប :

### - ជ្រូកញីរកឈ្មោល :

ពេលរកឈ្មោលជ្រូកញីផ្លាស់ប្តូររាងរៅទ្វារខាងក្រៅ និង អត្តចរិករបស់វា ។

### * ទ្វារខាងក្រៅ :

ហើមធំជាងធម្មតា ពណ៌ក្រហម ។ ជ្រូកឈរមិនស្ងៀម ដេកមិនស្ងៀម ស្រែកអុកៗតិចៗ ស៊ីតិច ជួនក៏មិនស៊ី ខាំកកេរទ្រុង ឡើងពាក់លើជ្រូកផ្សេងទៀត ជួនកាលពេលណាមានជ្រូកឡើងពាក់លើវា វានៅសម្ងំស្ងៀម ។ ពេលនោះបើយើងយកដៃសង្កត់ខ្នងវា វានៅស្ងៀម ហើយស្ទីកត្រចៀកបះត្រង់ឡើងលើ ។

ប៉ុន្តែក៏មានជ្រូកខ្លះពេលរកឈ្មោល ទ្វារខាងក្រៅហើមក្រហម តែគ្មានបង្ហាញលក្ខណៈអ្វីផ្សេងទៀតទេ ដូច្នេះយើងត្រូវតាមដានឱ្យបានដិតដល់ដើម្បីដាក់ឈ្មោលឱ្យបានទាន់ពេលវេលា ។

រយៈពេលរកឈ្មោលរបស់ជ្រូកញី បន្ទាយពី ១ ទៅ ៥ ថ្ងៃ ទៅតាមពូជ និង អាយុ ( មេក្មេង ឬ មេចាស់ ) ។ រយៈពេលរកឈ្មោលរបស់ពូជជ្រូកក្នុងស្រុក ៣-៤ ថ្ងៃ តែចំពោះជ្រូកយ៉កសៀ , ឌូរ៉ុក ២-៣ ថ្ងៃ ។

### * វដ្តរបស់ជ្រូកញី :

តាមធម្មតាចន្លោះពីវដ្តមួយទៅវដ្តមួយមានរយៈពេល ២១±២.៥ ថ្ងៃ ។ ក្រោយពេលផ្តាច់ដោះ ៣-៥ ថ្ងៃ បើយើងបំប៉ន និង ថែទាំវាបានល្អនោះ មេជ្រូកនឹងរកឈ្មោលឡើងវិញ ។

បើរហ័សផ្ដាច់ដោះ នោះមេជ្រូកក៏រហ័សរកឈ្មោល ។

មានមេជ្រូកមួយចំនួនទើបនឹងបង្កើតកូនហើយ ឬ ក៏ដាក់ឈ្មោលមានកូនទៅហើយ តែនៅរកឈ្មោលទៀត ការរកឈ្មោលរបៀបនេះយើងឱ្យឈ្មោះថា ការរកឈ្មោលក្លែងក្លាយ ។

*** ពេលវេលាដាក់ឈ្មោលសមស្រប :**

ក្រោយពេលមេជ្រូករកឈ្មោលចំនួនពីរថ្ងៃទើបពងជ្រុះ បើដាក់ឈ្មោលក្នុងពេលនោះនឹងបានកូនច្រើន ។ កាលណាពិនិត្យឃើញទ្វារប្រែពណ៌ពីក្រហមទៅខៀវព្រលែត ស្រកហើម ហើយមានទឹករំអិលហូរចេញ ពេលនោះជាពេលពងជ្រុះហើយ ។ ចំពោះពូជជ្រូកក្នុងស្រុក អាចដាក់ឈ្មោលនៅដើមថ្ងៃទី ៣ ។

គប្បីដាក់ឈ្មោលក្នុងពេលព្រឹកព្រហាម ឬ ពេលល្ងាចត្រជាក់មុនពេលឱ្យវាស៊ីចំណី ។ កន្លែងដាក់ឈ្មោល ត្រូវរាបស្មើ និង ស្ងប់ ស្ងាត់ ។ ក្រោយពេលដាក់ឈ្មោលរួច មិនត្រូវមុជទឹក ឬ ក៏ឱ្យជ្រូកដេក ក្នុងភក់ជ្រាំទេ ព្រោះអាចបណ្ដាលឱ្យគ្មានកូន ឬ ក៏មានជំងឺផ្សេងៗ ។ គប្បីដាក់មេជ្រូកក្នុងទ្រុងមួយដោយឡែក កុំឱ្យវាឡើងជាន់គ្នា ឬ ខាំគ្នា ដែលអាចបណ្ដាលឱ្យមានកូនតិច ។ អាកាសធាតុក្ដៅ ក៏ជាកត្តាបណ្ដាលឱ្យមានកូនតិចដែរ ។

**c)- កត្តាមានឥទ្ធិពលដល់ចំនួនពងជ្រុះ :**

ក្នុងរយៈពេលរកឈ្មោល ចំនួនពងជ្រុះចុះតិច ឬ ច្រើន សុទ្ធតែមានឥទ្ធិពលជាកត្តាកំណត់ដល់ចំនួនកូនកើតឡើង ។ កត្តាទាំងនោះមានៈ-

*** ពូជ :** ពូជផ្សេងគ្នា ចំនួនពងជ្រុះក៏ផ្សេងគ្នា។ ពូជយ៉កសៀ និង ឡែន រីស ពងជ្រុះច្រើន ។

*** កំរិតឈាមដូចគ្នា :**

មេជ្រូកដែលដាក់បាជាបងប្អូននឹងគ្នា មានពងជ្រុះតិច ។

មេជ្រូកចំណាស់មានពងជ្រុះច្រើនជាងមេជ្រូកក្មេង ។ តាមបទពិសោធន៍ បានបង្ហាញឱ្យឃើញថា កូនលើកទី ៤ និង ទី ៥ ពងជ្រុះច្រើនបន្ទាប់ពីនោះចុះជាបន្តបន្ទាប់ ។ មេជ្រូកឱ្យកូនល្អក្នុងអាយុពី ២ទៅ៤ ឆ្នាំ។

*** ចំណីអាហារ :**

ឱ្យចំណីអាហារល្អក្នុងពេលជ្រូកនៅជំទង់ និង មុនពេលដាក់ឈ្មោល នឹងបានចំនួនពងជ្រុះចុះច្រើន ។

*** កំដៅក្នុងទ្រុង :**

ទ្រុងក្តៅ ពងជ្រុះចុះតិច ។

d)- **មូលហេតុបណ្តាលឱ្យមេជ្រូកគ្មានកូនក្រោយដាក់ឈ្មោល** : - ដោយសារមេជ្រូកនោះមានវិបល្លាសខាងសរីរាង្គ មូលហេតុនេះពិបាកនឹងដឹងណាស់ ព្រោះប្រដាប់បង្កើតកូនមិនធម្មតា ដូចជាខូះបន្ទប់ពងដាច់ ឬ ស្ទះបំពង់នាំពង ។ មិនត្រូវរក្សាទុកមេជ្រូកបែបនេះធ្វើពូជទេ ។

- ដោយសារមេជ្រូកមានជំងឺផ្សេងៗដូចជា Brucellosis. Leptospirosis ដូចនេះត្រូវពិនិត្យ និង តាមដានឱ្យបានដិតដល់ ។

- **ដោយសារជ្រូកបា :**

**ទឹកកាមអន់គុណភាព :**

ដោយសារមានជំងឺ Brucellosis, Leptospirosis ។ ល ។

**ដោយសារការថែទាំ :**

- ដាក់ឈ្មោលមិនត្រូវពេលវេលា (រហ័សពេកឬក៏យឺតពេក)

- ចំណីខ្វះជីវជាតិ ចិញ្ចឹមមិនត្រឹមត្រូវ ជ្រូកធាត់ពេក ឬ ស្គមពេក ។
- ទ្រុងចង្អៀត និង ក្តៅពេក ។
- មកពីចាក់ថ្នាំការពារជំងឺប៉េស្តក្នុងពេលមានកូនក្នុងពោះ។

កាលណាជួបនឹងលក្ខណៈមេជ្រូកដាក់ឈ្មោលហើយគ្មានកូន ត្រូវធ្វើវិភាគរកមូលហេតុឱ្យបានច្បាស់លាស់ ដើម្បីមានវិធានការការពារ និងព្យាបាលបានទាន់ពេលវេលា ។

### e)- **វិធានការជំរុញមេជ្រូកឱ្យរកឈ្មោល និង ជំរុះពង :**

មេជ្រូករកឈ្មោល និង ជំរុះពង ជាសកម្មភាពសរីរៈសាស្ត្រយ៉ាងស្មុគ្រស្មាញរបស់មេជ្រូក ក្រោមឥទ្ធិពលនៃ Hormone និង សកម្មភាពរបស់សរសៃប្រសាទ ។

អាចជំរុញឱ្យមេជ្រូករកឈ្មោល និង ជំរុះពង តាមវិធានការ ដូចតទៅ :-

- **ប្រើជ្រូកឈ្មោល :**

ចំពោះមេជ្រូកដែលមិនរកឈ្មោលយូរថ្ងៃ ត្រូវយកជ្រូកបាមកដាក់ក្នុងទ្រុងជាមួយ ។

- **រំហើសផ្តាច់ដោះ :**

ដើម្បីរំហើសផ្តាច់ដោះ ត្រូវរំហើសបង្ខាត់ឱ្យកូនជ្រូកចេះស៊ីចំណី។

- ស្ពាប បំបៅសអង្កែល ក្រសោមដោះមេជ្រូក ។

## ក)- ចំណីអាហារ និង ការថែទាំជ្រូកញីជំទង់ និងជ្រូកញី មុនពេលដាក់ឈ្មោល :

ក្នុងតំណាក់កាលនេះ ត្រូវផ្តល់ចំណីអាហារមានជីវជាតិគ្រប់គ្រាន់ដល់ជ្រូក ប៉ុន្តែមិនត្រូវឱ្យជ្រូកធាត់ពេក ឬ ស្គមពេកទេ ។ បើស្គមពេកវាក្ររកឈ្មោល ពងជ្រុះតិច គុណភាពអន់ ។ បើជ្រូកធាត់កកខ្លាញ់ច្រើនពេកនឹងបណ្តាលឱ្យមេជ្រូកនោះក្លាយទៅជាជ្រូកអា ។

- ចំណីខ្វះជាតិសាច់ ពង (មេរូបញី ) ធំធាត់មិនធម្មតា ហើយជ្រុះតិច ។
- ខ្វះជាតិ កាល់ស្យូម ( Calcium ) ឬ វីតាមីន A អាចនឹងគ្មានកូន ឬ កូនតិច។

ដូចនេះចំណីសំរាប់មេជំទង់ មិនដូចចំណីសំរាប់ជ្រូកសាច់ទេ គឺត្រូវធានាឱ្យមានជាតិសាច់ ជាតិរ៉ែ និង ឱ្យបន្លែច្រើន ដើម្បីកុំឱ្យជ្រូកធាត់ដុះខ្លាញ់ ។

ទ្រុងត្រូវឱ្យទូលាយ ដើម្បីឱ្យជ្រូកធ្វើចលនាបានដោយសេរី ត្រូវឱ្យស្អាតបាត ស្ងួត មិនសើមប៉ផ្ទិចប៉ផ្ទាច់ ។

ត្រូវបង្ហាត់ឱ្យជ្រូក ជុះអាចម៍ ជុះនោមត្រូវកន្លែង ទម្លាប់នេះអាចឱ្យទ្រុងស្អាតពេលមានកូន ។

មុនពេលដាក់ឈ្មោល ត្រូវពិនិត្យសុខភាពរបស់មេជ្រូក ដើម្បីមានវិធានការបំប៉នចំណី ឬ ក៏ព្យាបាល ។ ចំពោះជ្រូកដែលធាត់ដុះ ខ្លាញ់ត្រូវឱ្យវាធ្វើចលនាឱ្យច្រើន និង បន្ថយចំណី ពិសេសចំណីផ្តល់ កំដៅ ។

## B - របៀបចិញ្ចឹមមេជ្រូកដើម :

ត្រូវធានាធ្វើយ៉ាងណាឱ្យកូនក្នុងពោះ រីកធំធាត់ជាធម្មតា មិនរលូតកូន កូនកើតមកមានសុខភាពល្អ ទម្ងន់ធ្ងន់ ហើយមេក៏មានសុខភាពល្អ ដើម្បីចិញ្ចឹមកូន ។

### ១. មេជ្រូកដើម :

ក្រោយពេលដាក់ឈ្មោល ២១ ថ្ងៃ បើមេជ្រូកមិនរកឈ្មោលទៀតទេ នោះអាចបញ្ជាក់ថាមេជ្រូកមានកូនហើយ ។ ប៉ុន្តែក៏មានលក្ខណៈខ្លះទោះជាមិនមានកូន ក៏មិនរកឈ្មោលទៀតដែរ នោះគឺមកពីមានជំងឺ ឬក៏មកពីចំណីអាហារ និង ការថែទាំមិនល្អ ។

មេជ្រូកមួយចំនួនមានកូនក្នុងពោះហើយ ក្រោយមួយវដ្ដ (២១ ថ្ងៃ ) រកឈ្មោលឡើងវិញ ប៉ុន្តែមិនច្បាស់លាស់ មិនព្រមឱ្យឈ្មោលពាក់ ហើយស៊ីចំណីធម្មតា នោះឈ្មោះថារកឈ្មោលក្លែងក្លាយ ។

អាចនឹងកំណត់បានថា មេជ្រូកមានកូន កាលណាឃើញ :-

- ជ្រូកដេកច្រើន ស៊ីច្រើន រោម ស្បែក ពីមួយថ្ងៃទៅមួយថ្ងៃកាន់តែរលោង ខ្លួនរីកធំ
- មានចរិកស្លូតបូត មានដំណើរធ្ងន់
- ដោះទាំងពីរជួរឡើងតឹង រីកធំ
- មិនចូលចិត្តនៅជិតជ្រូកឈ្មោល
- ក្រោយមានកូនពីរខែ ពោះធំច្បាស់

**a)- ការរីកធំធាត់របស់កូនក្នុងពោះ :**

រយៈពេលពរពោះជាមធ្យម ១១៤ ថ្ងៃ (៣ខែ ៣អាទិត្យ ៣ថ្ងៃ) ក្នុងរយៈពេលនេះគប្បីប្រុងប្រយ័ត្ន ជាពិសេសក្នុងតំណាក់កាល ទី ២:

**តំណាក់កាលទី១: ក្រោយពេលជាក់ឈ្មោលបាន ២០ថ្ងៃ:**

រយៈពេលនេះកូនខិតជាបណ្តើរៗទៅកាន់ដៃស្បូន រួចហើយធ្វើសំបុក នៅទីនោះ ស្រោមកូនក៏ចាប់មានជាបណ្តើរៗ ។

បទពិសោធន៍បានបញ្ជាក់ថា នេះជារយៈពេលដែលកូនក្នុងពោះងាប់ច្រើន ។ មូលហេតុដែលបណ្តាលឱ្យកូនក្នុងពោះមិនរីកធំធាត់មិនអាចបញ្ជាក់បានច្បាស់លាស់ទេ ប៉ុន្តែប្រហែលជាមកពីកត្តាពីរយ៉ាង ដូចតទៅនេះ :-

- មកពីពង ឬ កូនក្នុងពោះនោះតែម្តង
- មកពីចំណីខ្វះវីតាមីន A, $B_{12}$
- ចំណីផ្អូម ជុះផ្សិត មានជាតិពុល

**តំណាក់កាលទី២ : ពេលមានកូនពីរខែ :**

រយៈពេលនេះកូនក្នុងពោះរីកធំធាត់រហ័សណាស់ ពិសេសខែទីពីរ ។ ត្រូវផ្តល់ចំណីមានជីវជាតិគ្រប់គ្រាន់ ដើម្បីឱ្យកូនក្នុងពោះរីកធំធាត់។

**៦- តម្រូវការសារជាតិ :**

ចំណីត្រូវមានសារជាតិ ឆ្លើយតបនឹងតម្រូវការរបស់កូនក្នុងពោះ បន្ទាប់មកធានាតម្រូវការរបស់មេជ្រូក និងទុកមួយចំនួនក្នុងខ្លួន សំរាប់បញ្ចេញទឹកដោះចិញ្ចឹមកូន ។

ប្រសិនបើខ្វះជីវជាតិ កូនក្នុងពោះរីកធំធាត់មិនធម្មតា ទម្ងន់ស្រាលហើយអាចនឹងរលូត ក្នុងលក្ខណៈនេះ មេជ្រូកត្រូវចំណាយជាតិដែលរក្សាក្នុងខ្លួន ដើម្បីផ្តល់ដល់កូនក្នុងពោះ ដូចនេះមេជ្រូកនឹងចុះស្គម ហើយបញ្ចេញទឹកដោះមិនគ្រប់គ្រាន់ ។

សារជាតិដែលត្រូវផ្តល់ដល់មេជ្រូកក្នុងពេលពរពោះមាន :-

*** ជាតិសាច់ ( Protide ) :**

នេះជាជាតិដែលសំខាន់បំផុត ដើម្បីធានាឱ្យកូនក្នុងពោះធំធាត់ និង បង្កើតទឹកដោះ ។ គុណភាពជាតិសាច់ត្រូវតែល្អ និង ធានាឱ្យបាន ១° % ។

*** ជាតិរ៉ែ ( minéral ) :**

ជាតិកាល់ស្យូម និង ផូស្វ័រ ចាំបាច់ដល់ការបង្កើតឆ្អឹងរបស់កូនជ្រូក ។ ក្នុងចំណីត្រូវមាន កាល់ស្យូម ០.៧៥ % ផូស្វ័រ ០.៥០ % ។ បើខ្វះជាតិកាល់ស្យូម សុខភាពរបស់មេជ្រូកស្រុតចុះ ពិបាកកើត ទឹកដោះតិច ស្ពឹកជើង ងាយបាក់ឆ្អឹង កូនជ្រូកកើតឡើងខ្សោយ អត្រាងាប់ខ្ពស់ ។

ជាតិរ៉ែ ចាំបាច់ដល់ការរីកធំធាត់របស់កូនក្នុងពោះ និង បង្កើតទឹកដោះ ។ ចំនួនជាតិរ៉ែរក្សាទុកក្នុងខ្លួនបានតិច ឬ ច្រើន អាស្រ័យលើសុខភាពរបស់មេជ្រូក និង សារជាតិក្នុងចំណី ក្នុងពេលពរពោះ ។

*** វិតាមីន** ( Vitamine ) :

ចំណីរបស់មេជ្រូកត្រូវមានវីតាមីនគ្រប់គ្រាន់ ពិសេសវីតាមីន A , D, E កង្វះវីតាមីន A បណ្តាលឱ្យរលូតកូន កូនខ្សោយ និង ខ្វាក់ភ្នែក ។ ឱ្យមេជ្រូកស៊ី បន្លែស្រស់គ្រប់គ្រាន់ អាចដោះស្រាយកង្វះវីតាមីន A, E ព្រមទាំង អាចបំបាត់ជំងឺទល់លាមករបស់មេជ្រូកផង ។

កង្វះវីតាមីន D កូនក្នុងពោះក្រធំធាត់ មេជ្រូកមានជំងឺស្ពឹកងាយបាក់ឆ្អឹង ។ ដូចនេះចាំបាច់ត្រូវឱ្យមេជ្រូកពរពោះធ្វើចលនាក្រោមកំដៅថ្ងៃ នោះទើបមិនខ្វះវីតាមីន D ។

*** កំដៅ** ( Energie ) :

ក្នុងរយះពេលនេះត្រូវយកចិត្តទុកដាក់ដល់កំដៅក្នុងចំណី ។ ខ្វះកំដៅ មេជ្រូកស្គម ខ្សោយ កូនក្នុងពោះមិនរីកធំធាត់ ផ្ទុយទៅវិញបើកំដៅលើស បណ្តាលឱ្យមេជ្រូកធាត់ ពិបាកកើតកូន ពេលកើតកូនច្រើនមានជំងឺរលាកដោះ រលាកស្បូន អត់ទឹកដោះ ។ ដើម្បីការពារកុំឱ្យមានជំងឺនេះ មួយអាទិត្យមុនពេលកើត ត្រូវបន្ថយចំណីផ្តល់កំដៅ $\frac{1}{3}$ រួចបន្ថែមបន្លែស្រស់ជំនួស ។

ត្រូវឧស្សាហ៍ពិនិត្យសុខភាពរបស់មេជ្រូក ដើម្បីមានវិធានការបន្ថែម បន្ថយចំណីឱ្យបានសមស្រប ។

## ២. ការថែទាំមេជ្រូកពរពោះ :

ក្រោយពេលដាក់ឈ្មោលរួចហើយ ត្រូវដេញមេផ្សេងៗបញ្ចូលទ្រុង មិន ត្រូវដាក់ជ្រូកច្រើន ចង្អៀតពេកទេ មិនត្រូវដេញទាត់ធាក់មេជ្រូកឱ្យរត់ព្រោះ អាចបណ្តាលឱ្យរលូតកូន ។

ត្រូវឱ្យមេជ្រូកធ្វើចលនារាល់ថ្ងៃ ល្អបំផុតបើធ្លានោះមានស្មៅខ្ចី ។ ធ្លាត្រូវរាបស្មើ ចៀសវាងកុំឱ្យមានគ្រលឹកគ្រលុក ដែលអាចបណ្តាលឱ្យជំពប់ជើងដួល និង រលូតកូន ។ ជិតដល់ពេលកើតកូន ត្រូវបន្ថយចលនាដើររបស់ជ្រូក ។ ធ្វើចលនាសមស្របផ្តល់សុខភាពដល់មេជ្រូកកូនក្នុងពោះរីកធំធាត់ល្អ បង្ការបានជំងឺពិបាកកើតកូន ។ មុនពេលឱ្យមេជ្រូកដើរចេញក្រៅធ្លា ត្រូវឱ្យផឹកទឹកស្អាតឱ្យបានគ្រប់គ្រាន់ ។ ត្រូវមុជទឹកឱ្យជ្រូករៀងរាល់ថ្ងៃ ( លើក លែងពេលមេឃត្រជាក់ ) ដើម្បីឱ្យខ្លួនវាត្រជាក់ស្អាត ចៀសវាងជំងឺនានា ដូចជាជំងឺសើស្បែក ជំងឺពេលកើតកូន ។ ការមុជទឹកជាប្រចាំឱ្យជ្រូក ផ្តល់សុខភាពឱ្យជ្រូក ព្រមទាំងជាលក្ខណៈឱ្យជ្រូកស៊ាំងងាយស្រួលក្នុងការថែទាំ និង ព្យាបាលពេលចាំបាច់ ។

ទ្រុងជានិច្ចកាលត្រូវស្អាតបាត មានខ្យល់អាកាសចេញចូល ។ អាចដាក់មេជ្រូកធើមក្រោមពីរខែនៅជាមួយគ្នាច្រើន បន្ទាប់មកថយបន្តិចម្តងៗ ។ លុះដល់ពេលជិតកើត ត្រូវមានទ្រុងមួយសំរាប់មេមួយ ។ ទ្រុងចង្អៀតអាចបណ្តាលឱ្យរលូតកូន ដោយសារជល្មើមគ្នាស៊ី ។ មិនត្រូវចាក់ថ្នាំការពារជំងឺប៉េស្តឱ្យមេជ្រូកធើមទេ ។

### ៣. ការថែទាំមេជ្រូក មុន និងក្រោយពេលកើតកូន :

កាលណាយើងចាំថ្ងៃដាក់ឈ្មោល នោះយើងនឹងដឹងពីថ្ងៃដែលវាកើតកូន ដើម្បីមានវិធានការរៀបចំជាមុន សំដៅឱ្យមេជ្រូកកើតកូនដោយសុវត្ថិភាព កូនជ្រូករស់ច្រើន មេជ្រូកសំបូរទឹកដោះចិញ្ចឹមកូន ។

## គ. កិច្ចការដែលត្រូវរៀបចំ :

### * ទ្រុង :

មុនពេលកើត ១០-១៥ ថ្ងៃគប្បីលាងសំអាតទ្រុងដោយទឹកកំបោរស រៀបចំកន្លែង និង អំពូលកំដៅឱ្យកូនជ្រូក ។ កន្លែងណាគ្មានភ្លើងអគ្គីសនី ត្រូវរៀបចំចង្ក្រានដុតធ្យូង ដុតអុស ។ ត្រៀមចំបើង អង្កាមទ្រាប់បាតទ្រុង ។ ទ្រុងត្រូវស្ងប់ស្ងាត់ ស្ងួត មានខ្យល់អាកាសចេញចូល និង មានពន្លឺគ្រប់គ្រាន់ ។

### * សំភារះផ្សេងៗ :

សៀវភៅសំរាប់កត់ត្រា ក្រណាត់ជូត កន្ត្រៃកាត់ធ្មេញ ប្រដាប់កាត់ត្រចៀក ចេសសំរាប់ចងផ្ចិត ថ្នាំលាងសំអាត ( ថ្នាំក្រហម ) ឡាំង ឬ ធុងកំដៅ ចំបើងស្ងួត ។

### * យកមេជ្រូកទៅកាន់ទ្រុងកើត :

៥-៧ ថ្ងៃ មុនពេលកើត ត្រូវនាំមេជ្រូកទៅកាន់ទ្រុងកើត ដើម្បីឱ្យវាមានទំលាប់នឹងកន្លែងថ្មីនេះ ។ មុនពេលនាំវាទៅកាន់ទ្រុងកើត ត្រូវលាងសំអាតខ្លួនវាឱ្យស្អាត ( ដោយសាប៊ូ ) ពិសេសលាងដោះ ដើម្បីសំលាប់មេរោគ ។

### * មួយអាទិត្យមុនពេលកើត :

ត្រូវបន្ថយចំណីពី 1/3 ដល់ 1/2 រួចបន្ថែមបន្លែស្រស់ ដើម្បីការពារជំងឺរលាកដោះ រលាកស្បូន និង ជំងឺអត់ទឹកដោះ ។

ធម្មតាមេជ្រូកច្រើនកើតកូននៅពេលយប់ ត្រូវតាមដានឱ្យបានជិតដល់ ដើម្បីមានវិធានការសង្គ្រោះទាន់ពេលវេលាគ្រាចំបាច់ ចៀសវាងការខាតបង់ដែលគួរឱ្យសោកស្តាយ ។

## ខ. មេជ្រូកកើតកូន :

លក្ខណៈមេជ្រូកជិតដល់ពេលកើតកូន :

- ដំណើរធ្ងន់
- ជួរដោះទាំងពីរធំក្រហម ជួនកាលមានចេញទឹកដោះ កាលណាយើងច្របាច់ ។
- ជ្រូកតប់ប្រមល់ ខាំកកេរជញ្ជាំង ដេក ដើរមិនស្ងៀម
- ខាំចំបើង ស្មៅ ក្នុងទ្រុង ឈ្មុលទៅកៀនជញ្ជាំង ( យើងហៅថាជ្រូកធ្វើសំបុក )
- ពេលមានជាតិរំអិលពណ៌លឿងចេញពីទ្វារ បញ្ជាក់ថាជ្រូកជិតកើតកូនហើយ ។

ពេលកើតមេជ្រូកច្រើនមិនសូវដេក ពិសេសមេជ្រូកក្មេង ច្រើនឈរ ដែលងាយនឹងជាន់កូន ។ ជាមធ្យមពី ១៥-២០ នាទី កើតកូនមួយ ប៉ុន្តែក៏អាចរហ័សជាងនេះ ឬ ក៏យូរជាងនេះរាប់ម៉ោងក៏មាន ។

កូនជ្រូកកើតមក ច្រើនធ្វើឱ្យរហែកស្រោមដោយខ្លួនវា រួចចេញមកក្រៅ ជួនក៏កើតមកទាំងស្រោម មានន័យថាកូនជ្រូកនៅក្នុងស្រោមនៅឡើយ ពេលនោះត្រូវរហ័សហែកស្រោមចេញ ចៀសវាងកូនជ្រូកថប់ដង្ហើម ។

មេជ្រូកដែលមានកូនច្រើន កូនតូច រួចទឹកខ្ទែងរបស់កូនផ្លាស់ប្តូរខ្លាំង ដូចនេះបាតុភូតដែលជ្រូកកើតក្បាលមុន ឬ កន្ទុយមុន សុទ្ធតែជាបាតុភូតធម្មតាទេ ។

ពេលកើត មេជ្រូកច្រើនដេក រហូតដល់កូនកើតអស់ មានមេខ្លះកើតកូនបានមួយស្ទុះងើបឈរម្តង ក៏មានជ្រូកខ្លះឈរកើតកូន ដើរចុះដើរឡើង ត្រូវប្រុងប្រយ័ត្នក្រែងមេដើរជាន់ ឬ ទាត់កូន ។

សុកអាចនឹងធ្លាក់មកជាមួយកូន ជួនកើតកូនអស់ទើបធ្លាក់សុក ។ ត្រូវយកសុកចេញ ចៀសវាងកុំឱ្យស្អុយរលួយ ឬ ក៏ឱ្យមេជ្រូកស៊ី ( សុកទុកយូរស្អុយរលួយមានមេរោគ ) ឬ ក៏អាចបណ្តាលឱ្យមេជ្រូកមានទំលាប់អាក្រក់ស៊ីសាច់ឆៅ ដែលអាចស៊ីទាំងកូនវាផង ។

បើការកើតកូនមានរយៈពេលយូរពេក ត្រូវប្រើវិធានការដូចតទៅនេះ :-

- យកកូនដែលកើតរួចហើយ ឱ្យបៅដោះមេវា
- ចាក់ Ocytocin

បើវិធានការទាំងពីរនេះមិនបានលទ្ធផលល្អទេ ត្រូវអញ្ជើញភ្នាក់ងារបសុពេទ្យជួយសង្គ្រោះ ។

## គ_ជួយបង្កើតកូន និងថែទាំកូនជ្រូកដែលទើបនឹងកើត :

អ្នកជួយបង្កើតកូនជ្រូក ត្រូវកាត់ក្រចកដៃឱ្យខ្លី លាងសំអាតដៃដោយអាល់កុល ។ កូនជ្រូកទើបកើតមក ប្រឡាក់ទឹករំអិលពេញខ្លួន យើងត្រូវចាប់កូនជ្រូកថ្នមៗ ដៃមួយកាន់ទទឹងខ្លួនវា ដៃមួយទៀតជូតស្រោមស្តើងជុំវិញក្បាល ច្រមុះ និង ខ្លួន ។ យកកន្សែងស្អាតជូតទឹកនៅច្រមុះ មាត់មុនដើម្បីកុំឱ្យវាថប់ដង្ហើម រួចហើយសឹមជូតខ្លួនវាឱ្យស្ងួត ។

ទងផ្ចិតធម្មតាច្រើនដាច់ដោយខ្លួនឯង ជួនក៏ជាប់នឹងសុកនៅក្នុងពោះ បើមានបញ្ហាដូចនេះ ត្រូវទាញផ្តាច់ដោយថ្នមៗ ។

ត្រូវកាន់កូនជ្រូកថ្នមៗ កុំឱ្យវាស្រែក នាំឱ្យផ្អើលដល់មេវា ដែលជាកត្តាបន្ទាយរយៈពេលកើតកូន ។ ចំពោះមេជ្រូកកើតកូនឈរ ត្រូវស្ទាបអង្អែលដោះវា ដើម្បីឱ្យវាដេកចុះ ។

ជូតកូនជ្រូកស្អាតបាតហើយ កាត់ទងផ្ចិត កាត់ធ្មេញ ចង្កឹង រួច កាត់ស្លឹកត្រចៀក ចុះលេខចំណាំ ( បើជាការចាំបាច់ ) ។ យកចេស ចងផ្ចិតចម្ងាយពីពោះ ៣-៥ សម រួចយកកាំបិត ឬ កន្ត្រៃដែលស្ងោររួច ហើយកាត់ រួចលាបថ្នាំក្រហម ។

ដាក់កូនជ្រូកក្នុងទ្រុង ( ធុង ) កំដៅ បើមានអគ្គិសនីប្រើអំពូល ភ្លើង បើគ្មានប្រើចង្កៀង ។ បាតទ្រុង ( ធុង ) ត្រូវទ្រាប់ចំបើង ឬ បាវ ក្រចៅ ដើម្បីរក្សាកំដៅ ។

ក្នុងលក្ខណៈដែលមេជ្រូកកើតកូនរហ័ស ជាប់ៗគ្នា ត្រូវជូតសំអាត កូនជ្រូកឱ្យស្ងួត រួចដាក់ក្នុងធុងកំដៅជាមុនសិន សឹមកាត់ផ្ចិត និង ធ្វើកិច្ចការដទៃទៀតជាក្រោយ ។

ត្រូវជួយសង្គ្រោះកូនជ្រូកថប់ដង្ហើម ដោយមធ្យោបាយដូចតទៅ នេះ :

- បិទមាត់កូនជ្រូក រួចបឺតរន្ធច្រមុះឱ្យខ្លាំង ព្រោះការស្ទះដង្ហើម នេះ អាចបណ្ដាលមកពីជាតិរំអិល ។

- យួរជើងក្រោយទាំងពីរបញ្ច្រាសគ្នា ដៃមួយសង្កត់ស្រាលទៅលើ ភ្លៅ ឬ លើពោះ ដើម្បីជំរុញការដកដង្ហើម ។

- ដកដង្ហើមសិប្បនិម្មិត : ដាក់កូនជ្រូកដេកលើចំបើង ឬ បាវក្រចៅរុញជើងមុខទាំងពីរចុះឡើងស្រាលៗ រួចប្រើចុងដៃសង្កត់លើឆ្អឹង ជំនីទាំងពីរតាមចង្វាក់ដង្ហើម ។

- ជ្រលក់កូនជ្រូកក្នុងទឹកក្ដៅពី ២០-៣៨° អង្សា ។

ក្រោយពេលកើតប្រហែលមួយម៉ោង ត្រូវឱ្យកូនជ្រូកបៅ ប៉ុន្តែមុន ពេលឱ្យបៅ ត្រូវជូតសំអាតដូរដោះទាំងពីរ ជូតសំអាតជាតិរំអិលនៅលើដោះ ខ្លួន និង គូថមេជ្រូក ។

ត្រូវរាប់ចំនួនសុក តើធ្លាក់អស់ឬនៅ ? មើលសុខភាពវា មើលកំដៅខ្លួន និង ការស៊ីផឹក ពិនិត្យមើលដោះ និង របៀបឱ្យកូនបៅ ក្រែងវាមានជំងឺរលាកដោះ អត់ទឹកដោះ ដើម្បីមានវិធានការជួយសង្គ្រោះជាបន្ទាន់ ។

## C - របៀបចិញ្ចឹមមេជ្រូកបំបៅកូន :

ភារកិច្ចជាសំខាន់របស់មេជ្រូក គឺផលិតទឹកដោះឱ្យបានច្រើន និង មានគុណភាពខ្ពស់ ដើម្បីចិញ្ចឹមកូនឆាប់ធំធាត់ មានសុខភាពល្អ ហើយមិនសូវមានកូនងាប់ ។

### ១. ការឱ្យទឹកដោះរបស់មេជ្រូក :

ធម្មតាក្នុងមួយម៉ោងមេជ្រូកបញ្ចេញទឹកដោះម្តង ។ ពេលទឹកដោះចេញមេជ្រូកតែងស្រែកហៅកូន ( អ៊ុកៗ ) ឮសំរែកនេះ កូនជ្រូកស្ទុះរកបៅ ។ រយៈពេលបញ្ចេញទឹកដោះម្តងៗ មានត្រឹមប៉ុន្មានទនាទីតែប៉ុណ្ណោះ ។ ក្នុងពេលកំពុងឱ្យកូនបៅ បើមានសំលេងអ៊ូអរខ្លាំង នាំឱ្យភ្ញាក់ផ្អើល ទឹកដោះនឹងឈប់ចេញភ្លាម ។

#### * កត្តាដែលមានឥទ្ធិពលដល់ការបញ្ចេញទឹកដោះ :

##### - សារជាតិ

ចំណីអាហារមានឥទ្ធិពលផ្ទាល់ដល់បរិមាណ និង គុណភាពទឹកដោះ ព្រោះថាដើម្បីឱ្យកើតជាទឹកដោះ ជ្រូកត្រូវបឺតយកជាតិនានាពីក្នុងចំណី ។ ហេតុនេះចំពោះចំណីអាហារ ត្រូវធានាទាំងបរិមាណ ទាំងគុណភាព ឱ្យសមស្របនឹងសេចក្តីត្រូវការរបស់មេជ្រូកបំបៅកូន ។

សារជាតិដែលខ្លួនជ្រូកស្តុកទុកក្នុងពេលធើម ក៏មានឥទ្ធិពលដល់បរិមាណទឹកដោះ ។ ដូចនេះត្រូវផ្តល់ចំណីអាហារមានសារជាតិគ្រប់គ្រាន់ឱ្យមេជ្រូកធើម ព្រោះថាពេលមេជ្រូកធើម បើយើងពុំបានយកចិត្តទុកដាក់ចិញ្ចឹមវាឱ្យបានសមស្របទេ នោះនឹងមានមហន្តរាយដល់ការផលិតរបស់មេជ្រូកដូចជា : កូនជ្រូកកើតឡើងទំងន់ស្រាល មេមានទឹកដោះ តិច ។ ល ។

**ការថែទាំ :**

គ្រប់មូលហេតុដែលធ្វើឱ្យកំរើកដល់សរសៃប្រសាទ សុទ្ធតែមានឥទ្ធិពលមិនល្អដល់ចំនួនទឹកដោះ ។ មូលហេតុទាំងនោះមានសំលេងអ៊ូអរ ឬ ក៏ ទាត់ធាក់ជ្រូក ធ្វើឱ្យជ្រូកភ័យខ្លាច ឈឺចាប់ ។

អាកាសធាតុក្ដៅ និង កង្វះចលនារបស់មេជ្រូក សុទ្ធតែបណ្ដាលឱ្យទឹកដោះមិនចេញ ។ គប្បីឱ្យជ្រូកធ្វើចលនាដើរចុះឡើង និង មុជទឹកឱ្យវា ។

- **អាយុ :**

មេជ្រូកកើតកូនលើកដំបូង ឱ្យទឹកដោះតិចជាងមេជ្រូកដែលកើតកូនច្រើនលើកហើយ ។ បរិមាណទឹកដោះកើនឡើងជាបន្តបន្ទាប់ពីកូនលើកទី ១ ដល់កូនលើកទី ៥ រួចបន្ទាប់មកក៏ចុះថយបន្តិចម្ដងៗ ។

បរិមាណទឹកដោះក្នុងអាទិត្យនិមួយៗមិនដូចគ្នាទេ ក្នុងបីអាទិត្យដំបូង ទឹកដោះច្រើន រួចបន្ទាប់មកចុះថយតិចទៅៗ ។

- **ពូជ :**

ពូជផ្សេងគ្នា លទ្ធភាពឱ្យទឹកដោះក៏ផ្សេងគ្នា ពូជ Yorkshire, Landrace ឱ្យទឹកដោះច្រើន ។

- **អាកាសធាតុ :**

អាកាសធាតុត្រជាក់ល្មើយ ទ្រុងមានខ្យល់អាកាសចេញចូលបរិបូណ៌ មេជ្រូកឱ្យទឹកដោះច្រើន ។

ក្រៅពីនេះដោះនិមួយៗ ក៏ឱ្យទឹកដោះមិនដូចគ្នាដែរ ។ ដោះខាងមុខឱ្យទឹកដោះច្រើនជាងដោះខាងក្រោយ ។ ត្រូវកំណត់ដោះឱ្យកូនជ្រូក បៅដើម្បីឱ្យកូនជ្រូកធំធាត់ស្មើគ្នា ។

## ២. ការចិញ្ចឹមមេជ្រូកបំបៅកូន :

### a)- សេចក្តីត្រូវការសារជាតិ :

#### - ជាតិសាច់ :

ក្នុងមួយថ្ងៃមេជ្រូកបញ្ចេញទឹកដោះ ៥-៦ គក្រ ជាតិសាច់ក្នុងទឹកដោះមានពី ៥,៥-៦ % ដូចនេះរាល់ថ្ងៃមេជ្រូកត្រូវការជាតិសាច់មួយចំនួនដើម្បីបង្កើតទឹកដោះ ។ បើឱ្យជាតិសាច់មិនគ្រប់គ្រាន់ទេ បរិមាណទឹកដោះនឹងចុះយ៉ាងរហ័ស រួចគុណភាពក៏អន់ មេជ្រូកបាក់កំលាំង ចុះស្គម កូនជ្រូកខ្វះទឹកដោះ ក្រធំ ងាយកើតជំងឺផ្សេងៗ ។

ម្សៅត្រីជាចំណីដ៏ល្អបំផុតសំរាប់មេជ្រូកចិញ្ចឹមកូន ។ ចំណីសំរាប់មេជ្រូកចិញ្ចឹមកូន ត្រូវមានជាតិសាច់ ១៥ % ។

#### - ជាតិរ៉ែ :

ត្រូវយកចិត្តទុកដាក់ចំពោះជាតិរ៉ែពីរមុខ គឺ Ca និង P ។ ក្នុងទឹកដោះមេជ្រូកសំបូរជាតិកាល់ស្យូមជាបង្គួរ ។ បើក្នុងចំណីខ្វះជាតិកាល់ស្យូមក្នុងរយៈពេលយូរ មេជ្រូកនឹងយកជាតិកាល់ស្យូមពីក្នុងខ្លួនវា ដើម្បីបង្កើតទឹកដោះ ។ ដូចនេះអាចបណ្តាលឱ្យមេជ្រូកចុះស្គម ពិបាកដើរស្ពឹកជើង បរិមាណទឹកដោះថយចុះ ។ មេជ្រូកខ្វះទឹកដោះ ក៏អាចបណ្តាលមកពីចំណី ខ្វះជាតិកាល់ស្យូម ។ ដូចនេះត្រូវផ្តល់ជាតិ Ca និង P ឱ្យមេជ្រូកឱ្យបានគ្រប់គ្រាន់ ហើយរាល់ថ្ងៃត្រូវឱ្យមេជ្រូកធ្វើចលនា ( ដើរ ) ក្រោមកំដៅថ្ងៃ ដើម្បីជំរុញការប្រើប្រាស់ជាតិទាំងពីរនេះឱ្យបានល្អ ។

#### - វីតាមីន :

វីតាមីនជាសារធាតុសរីរាង្គសំរាប់ធានាសុខភាពរបស់ជ្រូក និងសំរាប់បង្កើតទឹកដោះ ។ ពិសេសបំផុតគឺវីតាមីន A ត្រូវឱ្យមានគ្រប់គ្រាន់

ក្នុងចំណី កូនជ្រូកទើបនឹងកើតបានទទួលវីតាមីន A តាមរយៈទឹកដោះមេ ។ បើក្នុងទឹកដោះខ្វះ វីតាមីន A កូនជ្រូកក្រធំ ងាយកើតជំងឺ ។

· វីតាមីន $B_{12}$ ចាំបាច់ក្នុងការបង្កើតឈាមរបស់កូនជ្រូក ។ វីតាមីន $B_{12}$ មានសំបូរនៅក្នុងម្សៅសាច់ ម្សៅត្រី ។

**b)- ចំណីសំរាប់មេជ្រូកបំបៅកូន :**

- បរិមាណចំណីសំរាប់មេជ្រូកបំបៅកូន ប្រែប្រួលទៅតាមទំងន់អាយុ និង បរិមាណទឹកដោះតិច ឬ ច្រើន ( គឺថាកូនតិច ឬ ច្រើន ) បរិមាណចំណីសំរាប់មេជ្រូកបំបៅកូន ជាមធ្យមប្រហែល ៥-៦គក្រ ក្នុងមួយថ្ងៃ ប៉ុន្តែដើម្បីជាការងាយគិត គឺយើងឱ្យវាស៊ីស្មើនឹង ៣ % នៃទំងន់របស់វា (មេជ្រូកស្ទាវឱ្យ ៣,២ % មេចំណាស់ ២,៨០ % ) ។

- ចំណីសំរាប់មេជ្រូកមិនត្រូវផុះផ្សិត ព្រោះអាចមានឥទ្ធិពលអាក្រក់ដល់ទឹកដោះ និង ងាយបណ្តាលឱ្យកូនជ្រូកកើតជំងឺនៅផ្លូវរំលាយអាហារ ។

- ត្រូវឱ្យចំណីណាដែលមានគុណភាពល្អ ហើយឱ្យបានច្រើនមុខ។
- ត្រូវឱ្យស៊ីបន្លែស្រស់បន្ថែម ។

ចំណីមានជីវជាតិល្អ កូនជ្រូកឆាប់ធំ រោមស្បែកភ្លឺរលោង ។

**c)- របៀបឱ្យស៊ី :**

ក្រោយពេលកើតកូនអស់ភ្លាម គប្បីឱ្យមេជ្រូកផឹកទឹកក្តៅឧណ្ហៗលាយជាមួយកន្ទក់រាវ ។ ក្នុងការបង្កើតកូន មេជ្រូកបាត់បង់កំលាំងច្រើនណាស់ ដូចនេះត្រូវឱ្យចំណីដែលថ្មី ឆ្ងាញ់ ព្រមទាំងងាយស្រួលរំលាយ។ ក្នុងប៉ុន្មានថ្ងៃដំបូង ត្រូវឱ្យចំណីរាវៗ ហើយបរិមាណត្រូវបន្ថែមបន្តិចម្តងៗ

លុះដល់ថ្ងៃទី ៤-៥ ទើបឱ្យតាមសេចក្ដីត្រូវការរបស់វា ។ ក្រោយពេលកើតកូន បើឱ្យស៊ីចំណីច្រើនភ្លាម អាចមានវិបល្លាសក្នុងការរំលាយអាហារទឹកដោះចុះ ។

ត្រូវឱ្យស៊ីឱ្យបានត្រឹមត្រូវតាមពេលវេលា មិនត្រូវទុកឱ្យវាឃ្លាន ដែលបណ្ដាលឱ្យវានៅមិនស្ងៀម និង មានឥទ្ធិពលដល់បរិមាណទឹកដោះ។

ត្រូវឱ្យផឹកទឹកឱ្យបានគ្រប់គ្រាន់ ព្រោះក្នុងទឹកដោះឱ្យកូនបៅ មានជាតិទឹកច្រើន ។

## ២. ការថែរក្សាមេជ្រូកបំបៅកូន :

ចលនា (ដើរ) ចុះឡើងក្រោមកំដៅថ្ងៃ បង្កើនលក្ខណៈល្អដល់មេជ្រូក បង្កើតទឹកដោះបានច្រើន ព្រមទាំងលើកស្ទួយសុខភាពរបស់មេជ្រូក។ ក្រោយពេលបង្កើតកូនបាន ៤-៥ ថ្ងៃ បើមេឃស្រឡះល្អ គប្បីឱ្យមេជ្រូកចេញក្រៅធ្លានៅពេលព្រឹក ហើយថ្ងៃបន្ទាប់ៗមក អាចបន្ថែមម៉ោងឱ្យចេញក្រៅ ។

- ទ្រុងត្រូវស្អាត ស្ងួត មានខ្យល់អាកាសចេញចូល និង ស្ងប់ស្ងាត់ ។ ទ្រុងក្ដៅស្អុះ ឬ អ៊ូអរ សុទ្ធតែធ្វើឱ្យថយទឹកដោះ និង ងាយបណ្ដាលឱ្យមេជាន់កូន ។

- ទ្រុងសើមផ្អើចផ្អាច់ ងាយឱ្យកូនជ្រូកកើតជំងឺផ្សេងៗ ។

- ត្រូវកំណត់ដោះឱ្យកូនបៅ ហើយត្រូវឱ្យកូនបៅឱ្យគ្រប់ដោះ ការពារកុំឱ្យមានជំងឺរលាកដោះ ។

- ការមុជទឹកឱ្យជ្រូក ជាការសំខាន់ណាស់ ព្រោះអាចបង្កើនសុខភាព បន្ថយជំងឺរលាកដោះ ។ ប៉ុន្តែត្រូវរង់ចាំពីរអាទិត្យក្រោយកើតកូនសឹមមុជទឹកឱ្យវា ដើម្បីចៀសវាងជំងឺផ្សេងៗ ។

ក្នុងប៉ុន្មានថ្ងៃក្រោយពេលកើតកូន ត្រូវប្រយ័ត្នតាមដានកំដៅខ្លួន ការស៊ីចុក និង ពិនិត្យប្រដាប់បន្តពូជរបស់មេជ្រូក ដើម្បីមានវិធានការព្យាបាលបានទាន់ពេលវេលា បើឃើញថាមានជំងឺ ។



# V- របៀបចិញ្ចឹមកូនជ្រូកបៅដោះ

រយៈកាលនេះចាប់ផ្តើមពីពេលកើតដល់ពេលផ្តាច់ដោះ ។ នេះជារយៈកាលដែលត្រូវយកចិត្តទុកដាក់ថែទាំឱ្យបានហ្មត់ចត់ ព្រោះថារយៈកាលនេះកូនជ្រូកងាយនឹងកើតជំងឺណាស់ ។

ត្រូវធ្វើយ៉ាងណាឱ្យកូនជ្រូករស់ច្រើន ងាប់តិច ពេលផ្តាច់ដោះមានទំងន់ធ្ងន់ កូនធំស្មើ ។

ដើម្បីទទួលបានលទ្ធផលល្អ ដំបូងបង្អស់គឺត្រូវស្គាល់ពីលក្ខណៈរបស់កូនជ្រូកបៅដោះ ដើម្បីមានវិធានការបច្ចេកទេសសមស្រប ។

## A - ចំណុចពិសេសរបស់កូនជ្រូកបៅដោះ :

### ក- រហ័សធំ :

គប្បីយល់ថាកូនជ្រូកបៅដោះរហ័សធំណាស់ បើយើងតាមដានឱ្យបានច្បាស់នោះនឹងឃើញថា :

- ទំងន់កូនជ្រូកក្នុងអាយុ១០ថ្ងៃ ធ្ងន់ជាងកូនជ្រូកទើបកើត ២ដង
- - ៣០ថ្ងៃ - ៤-៥ ដង
- - ៦០ថ្ងៃ - ១០ ដង

កូនជ្រូករហ័សធំ ទាមទារចំណីមានជីវជាតិច្រើន ។ បើមិនដូច្នោះទេនោះ នឹងនាំឱ្យមានការខាតបង់ច្រើនណាស់ ។

## ខ. ប្រដាប់រំលាយអាហាររបស់កូនជ្រូក រីកដុះដាលរហ័ស ប៉ុន្តែការរំលាយអាហារខ្សោយ :

កូនជ្រូកដែលទើបកើត រស់អាស្រ័យទឹកដោះមេ ។ ពេលផ្ដាច់ដោះកូនជ្រូកត្រូវរស់ដោយខ្លួនឯង និង យកជីវជាតិពីចំណីអាហារ ដូចនេះប្រដាប់រំលាយអាហាររបស់វា ត្រូវឆ្លងតំណាក់កាលនៃការប្រែប្រួល ដើម្បីសំរបទៅនឹងលក្ខណៈរស់នៅថ្មី ។

ប្រដាប់រំលាយអាហាររបស់កូនជ្រូក ដំបូងឡើយនៅតូច អង្គជាតិ (Diastase ) រំលាយអាហារមិនទាន់មានគ្រប់គ្រាន់ ។ ក្នុងអាទិត្យដំបូងក្រពះរបស់វាខ្វះជាតិជូរ ( Acide chlorydrique ) ដូចនេះងាយនឹងមានជំងឺក្រពះណាស់ ។ លទ្ធភាពរំលាយជាតិស្ករក្នុងរយៈកាលដំបូងនៅខ្សោយ ។ លទ្ធភាពរំលាយជាតិសាច់មានដើមកំណើតពីសត្វខ្ពស់ជាងជាតិសាច់ពីរុក្ខជាតិ ។ កូនជ្រូក មានលទ្ធភាពស្រូប និង រំលាយជាតិខ្លាញ់ ( Acide gras ) ខ្ពស់ បានជាកូនជ្រូកអាចប្រើប្រាស់ជាតិខ្លាញ់ក្នុងទឹកដោះបានយ៉ាងស្រួល ។

ប្រដាប់រំលាយអាហាររបស់កូនជ្រូក រីកដុះដាលរហ័សណាស់ ប៉ុន្តែលទ្ធភាពរំលាយអាហារ និង លទ្ធភាព ប្រឆាំងជំងឺខ្សោយ ។ ដូច្នេះត្រូវយកចិត្តទុកដាក់ចំពោះចំណុចមួយចំនួនដូចតទៅនេះ :

- ត្រូវឱ្យចំណីស្រួលរំលាយ និង ឱ្យសមស្របចំពោះលទ្ធភាពនៃការរំលាយរបស់វា ។
- ត្រូវកែច្នៃចំណីឱ្យបានល្អដើម្បីជួយសំរួលដល់ការរំលាយអាហារ
- ត្រូវរក្សាអនាម័យចំណី ទឹក ទ្រុង ដើម្បីការពារកុំឱ្យមាន ជំងឺផ្លូវពោះវៀន និង ជំងឺដទៃទៀត ។
- ត្រូវឱ្យស៊ីច្រើនពេលក្នុងមួយថ្ងៃ ។

- ត្រូវបង្ហាត់ឱ្យកូនជ្រូករហ័សចេះស៊ីចំណី ដើម្បីជំរុញការរីកដុះដាលប្រដាប់រំលាយអាហារ និង អង្គជាតិរំលាយអាហារ ។

**គ- ការធន់ទ្រាំនឹងធាតុត្រជាក់នៅខ្សោយ :**

ប្រពន្ធ័សរសៃប្រសាទ និង វិញ្ញាណដទៃទៀត ស្ថិតក្នុងកំរិតដុះដាលទាប បានជាកូនជ្រូកងាយទទួលឥទ្ធិពលផ្ទាល់ពីបរិយាកាសខាងក្រៅ ដូចជា ធាតុត្រជាក់ ធាតុក្តៅ ធាតុសើម ។ ល ។

ម្យ៉ាងទៀតមកពីស្រទាប់ខ្លាញ់នៅក្រោមស្បែករបស់វាស្តើង បានជាលទ្ធភាពប្រឆាំងជាតិត្រជាក់របស់វាខ្សោយ ។ ហេតុនេះត្រូវតែមានទ្រុងកំដៅឱ្យវា ។

ទ្រុងត្រូវស្ងួត មានខ្យល់អាកាសចេញចូល ប៉ុន្តែមិនត្រូវឱ្យខ្យល់ខ្លាំង ឬ ភ្លៀងសាចចូល ។ ត្រូវឱ្យកូនជ្រូកស៊ីចំណីដែលមានជីវជាតិគ្រប់គ្រាន់ ដើម្បីមានលទ្ធភាពទប់ទល់នឹងជំងឺ ។

**B - បច្ចេកទេសចិញ្ចឹមកូនជ្រូកនៅដោះ :**

ថិតក្នុងរយៈពេលកំពុងនៅបៅដោះ អត្រាងាប់របស់កូនជ្រូកមានកំរិតខ្ពស់ មកពីជំងឺរលាកស្ងួត រាគរអាចម៍ ឬ ក៏មកពីមេដេកកិន ។ ដើម្បីការពារកុំឱ្យកូនជ្រូកងាប់ច្រើន និង មានសុខភាពល្អ ត្រូវអនុវត្តតាមបែបបទបច្ចេកទេសដូចតទៅនេះ : -

### ១- ត្រូវឱ្យកូនជ្រូកបានបៅដោះដំបូង ហើយកំណត់ដោះឱ្យកូនជ្រូកបៅ :

ទឹកដោះរបស់មេជ្រូកដែលទើបបង្កើតកូនបាន ២-៣ ថ្ងៃ គេហៅថាទឹកដោះខ្ចី ឬ ទឹកដោះដំបូង ។ ទឹកដោះនេះមានជីវជាតិជាងទឹកដោះធម្មតា ឬ ក៏មានជាតិខ្លះដែលទឹកដោះធម្មតាគ្មាន ។ ទឹកដោះដំបូងមានអង្គប្រយុទ្ធ Anticorps ( ɤ globuline ) ដែលជួយឱ្យកូនជ្រូកអាចប្រឆាំងនឹងមេរោគបាន ។ ត្រូវធ្វើយ៉ាងណាឱ្យកូនជ្រូកទាំងអស់បានបៅទឹកដោះដំបូង ដើម្បីទទួលបាននូវជីវជាតិចាំបាច់ ដែលមិនអាចយកចំណីណាមកជំនួសបាននេះ ។ ទឹកដោះដំបូង ផ្តល់កំដៅដល់កូនជ្រូកប្រឆាំងនឹងធាតុត្រជាក់ ។ ធ្វើយ៉ាងណាឱ្យកូនជ្រូកបៅ ទឹកដោះដំបូងកាន់តែរហ័សកាន់តែប្រសើរ ។ ក្រោយពេលកើតកន្លះម៉ោង ទៅមួយម៉ោង ត្រូវឱ្យវាបៅបើទុកយូរក្រឱ្យបៅ នឹងបណ្តាលឱ្យកូនជ្រូកខ្សោយ ងាយទទួលធាតុត្រជាក់និង ងាយកើតជំងឺណាស់ ។

-ជាមួយនេះដែរ ត្រូវកំណត់ឱ្យកូនជ្រូកបៅដោះមួយណា បៅដោះនោះរហូតដល់ថ្ងៃផ្តាច់ដោះ ។

ក្នុងពេលបៅជាលើកដំបូង កូនជ្រូកច្រើនប្រជែងគ្នាដណ្តើមដោះ។ កូនធំមានសុខភាពល្អ ច្រើនដណ្តើមបានដោះដែលមានទឹកដោះច្រើន ឬ ក៏ដោះខាងមុខ ។ ដើម្បីឱ្យកូនជ្រូកធំស្មើគ្នា ត្រូវឱ្យកូនណាខ្សោយ បៅដោះខាងមុខ កូនធំ ខ្លាំង បៅដោះខាងក្រោយ ទំលាប់វាយ៉ាង នេះតែ ២-៣ ថ្ងៃ វានឹងធ្លាប់ ( កូនណាដោះនោះ ) ។

ចំពោះមេជ្រូកដែលកូនជាលើកដំបូង ត្រូវឱ្យវាមានទំលាប់ដេកត្រង់ខ្លួន ដើម្បីឱ្យជួរដោះខាងក្រោមលេចចេញមកក្រៅ ស្រួលឱ្យកូនបៅ ។

## ២. ត្រូវបន្ថែមជីវជាតិដល់កូនជ្រូក :

ក្រៅពីបៅទឹកដោះ កូនជ្រូកនៅត្រូវការជីវជាតិបន្ថែមទៀត ព្រោះ:

- បរិមាណទឹកដោះថយចុះចាប់ពីអាទិត្យទី ៣ ផ្ទុយទៅវិញកូនជ្រូកកាន់តែត្រូវការជីវជាតិច្រើនឡើង ដើម្បីឱ្យខ្លួនវាធំធាត់ ។
- បន្ថែមជាតិមួយចំនួន ដែលក្នុងទឹកដោះមានមិនគ្រប់គ្រាន់ ពិសេសគឺជាតិដែក បើមិនថែមជាតិដែកទេ កូនជ្រូកនឹងមានជំងឺខ្វះឈាម ។

ក្រោយពេលកើតបានមួយអាទិត្យ កូនជ្រូកចាប់ផ្តើមដុះធ្មេញ ។ វាចូលចិត្តខាំរបស់រឹងៗ ដូចជាស្នូកចំណី ជញ្ជាំង ឬ កំរាលទ្រុង ។ល ។ ប៉ុន្តែបើមានចំណី វានឹងបន្ថយការដើរខាំរបស់ដែលមិនស្អាតដែលមាននៅក្នុងទ្រុង ដូចនេះក៏អាចបន្ថយការចំលងមេរោគផ្សេងៗ ។

### ក. បន្ថែមជាតិដែក :

បន្ថែមជាតិដែកឱ្យកូនជ្រូក តាមរបៀបដូចខាងក្រោមនេះ :-

- បើមានថ្នាំដែលមានជាតិដែកដូចជា Ferdextran ឬ Ferrodex ចាក់ឱ្យកូនជ្រូក ១ cc ចាក់នៅថ្ងៃទី ៣ និង ទី ១០ ។
- ឱ្យផឹកស៊ីរ៉ូដែក ។ តែបើគ្មានយើងអាចលាយ 2,5 g Sulfate de fer + 1 g Sulfate de cuivre ក្នុងទឹកមួយលីត្រ ។ ក្នុងអាទិត្យទី ១ ឱ្យកូនជ្រូកផឹកក្នុងមួយថ្ងៃ ១ cc និង នៅអាទិត្យទី ២ គឺឱ្យ ២ cc ក្នុងកូនជ្រូកមួយ ។

ក្នុងលក្ខណៈដែលគ្មានថ្នាំទាំងពីរប្រភេទខាងលើនេះ យើងអាចយកដីឥដ្ឋពណ៌ក្រហម លឿង ហាលឱ្យស្ងួត បោះចូលក្នុងទ្រុងឱ្យវាកកេរក៏អាចជំនួសបានដែរ ( ជីកដីកន្លែងស្អាតជំរៅយ៉ាងតិចមួយម៉ែត្រ ) ។

បើមានធ្លាស្អាតបាត អាចលែងឱ្យកូនជ្រូកដើរ នោះក៏អាចបង្កលក្ខណៈឱ្យកូនជ្រូកអាចរកបានជាតិរ៉ែនេះដែរ ។

## ខ. បន្ថែមជីវជាតិផ្សេងៗទៀត :

ចំណីសំរាប់កូនជ្រូកត្រូវមានជាតិសាច់ពី ១៨-២០ % ស្រួលរំលាយ ហើយមានជាតិសែលុយឡូសតិច ។ ក្នុងអាយុ ១០ ថ្ងៃ បង្ហាត់វាឱ្យចេះស៊ីចំណីខាប់ៗ ។ នៅថ្ងៃដំបូងយកចំណីទៅលាបដោះមេ ដើម្បីឱ្យកូនបៅ ឬ ក៏ដាក់បញ្ចូលទៅក្នុងមាត់របស់វា ក្នុងរវាង ២-៣ ថ្ងៃ កូនជ្រូកនឹងមានទម្លាប់បន្តិចម្តងៗ ដើរទៅរកស៊ីដោយខ្លួនឯង ។ ចាប់ពីថ្ងៃទី២០ ឡើងទៅ កូនជ្រូកអាចស៊ីចំណីលាយស្ងួត ឬ ក៏ផឹ្សមទឹកតិចៗ និងស៊ីបន្លែស្រស់ ។

បើចង់ផ្លាស់ប្តូរមុខចំណី ត្រូវផ្លាស់ប្តូរបន្តិចម្តងៗ ដើម្បីឱ្យប្រដាប់រំលាយអាហាររបស់វាទម្លាប់នឹងចំណីថ្មី ដើម្បីចៀសវាងនូវបាតុភូតផ្សេងៗ និង ការពារកុំឱ្យរាគរូស ។ ស្នូកចំណី ស្នូកទឹកត្រូវតែស្អាត ស្ងួត មិនត្រូវទុកចំណីសល់ក្នុងស្នូកយូរថ្ងៃ ឱ្យជូរផ្អូមនោះទេ ។

## គ. គប្បីបង្ហាត់កូនជ្រូកឱ្យឆាប់ចេះស៊ីតាមពេលវេលាដូចតទៅនេះ

ថ្ងៃទី ៣ : ថែមជាតិដែក

ថ្ងៃទី ៥-១០ : គ្រាប់ពោតលីង ( កិនឱ្យហ្មត់ )

ថ្ងៃទី១០-១៥ : ចំណីលាយចំរុះមានគុណភាពល្អ

ថ្ងៃទី២០ ឡើងទៅ : ចំណីលាយចំរុះ និង បន្លែស្រស់

ការពិតជាក់ស្តែងបានបង្ហាញឱ្យឃើញថា ការបន្ថែមចំណីឱ្យកូនជ្រូក ក៏ដូចជាពេលវេលាចាប់ផ្តើមបន្ថែមចំណី មានឥទ្ធិពលច្បាស់លាស់ក្នុងការធ្វើឱ្យកូនជ្រូកមានទំងន់ធ្ងន់ពេលផ្តាច់ដោះ ។

នៅតំបន់ខ្លះ គេទម្លាប់បង្ហាត់ឱ្យកូនជ្រូករហ័សចេះស៊ីចំណី (១២-១៥ ថ្ងៃ ) ជាលទ្ធផលកូនជ្រូករហ័សចេះស៊ីចំណី ឆាប់ធំ ហើយអាចផ្តាច់ដោះបានក្នុងអាយុ ១ ខែ ។ ចំណីសំរាប់បន្ថែមឱ្យកូនជ្រូក ត្រូវមានជាតិសាច់ ២០ % ។ ចំណីសំរាប់បង្ហាត់ឱ្យវាចេះស៊ី ត្រូវតែថ្មី ឆ្ងាញ់ មានសែលុយឡូសតិច ស្រួលរំលាយ ។ ត្រូវមានទ្រុងពិសេសឱ្យកូនជ្រូកអាចចេញចូលស៊ីចំណីបានដោយសេរី ។

### ឃ- ឱ្យកូនជ្រូកធ្វើចលនា (ដើរ) ក្រោមកំដៅថ្ងៃ :

ទ្រុងសំរាប់មេជ្រូកត្រូវមានធ្លាឱ្យកូនជ្រូកចេញចូលហាលថ្ងៃ ។ ចាប់ពីអាយុ ២ អាទិត្យឡើងទៅ ពេលដែលកូនជ្រូកមានកំលាំងខ្លាំងក្លា និង រហ័សរហួនហើយ អាចលែងក្នុងធ្លាមួយថ្ងៃម្តង នៅពេលព្រឹក ។

*** ផលប្រយោជន៍ក្នុងការលែងកូនជ្រូកក្នុងធ្លា :**

- អាចផ្តល់វីតាមីន D គ្រប់គ្រាន់ និង អាចផ្គត់ផ្គង់ជាតិរ៉ែមួយចំនួនទៀតដល់កូនជ្រូក ។
- រាងកាយកូនជ្រូករឹងមាំ
- បង្ហាត់ឱ្យវាចេះសំរបខ្លួនជាបណ្តើរៗនឹងបរិយាកាសខាងក្រៅ ព្រមទាំងស្រួលចិញ្ចឹមពេលផ្តាច់ដោះ ។

### ខ. ទ្រុងត្រូវស្អាត កក់ក្ដៅ ព្រមទាំងស្ងប់ស្ងាត់ :

កូនជ្រូកទើបកើតចាញ់ធាតុត្រជាក់ ដូច្នេះត្រូវមានកន្លែងកំដៅឱ្យវា ។ អាចសង់ទ្រុងតូចមួយទំហំប្រហែល ១ម² ឬក៏ធ្វើធុងឈើ រែងឬស្សីក្រាលចំបើងឱ្យកក់ក្ដៅ ។ បើមានអគ្គិសនី ព្យួរអំពូលភ្លើង ១០០វ៉ាត់ មានសន្ទះដែកគ្របពីលើ កំពស់ ០,៥០ម ពីបាតទ្រុង ។ កាលណាកូនជ្រូកកាន់តែធំ យើងលើកអំពូលភ្លើងឡើងលើបន្តិចម្ដងៗ ។ កន្លែងដែលគ្មានអគ្គិសនី អាចដុតអុស ឬ ធ្យូងក៏បាន ។ ក្រោយ ១៥-២០ ថ្ងៃ ( តាមរដូវ ) ខែក្ដៅ ពេលថ្ងៃមិនបាច់កំដៅទេ ។ ក្នុងទ្រុងកំដៅត្រូវក្រាលចំបើង ឬ បាវ ចៀសវាងកុំឱ្យកូនជ្រូកដេកផ្ទាល់ឥដ្ឋ ឬ ក្ដារ ។ ទ្រុងត្រូវស្ងួតមិនត្រូវមានទឹកដក់ ត្រូវមានរនាំងបាំងខ្យល់បាំងភ្លៀង ។

ទ្រុងសើម កូនជ្រូករងា ងាយមានជំងឺហើមស្ងួត រាគអាចម៍ ។ មិនគប្បីសង់ទ្រុងនៅកន្លែងអ៊ូអរ មានសំលេងខ្លាំង មានមនុស្សដើរចុះឡើង ព្រោះអាចបណ្ដាលឱ្យមេជ្រូកខ្លាច ផ្អើលជាន់កូន ព្រមទាំងបង្អាក់ការចេញទឹកដោះ ។

## C- របៀបថែទាំមេជ្រូកកូនច្រើន :

កាលណាមេជ្រូកកើតកូនច្រើនជាងដោះ ឬ ក៏មេជ្រូកឈឺ មិនអាចឱ្យកូនបៅ យើងអាចប្រើបណ្ដារបៀបណាមួយក្នុងរបៀបដូចតទៅនេះដើម្បីចិញ្ចឹមកូនជ្រូកឱ្យរស់ :-

### ១. ចិញ្ចឹមផ្ញើ :

របៀបនេះស្រួលធ្វើ អាចធានាឱ្យកូនជ្រូកធំធាត់ល្អ ប៉ុន្តែអនុវត្តបានតែនៅកន្លែងណាដែលមានមេច្រើន កើតកូនតំណាលគ្នា ។

អនុវត្តរបៀបចិញ្ចឹមផ្ញើបាន លុះត្រាតែអាយុរបស់កូនជ្រូកប្រហាក់ប្រហែលគ្នា មិនលើសខ្វះគ្នាលើសពី ៣ ថ្ងៃ ។ បើអាយុលើសខ្វះគ្នាច្រើនត្រូវរង់ចាំមេដទៃទៀតកើតកូន ។ បើយកទៅផ្ញើមេកើតកូនហើយ ២-៣ ថ្ងៃ ចាំបាច់ត្រូវឱ្យកូនជ្រូកនោះបៅដោះមេវា តិចបំផុតក៏មួយថ្ងៃដំបូងដែរ ។

ដើម្បីកុំឱ្យមេជ្រូកដឹងថាមានកូនដទៃទៀតផ្ញើ មុននឹងលែងកូនជ្រូកបញ្ចូលគ្នា ត្រូវដាក់វាក្នុងទ្រុងរួមគ្នា ( ទាំងកូនបង្កើត ទាំងកូនផ្ញើ ) រួចយកប្រេងកាត ឬ ក្រេស៊ីលមកលាបគ្រប់កូនទាំងអស់ ។

ចំពោះកូនដែលតូចពេក ហើយខ្សោយផង គប្បីយកចេញតាំងពីថ្ងៃដំបូង ដើម្បីកុំឱ្យខាតចំណី និង ខាតកំលាំង ។

### ២. ចែកកូនជ្រូកជាក្រុម :

ក្នុងលក្ខណៈដែលគ្មានមេផ្ញើ អាចចែកកូនជ្រូកជាក្រុម ។

- **ចែកជាពីរក្រុម :**

**ក្រុមទី ១ :**

ជាក្រុមកូនជ្រូកធំធាត់ ចំនួនរបស់វាស្មើនឹងចំនួនដោះរបស់មេ ។

**ក្រុមទី ២ :**

ក្រុមកូនជ្រូកដែលនៅសល់ យើងឱ្យវាបៅដោះពីរ ។ ក្រុមទាំងពីរនេះត្រូវផ្លាស់ប្តូរគ្នាបៅ ដូចនេះគ្រប់ដោះទាំងអស់ សុទ្ធតែមានកូនបៅ ហើយកូនដែលខ្សោយក៏បានបៅដោះច្រើន ។

- **ចែកជាបីក្រុមប្រហាក់ប្រហែលគ្នា :**

ឧទាហរណ៍កូន ១៦ យើងចែកជា ៥- ៥- ៦ ឱ្យវាបៅផ្លាស់ប្តូរគ្នា ក្នុងម្តងយកពីរក្រុមឱ្យបៅ ដូចនេះក្នុងបីដង គ្រប់កូនបានបៅពីរដង ។

- **ចែកជាបីក្រុម :**

មួយក្រុមដាក់កូនខ្សោយៗ ហើយឱ្យបៅគ្រប់ពេលចេញទឹកដោះ (ឱ្យបៅដោះខាងក្រោយ ) ។ ពីរក្រុមផ្សេងទៀតផ្លាស់ប្តូរគ្នា ( បៅដោះខាងមុខ ) ធ្វើយ៉ាងនេះអាចឱ្យកូនជ្រូកធំស្មើគ្នា ។

ការចែកជាក្រុមឱ្យបៅនេះស្មុគ្រស្មាញណាស់ របៀបនេះច្រើនអនុវត្តតែលើជ្រូកពូជល្អ និង មានលក្ខណៈអាចថែទាំបាន ។

## D - ក្រៀវ និង ចាក់ថ្នាំការពារឱ្យកូនជ្រូក :

គប្បីក្រៀវកូនជ្រូកដែលនៅសល់ពីការជ្រើសរើសសំរាប់ធ្វើពូជ ។ ក្រៀវនៅពេលកូនជ្រូកកំពុងបៅដោះជាការល្អ ប៉ុន្តែត្រូវចៀសវាងពេលទឹកដោះចុះ (ក្រោយអាទិត្យទី ៣) ពេលចាក់ថ្នាំការពារ និង ពេលផ្តាច់ដោះ។

អាចក្រៀវកូនជ្រូកឈ្មោលក្រោយពេលកើត ព្រោះរយៈពេលនេះមុខរបួសរហ័សជា មិនសូវឈឺ ប៉ុន្តែកូនជ្រូកនៅតូចពេក ពិបាកកាន់ ពិបាកចងអំបោះ ។ ក្រៀវក្នុងកំឡុងអាយុ ៧-១០ ថ្ងៃ ក្រោយពេលកើតជាការល្អ ។

ជ្រូកញីពូជបរទេសចិញ្ចឹមយកសាច់មិនបាច់ក្រៀវទេ ព្រោះថាចិញ្ចឹមដល់ពេលអាចលក់បាន ជ្រូកមិនទាន់រកឈ្មោលនៅឡើយទេ ។ ចំពោះជ្រូកក្នុងស្រុកដោយសារវារហ័សរកឈ្មោល ហើយពេលវេលាចិញ្ចឹមយកសាច់យូរ ត្រូវក្រៀវវា ។ ធម្មតាគេច្រើនក្រៀវក្នុងអាយុ ៣-៤ ខែ ។

មុនពេលផ្តាច់ដោះ ត្រូវចាក់ថ្នាំការពារឱ្យកូនជ្រូក ។ ចាក់ថ្នាំការពារជំងឺប៉េស្ត ជំងឺសារទឹក និង ជំងឺរាគកូនជ្រូក ។

E - **ការផ្តាច់ដោះ :**

ធម្មតាគេច្រើនផ្តាច់ដោះកូនជ្រូកក្នុងអាយុ ៨អាទិត្យ ប៉ុន្តែបច្ចុប្បន្ននេះគេផ្តាច់ដោះក្នុងអាយុ ៦ អាទិត្យ មានកន្លែងខ្លះផ្តាច់ដោះក្នុងអាយុ ៣៥ ថ្ងៃ ។

ការផ្តាច់ដោះត្រូវធ្វើជាបណ្តើរៗ មិនត្រូវផ្តាច់ភ្លាមតែម្តងនោះទេ ហើយត្រូវយកមេចេញពីទ្រុង ទុកកូនក្នុងទ្រុងចាស់ចំនួនមួយអាទិត្យ ( មិនមែនយកកូនចេញនោះទេ ) ធ្វើយ៉ាងនេះដើម្បីកុំឱ្យកូនជ្រូកនឹកមេ នឹកទ្រុង។

អាចផ្តាច់ដោះទាំងសំបុកតែម្តង ឬ ក៏ចែកជាក្រុមទៅតាមសុខភាពរបស់វា ។ ប៉ុន្តែត្រូវយកចិត្តទុកដាក់ចំពោះចំណុចដូចតទៅនេះ :-

**ផ្តាច់ជាបណ្តើរៗ :**

បន្ថយពេលបៅក្នុងមួយថ្ងៃ ធ្វើយ៉ាងនេះមិនមានឥទ្ធិពលអាក្រក់ដល់សុខភាពរបស់កូនជ្រូក ឬ ក៏បណ្តាលឱ្យមេជ្រូកមានជំងឺរលាកដោះ ។

- ពេលផ្តាច់ដោះ ត្រូវទុកកូនក្នុងទ្រុងចាស់ នាំមេទៅទ្រុងផ្សេង
- បើកូនធំមិនស្មើគ្នា អាចឱ្យកូនធំផ្តាច់ដោះមុន កូនដែលនៅសល់ឱ្យបន្តបៅមួយរយៈទៀត ។
- ចំណីសំរាប់កូនជ្រូកផ្តាច់ដោះ ត្រូវឱ្យមានជីវជាតិគ្រប់គ្រាន់ មានជាតិសាច់ ( ១៨-២០ % ) រួចហើយចំណីក្រោយពេលផ្តាច់ ត្រូវឱ្យស្រដៀងនឹងចំណីមុនពេលផ្តាច់ដោះ ។

ចំណីត្រូវមានអនាម័យ ទាំងស្នូកចំណី ស្នូកទឹក ក៏ដូច្នោះដែរ ។ ចំពោះមេជ្រូកដែលសំបូរទឹកដោះ មុនពេលផ្តាច់ដោះចំនួន ៣-៥ ថ្ងៃ ត្រូវបន្ថយចំណី ដើម្បីកុំឱ្យមានជំងឺរលាកដោះ ។

ក្រោយពេលផ្តាច់ដោះ ត្រូវឧស្សាហ៍ពិនិត្យដោះមេជ្រូក បើមានជំងឺត្រូវព្យាបាលជាបន្ទាន់ ។

# VI - របៀបចិញ្ចឹមជ្រូកសាច់

ការចិញ្ចឹមជ្រូកសាច់ត្រូវឆ្លើយតបនឹងសំណូមពរដូចខាងក្រោមនេះ

- ត្រូវធ្វើយ៉ាងណាឱ្យជ្រូករហ័សធំ អាចគ្រប់ទំងន់លក់ក្នុងរយៈពេលខ្លី ។
- បន្ថយចំណាយចំណី ដើម្បីបានសាច់ ១ គក្រ ។
- អនុវត្តបែបបទបច្ចេកទេស តាំងពីចំណី និង ការថែទាំ ដើម្បីលើកកំពស់គុណភាពសាច់ ។

## A - កត្តាដែលមានឥទ្ធិពលដល់ការចិញ្ចឹមជ្រូកសាច់ :

### ក. ពូជ :

ពូជមានឥទ្ធិពលដល់ការធំធាត់ និង គុណភាពសាច់ និង ខ្លាញ់ ។ ល ។ ចំពោះពូជជ្រូកបរទេសបើចិញ្ចឹមត្រឹមត្រូវតាមបច្ចេកទេស នោះវារហ័សធំ ព្រមទាំងចំណាយចំណីអស់តិច ប៉ុន្តែបើការចិញ្ចឹមមិនសមស្របតាមបច្ចេកទេស វាក្រធំជាងពូជក្នុងស្រុកទៅទៀត ។ បើយើងចិញ្ចឹមជ្រូកយកសាច់ គប្បីចិញ្ចឹមពូជបង្កាត់ ។ ប៉ុន្តែបើគ្មានចំណី គ្មានទ្រុងត្រឹមត្រូវ គ្មានលក្ខណៈនឹងថែទាំជ្រូកបានល្អទេ នោះគួរចិញ្ចឹមជ្រូកពូជក្នុងស្រុកវិញ ព្រោះថាពូជក្នុងស្រុកពូកែទ្រាំទ្រនឹងលក្ខណៈលំបាកលំបិន ហើយ ។

### ចំណី :

ចំណីមានឥទ្ធិពលជាកត្តាកំណត់ពីជោគជ័យ ឬ បរាជ័យក្នុងការចិញ្ចឹមជ្រូកសាច់ ។

ឱ្យស៊ីចំណីមានគុណភាពល្អ និង គ្រប់គ្រាន់ ជ្រូករហ័សធំធាត់ ។ ចំណីក៏អាចធ្វើឱ្យជ្រូកក្រធំ ដោយសារ :-

- ឱ្យស៊ីមិនឆ្អែត
- ចំណីសំបូរជាតិសែលលុយឡូស តែខ្វះជីវជាតិដទៃទៀត
- បើឱ្យជ្រូកស៊ីចំណីមានជាតិម្សៅច្រើន ( ចំណីផ្តល់កំដៅ ) ជ្រូកសំបូរខ្លាញ់ ។

ហើយបើឱ្យចំណីមានជាតិខ្លាញ់ច្រើន នោះសាច់ជ្រូក និង ខ្លាញ់ជ្រូកនោះទន់ជ្រាយ ។

គប្បីឱ្យជ្រូកស៊ីឱ្យត្រូវម៉ោងពេល ដើម្បីឱ្យវារំលាយអាហារបានល្អ រហ័សធំ ។

## គ. ការថែទាំ :

ក្នុងលក្ខណៈពូជ និង ចំណីដូចគ្នា ជ្រូកដែលចិញ្ចឹមថែទាំដិតដល់ រហ័សធំ និង មិនសូវចុះចំណី កូនជ្រូកដែលចិញ្ចឹមដោយគ្មានការថែទាំដិតដល់ ក្រធំ ។

ត្រូវក្តាប់ឱ្យបាននូវលក្ខណៈពិសេសនៃជ្រូកនិមួយៗ ថាតើវាចូលចិត្តស៊ីស្អី មានទម្លាប់អាក្រក់យ៉ាងម៉េចខ្លះ ? ដើម្បីមានវិធានការបង្កាត់វាការពារវា និង ឱ្យចំណីឱ្យបានសមស្រប ។

### ១. ធ្វើចលនា ( ដើរ ):

ជ្រូកនៅតូចត្រូវធ្វើចលនាច្រើន ព្រោះថាការធ្វើចលនាជួយដល់ការរំលាយអាហារ និង ការផ្លាស់ប្តូរជីវជាតិក្នុងខ្លួន ជួយជំរុញការរីកធំធាត់នៃឆ្អឹង និង សាច់ ។ ប៉ុន្តែក្នុងរយៈពេលញាត់សាច់ គប្បីបន្ថយចលនា (ការដើរ) ដើម្បីបន្ថយការចំណាយថាមពល ។ ទុកថាមពលនេះ ដើម្បីជំរុញការធំធាត់ ។

**២. ពន្លឺថ្ងៃ :**

ទ្រុងសំរាប់កូនជ្រូកត្រូវមានពន្លឺគ្រប់គ្រាន់ ប៉ុន្តែពេលជ្រូកធំ ទ្រុងត្រូវមានពន្លឺតិច ( ល្ងិតតិចៗ ) ដើម្បីឱ្យជ្រូកដេកច្រើន ឆាប់ ធំ ។

**៣. កំដៅក្នុងទ្រុង :**

ទ្រុងក្តៅពេក ឬ ត្រជាក់ពេក សុទ្ធតែមានឥទ្ធិពលអាក្រក់ដល់ការធំធាត់របស់ជ្រូក ។ ជ្រូកកាន់តែធំ កាន់តែចាញ់កំដៅ ព្រោះថាអាកាសធាតុក្តៅ បណ្តាលឱ្យជ្រូកស៊ីមិនឆ្ងាញ់ ( ស៊ីតិច ) ជ្រូកនៅមិនស្ងៀម បានជាក្រធំ ។ ដូចនេះត្រូវយកចិត្តទុកដាក់ចំពោះអាកាសធាតុ ត្រូវធ្វើទ្រុងយ៉ាងណាឱ្យមានខ្យល់អាកាសចេញចូល ស្ងួត ។ ត្រូវមុជទឹកឱ្យជ្រូកមួយថ្ងៃ ១-២ ដង ។ ត្រូវដាំដើមឈើដែលមានម្លប់ ( ដូចជាដើមទឹកដោះគោ) ជុំវិញទ្រុង ប្រសិនជាអាចធ្វើបាន ។

**ឃ. សុខភាព និង ទំងន់កូនជ្រូកពេលកើត :**

ក្នុងលក្ខណៈចំណី និង ការថែទាំដូចគ្នា ជ្រូកដែលមានសុខភាពល្អ មានទំងន់ធ្ងន់ពេលកើត និង មានទំងន់ធ្ងន់ពេលផ្តាច់ដោះ ឆាប់ធំជាងកូនជ្រូកខ្សោយ ទំងន់ស្រាលពេលកើត និង ពេលផ្តាច់ដោះ ។

**ង. ពូជបង្កាត់ :**

ជ្រូកពូជកាត់ចិញ្ចឹមរហ័សធំ ចំណាយចំណីអស់តិចជាងពូជសុទ្ធ ។

ច. ក្រៀវ :

ត្រូវក្រៀវជ្រូកឈ្មោលទុកចិញ្ចឹមយកសាច់ ។ ព្រោះជ្រូកក្រៀវចិញ្ចឹមរហ័សធំជាងជ្រូកមិនក្រៀវ ហើយម្យ៉ាងទៀតអាចបំបាត់ក្លិនឆ្អេះក្នុងសាច់ និង ខ្លាញ់បានទៀតផង ។

ឆ. អាយុ :

ការរីកធំធាត់ និង គុណភាពសាច់ខុសគ្នាទៅតាមអាយុជ្រូក ។ ជ្រូកអាយុពី ១ ថ្ងៃ ដល់៣ខែ រីកឆ្អឹង និង សាច់ជាសំខាន់ ។ ដល់អាយុ ៦-៧ ខែ ក្រៅពីរីកឆ្អឹង និង សាច់ នៅរីកខ្លាញ់ទៀត ។ ចិញ្ចឹមលើសពី ៨ ខែ កំលាំងរីកធំធាត់របស់ជ្រូកចុះថយ ។

ជ្រូកកាន់តែធំ ខ្លាញ់កាន់តែច្រើន ស៊ីចំណីក៏កាន់តែច្រើន ។ ការចិញ្ចឹមជ្រូកសាច់ទទួលបានជោគជ័យ ឬ បរាជ័យនៅត្រង់ថាយើងគប្បីលក់ចេញនៅពេលណា ? ចំពោះជ្រូកពូជបរទេស ឬ ជ្រូកពូជកាត់ គប្បីលក់ចេញក្នុងអាយុ ៧-៨ខែ ពេលដែលជ្រូកមានទំងន់ ៩០-១០០ គក្រ ។

## B - បច្ចេកទេសចិញ្ចឹមជ្រូកសាច់ :

គេច្រើនបែងចែកការចិញ្ចឹមជ្រូកសាច់ជាបីតំណាក់កាល ដោយផ្អែកលើចំណុចពិសេសនៃការធំធាត់របស់វា ។

### ១. កូនជ្រូកពីពេលផ្តាច់ដោះដល់អាយុ ៣-៤ ខែ

ក្នុងតំណាក់កាលនេះកូនជ្រូកជួបនូវវិបល្លាសច្រើនណាស់ ពីផ្តាច់ពៅដោះមេមកស៊ីចំណីខ្លួនឯង ដែលច្រើនតែខ្វះជីវជាតិ មានវិបត្តិក្នុងផ្លូវរំលាយអាហារ ភាគ ។

ក្នុងតំណាក់កាលនេះឆ្អឹង និង សាច់រីកធំធាត់រហ័ស ហេតុនេះ ត្រូវឱ្យស៊ីចំណីឱ្យបានគ្រប់គ្រាន់ និង មានគុណភាពល្អ ។ ជាតិសាច់ក្នុង ចំណីត្រូវមានពី ១៦-២០ % ។ បើផ្តាច់ពេលនៅតូច ត្រូវឱ្យជាតិសាច់ ២០% រួចបន្ថយបន្តិចម្តងៗទៅតាមការរីកធំធាត់នៃខ្លួនវា ។ ជាតិកាល់ស្យូម ត្រូវមានពី ០.៦៥-០.៨០ % . ផូសស្វ័រពី ០.៥-០.៦ % ។ ដើម្បីធានាជាតិ សាច់មានគុណភាពល្អ មានជាតិរ៉ែគ្រប់គ្រាន់ គួរប្រើម្សៅត្រី ( ១០ % ក្នុង ចំណី ) ។ ក្រៅពីនេះត្រូវឱ្យស៊ីបន្លែស្រស់ខ្ចី ( ១-២ គក្រ ក្នុងមួយថ្ងៃ )។

កូនជ្រូកនៅតូចត្រូវការចំណីអាហារដែលមានជីវជាតិគ្រប់គ្រាន់ ប៉ុន្តែប្រដាប់រំលាយអាហាររបស់វានៅខ្សោយ ដូច្នេះត្រូវឱ្យស៊ីច្រើនពេលក្នុង មួយថ្ងៃ ( ៤-៥ ដង ) រួចបន្ទាប់មកបន្ថយនៅត្រឹម ៣ ដងក្នុង ១ថ្ងៃ ។

ទ្រុងត្រូវមានខ្យល់អាកាសចេញចូល មានពន្លឺគ្រប់គ្រាន់ និង មានធ្លាសំរាប់ឱ្យជ្រូកធ្វើចលនាបានដោយស្រួល ។ ពេលទើបផ្តាច់ដោះត្រូវ ប្រយត្ន័ការពារធាតុត្រជាក់ ពិសេសពេលយប់ និង ពេលភ្លៀង ។

នេះជាតំណាក់កាលឆ្លងកាត់យ៉ាងសំខាន់ បើឱ្យស៊ីមិនគ្រប់គ្រាន់ ជ្រូកក្រធំ ក្រិន រោមបះ ហើយងាយនឹងកើតជំងឺផ្សេងៗ ។

## ២. ជ្រូកអាយុ ៥.៦ ខែ

នេះជាតំណាក់កាលជ្រូករីកមាឌ និង កំពស់ ។ លទ្ធភាពរំលាយ អាហារខ្ពស់ អាចឱ្យស៊ីចំណីថ្លៃថោក ស្រួលរក ដូចជា ដំឡូងមី ស្លឹក សណ្តែកដីស្ងួតកិនឱ្យហ្មត់ ទងដំឡូងផ្កាក្រៀម និង ប្រភេទស្មៅនានា ។

ត្រូវឱ្យជ្រូកធ្វើចលនាដើម្បីជំរុញលទ្ធភាពរំលាយអាហារ ។ ក្រៅពី រីកឆ្អឹង និង សាច់ ជ្រូកចាប់ផ្តើមមានខ្លាញ់បន្តិចហើយ ។ សេចក្តីត្រូវការ សាច់ក្នុងតំណាក់កាលនេះគឺ ១៤ % ។ អាចបន្ថយម្សៅត្រី ហើយបន្ថែម កាកប្រេងដូង ។

បើយើងចិញ្ចឹមត្រឹមត្រូវតាមបច្ចេកទេស ដងខ្លួនជ្រូករីកធំធាត់ ហើយជ្រូករហ័សធំក្នុងតំណាក់កាលបន្តមកទៀត ។

បើក្នុងតំណាក់កាលនេះដងខ្លួនជ្រូកមិនរីកធំធាត់ តែរហ័សមានខ្លាញ់ ( អាចបណ្តាលមកពីចំណីខ្វះជាតិរ៉ែ ជាតិសាច់ តែសំបូរជាតិស្ករ ) ។ នេះជាតំណាក់កាលស្រួលចិញ្ចឹម ហើយជ្រូកមិនសូវមានជំងឺ ។

### ៣. អាយុ ៧.៨ ខែ :

តំណាក់កាលនេះជ្រូកមានលទ្ធភាពស្តុកខ្លាញ់ច្រើន ហើយបន្ទាប់ពីអាយុ ៨ ខែឡើងទៅការរីកធំធាត់របស់ជ្រូកចុះថយ ។ ក្នុងតំណាក់កាលនេះគប្បីយកចិត្តទុកដាក់លើបញ្ហាមួយចំនួនដូចតទៅនេះ :-

- ត្រូវឱ្យចំណីផ្តល់កំដៅច្រើន ( អាចប្រើដល់ ៩០ % )
- ជាតិសាច់ ១៣ %
- បន្ថយចលនាដើរចុះឡើង រក្សាភាពស្ងប់ស្ងាត់ ដើម្បីឱ្យជ្រូកដេកច្រើន
- ឧស្សាហ៍ងូតទឹកឱ្យជ្រូក

## សង្ខេបមកវិញ :

ក្នុងការចិញ្ចឹមជ្រូក ទោះបីជាយើងចែកជាបីតំណាក់កាលក៏ដោយក៏តំណាក់កាលនិមួយៗមានទំនាក់ទំនងនឹងគ្នាជិតស្និទ្ធ និង មានឥទ្ធិពលដល់គ្នាទៅវិញទៅមក ។ ចិញ្ចឹមពីតូចល្អ ជាបច្ច័យឱ្យការចិញ្ចឹមជាបន្តធាប់ធំធាត់ ។

បើប្រសិនជាយើងសំបូរចំណី ក្នុងតំណាក់កាលទី ២ យើងឱ្យចំណីដូចតំណាក់កាលទី ១ នោះជ្រូកនឹងរហ័សធំ ហើយអាចលក់ចេញក្នុងរយៈពេលខ្លី ចំណាយលើចំណីអស់តិច ជ្រូកមានខ្លាញ់តិច សាច់ក្រហមច្រើន ។

# VII - របៀបចិញ្ចឹមជ្រូកបា

**អំពីចំណីអាហារ និង ការថែទាំ :**

ចំពោះជ្រូកបា គឺយើងត្រូវធ្វើយ៉ាងណាកុំឱ្យវាធាត់ពេក ឬ ក៏ស្គមពេក ព្រោះថាបើវាធាត់ពេក ឬក៏ស្គមពេកនោះ នឹងបណ្តាលឱ្យបាត់ភាពខ្លាំងក្លាក្នុងការពាក់មេ ដែលជាមូលហេតុបណ្តាលឱ្យមានកូនតិច ។

- ត្រូវឱ្យវាធ្វើចលនា ដើម្បីឱ្យជើងវារឹងមាំ មានន័យថាទ្រុងត្រូវមានទីធ្លា ដើម្បីឱ្យវាអាចដើរចុះដើរឡើងបាន ។

- ត្រូវឱ្យជ្រូកបាស៊ីចំណីតាមពេលវេលា ហើយឱ្យវាពាក់មេនៅពេលព្រឹកព្រលឹម ឬ ពេលល្ងាចត្រជាក់ ។ មុនពេលឱ្យវាពាក់មេមិនត្រូវឱ្យវាស៊ីឆ្អែតពេកទេ ។

- ចំណីត្រូវមានជាតិសាច់ ( Protein ) ១៦ % ហើយត្រូវមានជាតិរ៉ែ និង វីតាមីនគ្រប់គ្រាន់ ។ ក្នុងមួយថ្ងៃត្រូវឱ្យវាស៊ីចំណីដែលយើងលាយស្រាប់ប្រហែល ២ គក្រ និង ឱ្យត្រកួន ពី ១-១.៥ គក្រ ។ ឱ្យវាស៊ីថែមពងមាន់ ឬ ពន្លកស្រូវ ក្រោយពេលពាក់មេ ។

- ដើម្បីឱ្យប្រាកដថាមានកូន ត្រូវឱ្យបាពាក់មេពីរដង ។

- ក្នុងមួយអាទិត្យអាចឱ្យជ្រូកបា ពាក់មេបី ឬ បួនដង ។

- ត្រូវនាំជ្រូកបាទៅកាន់ទ្រុងជ្រូកមេ ។ ប៉ុន្តែត្រូវប្រយ័ត្នកុំឱ្យបាក្មេងពាក់មេកាច ព្រោះថាបើក្នុងការពាក់មេជាលើកដំបូងនេះ បានោះត្រូវមេខាំ វានឹងក្លាយជាជ្រូកបាកំសាក ខ្លាចមេ ដែលជាការលំបាកក្នុងការឱ្យវាពាក់មេផ្សេងទៀត ។

- ត្រូវមានកម្មវិធីឱ្យវាពាក់មេជាប្រចាំ ព្រោះថាបើឱ្យវាសំរាកតែ ២ ឬ ៣ ខែនោះ ប្រសិទ្ធិភាពនៃការពាក់មេរបស់វានឹងចុះខ្សោយ ។
- ជ្រូកបាមួយអាចឱ្យពាក់មេពី ១៥-២០ ក្បាល ។ ប៉ុន្តែបើអនុវត្តរបៀបបង្កាត់ពូជដោយសិប្បនិម្មិត ជ្រូកបាមួយអាចបង្កាត់ជាមួយជ្រូកមេពី ៨០ ទៅ ១០០ ក្បាល ។
- កុំទុកជ្រូកបាយូរឆ្នាំពេក ប្រើវាត្រឹម ៣-៤ ឆ្នាំ បានហើយ ។

**អំពីទ្រុង :**

ទ្រុងជ្រូកបាត្រូវសង់ឱ្យឆ្ងាយពីទ្រុងជ្រូកមេ ។ ព្រោះថាបើវានៅជិតជ្រូកមេនោះ ភាពរំជើបរំជួលនឹងមានជាប្រចាំ ជាហេតុបណ្ដាលឱ្យខ្សោយកំលាំង ។

ទ្រុងជ្រូកបាត្រូវមានជញ្ជាំងកំពស់ពី ១,២ម-១,៥ម ។ ទ្វារត្រូវធ្វើឱ្យមាំ កុំឱ្យវាចេញរួច ទៅខាំគ្នានឹងជ្រូកបាដទៃទៀត ឬ ក៏ទៅពាក់មេពាសវាលពាសកាល ។

# VIII - របៀបជ្រើសរើសជ្រូកទុកធ្វើពូជ

របៀបជ្រើសរើសជ្រូកទុកធ្វើពូជ ដែលងាយស្រួលគឺពឹងផ្អែកលើបទពិសោធន៍ដែលយើងធ្លាប់អនុវត្តនៅតាមជនបទ ។

## ១. ជ្រើសរើសកូនជ្រូក :

ត្រូវជ្រើសកូនណារហ័សរហួន ស្បែកស្តើង រោមទន់ផ្ងារ ខ្លួនវែង ខ្នងត្រង់ ឬ កោងឡើងលើបន្តិច ជើងទាំងបួនត្រង់ ស្វាពេញ ខ្លួនមានលំនឹង មានគ្រប់ចំណុចនៃពូជជ្រូកដែលយើងចង់បាន ។ មានដោះច្រើនជាង ១២ ប្រដាប់បន្តពូជធម្មតា ចូលចិត្តស៊ីចំណី កន្ទុយបក់ចុះឡើង ខ្មៅឡើងលើ ។

## ២. ជ្រើសរើសទុកធ្វើមេ :

យកជ្រូកណាដែលមានខ្លួនវែង ខ្លួនមានលំនឹង តួថ និង ភ្លៅរីកស្វាពេញ ទ្រូងជ្រៅ ជើងទាំងបួនត្រង់មាំ ក្រចកជើងជិត ដើរលើក្រ ចក ។ មានដោះគត់គូ ហើយច្រើនជាង ១២ អត់មានដោះស្វិត ចន្លោះពីដោះមួយទៅដោះមួយស្មើគ្នា ហើយពេលវាដេកជួរដោះខាងលើ និងខាងក្រោមឃ្លាតគ្នាមិនឆ្ងាយពេក ។

## ៣_ ជ្រើសទុកធ្វើជ្រូកបា :

ជ្រើសជ្រូកណាដែលមានសុខភាពល្អ រហ័សរហួនតែស្លូត ខ្លួនវែង ខ្នងទូលាយ ស្មាទូលាយ ខ្ពស់ជាង ឬ ស្មើគូថ ជើងទាំងបួនត្រង់ហើយរឹងមាំ ក្រចកជើងជិត ដើរលើក្រចក ចន្លោះរវាងជើងមុខ និង ជើងក្រោយទូលាយ ។ មានពងទាំងពីរធំស្មើ អត់ធ្លាក់ចុះ មានដោះច្រើនជាង ១២ ចន្លោះដោះទាំងពីរជួរស្មើគ្នា ។



# IX - អំពីទ្រុងនិងកិច្ចការមួយចំនួនផ្នែកបសុពេទ្យ

## ក. អំពីទ្រុង :

### ១. ទ្រុងត្រូវសង់នៅកន្លែងដែលមានដីខ្ពស់ :

គ្មានក្រហេងក្រហូង ស្រួលបញ្ចេញទឹក ។ ត្រូវមានម្លប់ត្រជាក់ និង មានខ្យល់អាកាសចេញចូលស្រួល ។ ត្រូវសង់នៅកន្លែងណាដែលអាចមានលទ្ធភាពពង្រីកទៅថ្ងៃក្រោយ ហើយត្រូវមានដីមួយចំនួនសំរាប់ដាំស្មៅ ដាំបន្លែ និង សំរាប់លែងឱ្យជ្រូកធ្វើចលនា ( ដើរ ) ។

### ២. ត្រូវមានប្រភពទឹកស្អាត :

បើសង់នៅក្បែរក្រុងត្រូវជ្រើសរើសកន្លែងណាដែលអាចមានលទ្ធភាព ត បណ្តាញទឹកស្អាត ឬបើមិនដូច្នោះទេ ត្រូវជ្រើសរើសកន្លែងណាដែលយើងអាចបុកអណ្តូងយកទឹកមកប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ ហើយទឹកនោះមិនមានឥទ្ធិពលអាក្រក់ដល់សុខភាពសត្វ និង មនុស្ស ។

### ៣. ត្រូវសង់ទ្រុងឆ្ងាយពីទីប្រជុំជន :

ឆ្ងាយពីកន្លែងមានមនុស្សកុះករដូចជាផ្សារ សាលារៀន ។ល។ យ៉ាងតិចបំផុត ២០០-៣០០ម ត្រូវឱ្យឆ្ងាយពីផ្លូវជាតិ ឆ្ងាយពីឡកំបោរ ឡឥដ្ឋ និង សត្តឃាតដ្ឋាន ១០០០ម ។

ត្រូវធានាគោលការណ៍ជាមូលដ្ឋានដូចតទៅនេះ :-

- ទ្រុងត្រូវតែកក់ក្តៅពេលត្រជាក់
- ហើយត្រូវតែល្ហើយ ត្រជាក់ពេលអាកាសធាតុក្តៅ

- ត្រូវឱ្យមានខ្យល់អាកាសចេញចូល តែត្រូវការពារកុំឱ្យខ្យល់បោកបក់ និង ភ្លៀងជះចូល ។
- ត្រូវមានពន្លឺថ្ងៃគ្រប់គ្រាន់ ដើម្បីឱ្យជ្រូកធំធាត់ និង ការពារកុំឱ្យមានជំងឺ
- ត្រូវឱ្យមានពន្លឺព្រះអាទិត្យជះចូលនៅពេលព្រឹក
- ត្រូវតែស្ងួត ដើម្បីរាំងខ្ទប់ការរីកលូតលាស់នៃមេរោគ
- ត្រូវស្ងប់ស្ងាត់ ព្រោះជ្រូកងាយនឹងរំជួលដោយសារសំលេងខ្លាំង

**៤. អំពីរោងទ្រុង :**

មានពីរប្រភេទ

- ទ្រុងជំបូលសង្ខាង អាចសង់ទិសខាងណាក៏បាន
- ទ្រុងតំបូលតែម្ខយ ច្រើនធ្វើសំរាប់ជ្រូកបា

* ចំពោះជ្រូកទំងន់ពី ២០-៥០គក្រ អាចដាក់ជ្រូកមួយក្នុង១ម²

* - - ៥០-១០០គក្រ អាចដាក់ជ្រូកមួយក្នុង២ម²

ចំពោះមេជ្រូក ២,៥០ម² ក្នុងមេមួយ

ចំពោះមេបំបៅកូន ១០ម²

ដូច្នេះបើយើងមានទ្រុងទំហំ ៤ x ៥ម : ២០ម² នោះយើងអាចដាក់កូនជ្រូកបាន ២០ ក្បាល ឬ ជ្រូកសាច់១០ ក្បាល ឬ មេក្រមុំ ៨ ក្បាល ឬក៏បា មួយក្បាល ។

**៥. របៀបដឹកជ្រូក :**

**A - របៀបដឹកជ្រូកឱ្យដើរ :**

ការដឹកជ្រូកឱ្យដើរទៅតាមបំណងរបស់យើង ទោះបីមិនមែនជាការ

លំបាក ប៉ុន្តែបើមិនចេះរបៀប ក៏អាចជាការលំបាក ព្រោះជ្រូកដើរតែពីស តែពាសតាមចិត្តវា ។

ទៅតាមលក្ខណៈជាក់ស្តែង យើងអាចប្រើរបៀបដូចតទៅនេះ :-

**ទី ១ :** កាន់បន្ទៃមួយក្តាប់ដាក់មុខវា ឱ្យវាស៊ីបណ្តើរដើរបណ្តើរ ប៉ុន្តែចំពោះជ្រូកថ្លាង ប្រើរបៀបនេះមិនមានលទ្ធផលទេ ។

**ទី ២ :** ឱ្យមនុស្សម្នាក់យកធុងគ្របមុខវាដល់ក្បាល បិទភ្នែកវា ធ្វើឱ្យវាលែងដឹងទិស រួចឱ្យមនុស្សម្នាក់ទៀតកាន់កន្ទុយរុញវា ។

**ទី ៣ :** ឱ្យមនុស្សម្នាក់កាន់ស្លឹកត្រចៀកទាំងពីរទាញដើរ ហើយឱ្យមនុស្សម្នាក់ទៀតរុញកន្ទុយ ។

**ទី ៤ :** យកល្ហសបន្ទាដាក់សង្ខាងផ្លូវ ឬក៏សង់ជញ្ជាំងឥដ្ឋ ទុកផ្លូវតូចមួយសំរាប់នាំជ្រូកចេញ ។

**B - របៀបដឹកជញ្ជូនជ្រូក :**

ការដឹកជញ្ជូនជ្រូកពីកន្លែងមួយទៅកន្លែងមួយ ជារឿងដែលគេតែងឃើញជារឿយៗ ។ ដោយសារជ្រូកជាសត្វដែលមានខ្លាញ់ច្រើន រន្ធបញ្ចេញញើសតិច បានជាងាយនឹងមានជំងឺ កាលណាកន្លែងចង្អៀត ក្តៅស្អុះ ដូចនេះត្រូវធ្វើយ៉ាងណាឱ្យមានខ្យល់ចេញចូល និងឱ្យទឹកផឹកឱ្យបានគ្រប់គ្រាន់។

**១. ដឹកដើរ :**

ច្រើនអនុវត្តលើជ្រូកបា ។ គប្បីដឹកដើរឱ្យបានពីព្រឹក ហើយយឺតៗ កាលណាឃើញវាហត់ ត្រូវរកម្លប់ឱ្យវាសំរាក និង ឱ្យវាផឹកទឹកឱ្យ

បានគ្រប់គ្រាន់ ។ បើអាកាសធាតុក្ដៅខ្លាំង ពេលឈប់សំរាកត្រូវស្រោចទឹកឱ្យសព្វខ្លួនវា សឹមចាប់បន្តដំណើរទៅទៀត ។

**២. ដឹកតាមកន់. ម៉ូតូ :**

យកឈើពីរចងទទឹងលើចង្កើរ រួចចងជ្រូកពីលើនោះ ប៉ុន្តែល្អបំផុតបើដាក់លើជុចឬស្សី ឬ ផ្ដៅ ។ បើដឹកផ្លូវឆ្ងាយត្រូវកាច់ស្លឹកឈើ ស្លឹកចេក ឬដង្កៀតផ្ទោក គ្របពីលើខ្លួនវា ។

**៣. ដឹកដោយរថយន្ត :**

ទោះបីជាដឹកជិត ឬ ឆ្ងាយ ក៏មិនត្រូវឱ្យវាចង្អៀតពេកទេ ។ ធម្មតាក្នុងឡានតែងមានក្លិន ដូច្នេះមិនត្រូវបិទទ្វារឡានទេ។ មុនពេលដឹកត្រូវបង្អត់ចំណី ឱ្យស៊ីតែបន្តិចបន្តួច ឬក៏បង្អត់វាមួយពេល។ បើដឹកផ្លូវឆ្ងាយ តាមផ្លូវត្រូវឈប់សំរាក មុជទឹកឱ្យវា ហើយពេលទៅដល់កន្លែងមុជទឹកឱ្យវាម្ដងទៀត។ ក្រោយពេលជ្រូកបាត់ហត់ ឱ្យវាស៊ីជាធម្មតាឡើងវិញ។

**គ. របៀបឱ្យជ្រូកផឹកថ្នាំ :**

មានប្រភេទថ្នាំបីយ៉ាង : ថ្នាំទឹក ថ្នាំម្សៅ និង ថ្នាំគ្រាប់ ។ ថ្នាំខ្លះមានក្លិនធម្មតា ខ្លះមានក្លិនពិបាកទ្រាំ ខ្លះល្វីងចត់ ។

របៀបដែលប្រសើរបំផុតគឺឱ្យវាស៊ី ឬ ផឹកដោយគ្មានការបង្ខិតបង្ខំ

- ថ្នាំដែលរលាយក្នុងទឹក គប្បីឱ្យវាផឹកជាមួយទឹក ។ មុនឱ្យវាផឹកថ្នាំ ត្រូវបង្អត់ទឹកវាមួយរយៈ ឱ្យវាស្រេកខ្លាំង សឹមឱ្យវាផឹក ( លាយទឹកល្មមតែថ្នាំរលាយបានហើយ )។

- ចំពោះថ្នាំម្សៅដែលមិនរលាយក្នុងទឹក ប្រសិនបើជាគ្រាប់ ត្រូវកិនឱ្យទៅជាម្សៅ លាយជាមួយចំណី លាយបន្តិចបានហើយ រួចដាក់ចំណីដែលលាយថ្នាំនោះឱ្យវាស៊ីមុន ។

ចំពោះថ្នាំដែលមានក្លិន ធ្វើឱ្យជ្រូកមិនចូលចិត្តស៊ី ឬ ធីកនោះ ត្រូវបង្ខំឱ្យវាផឹក ។ ប្រើសឺរ៉ាំងអត់ម្ជុល បូមថ្នាំបាញ់ចូលក្នុងមាត់ កន្លែងអត់ធ្មេញ ។

មិនត្រូវបាញ់បញ្ចូលក្នុងពេលជ្រូកកំពុងស្រែកទេ ព្រោះថ្នាំអាចនឹងចូលទៅក្នុងសួត បណ្ដាលឱ្យមានជំងឺរលាកសួត ឬក៏អាចឱ្យជ្រូកងាប់ ។

## ឃ. របៀបចាក់ថ្នាំ និង កន្លែងចាក់ថ្នាំ :

ការចាក់ថ្នាំមានច្រើនរបៀប ទៅតាមប្រភេទថ្នាំ : ចាក់សើស្បែក ចាក់សាច់ ចាក់សរសៃ ចាក់ក្នុងស្រទាប់ពោះ ។ មុនពេលចាក់ ត្រូវសំអាតកន្លែងចាក់ដោយ អាល់កុល ឬ ថ្នាំក្រហម ។

### ១. ចាក់សើស្បែក ( S/C ) :

ប្រើចំពោះប្រភេទថ្នាំមួយចំនួន ដូចជា ថ្នាំការពារ ( Vaccin ) ឬក៏ថ្នាំប្រភេទធម្មតាដូចជា Camphora, Cafeine ។ ល ។ កន្លែងចាក់សើស្បែកមានច្រើនកន្លែងណាស់ ប៉ុន្តែធម្មតាច្រើនប្រើម្ជុលខ្លី ចាក់ក្រោមត្រចៀក ឬ ក៏នៅគូថ មិនត្រូវចាក់ជ្រៅពេកទេ ប្រហែល ១សម ល្មម ។

### ២. ចាក់សាច់ ( I.M ) :

ប្រើចំពោះប្រភេទថ្នាំដូចតទៅនេះ :-

Penicilline, Streptomycine, Sulfamide និងថ្នាំវីតាមីន ។

### ៣. ចាក់សរសៃ (I.V ) :

ចាក់នៅលើស្លឹកត្រចៀកខាងក្រោយ ។ យកខ្សែចងគល់ត្រចៀក ឬ ក៏យកដៃច្របាច់ឱ្យសរសៃលេចឡើង រួចចាក់ម្ជុលបញ្ឈៀងតាមរន្ធសរសៃ

### ៤. ចាក់ថ្នាំក្នុងស្រទាប់ពោះ :

ប្រើសំរាប់បូមបញ្ចូលទឹកស្ករ ឬ ក៏ទឹកអំបិល ជាចំនួនច្រើនទៅក្នុងខ្លួនជ្រូក ។

ចេញក្នុងពេលឆាប់ៗនេះហើយ
សៀវភៅ បច្ចេកទេសចិញ្ចឹមមាន់
ដោយ បណ្ឌិត ឈុំ ភិតលន់
និង បណ្ឌិត ជា ណោង

# I - ជំងឺឆ្លង

## ១. ជំងឺប៉េស្ត ( Peste Porcine )

ជំងឺប៉េស្ត ជាជំងឺដ៏សាហាវមួយ ជ្រូកដែលកើតជំងឺនេះងាប់ ១០០ % ។ ជំងឺនេះកើតមាននៅគ្រប់ទីសទីក្នុងទូទាំងប្រទេសរបស់យើង ហើយឆ្លងរាលដាលយ៉ាងរហ័ស ពិសេសនៅពេលប្រមូលទិញ ដឹកជញ្ជូនជ្រូក ឬ ក៏នៅពេលដែលខ្វះចំណីអាហារ រណ្ដោលឱ្យជ្រូកបាក់កំលាំង ។

### ក. រោគសញ្ញា :

លក្ខណៈពិសេសនៃជំងឺនេះ គឺឆ្លងរាលដាលឆាប់រហ័សណាស់ ។ យើងអាចឃើញរោគសញ្ញារបស់វានៅលើប្រដាប់រំលាយអាហារ ប្រដាប់ដកដង្ហើម នៅលើស្បែក និង នៅលើសរសៃប្រសាទ ។

ជំងឺច្រើនកើតឡើងក្នុងករិតធ្ងន់ធ្ងរ រយៈពេលដែលជំងឺនេះនៅសម្ងំស្ងៀម គឺពី ៣-៥ ថ្ងៃ ជ្រូកក្ដៅតិចៗ ស៊ីតិច លាមករឹង ។ បន្ទាប់មកក្ដៅខ្លាំង ៤១-៤២ °C ជ្រូកលែងស៊ីចំណី ច្រើនក្អួតចង្អោរ ភ្នែកក្រហម ហើយមានពពឹកភ្នែកច្រើន ។

### ប្រដាប់រំលាយអាហារ :

ជ្រូកគៀន ទល់លាមកពេលក្ដៅខ្លាំង ប៉ុន្តែក្រោយមកជ្រូកមានការរាគរូសយ៉ាងខ្លាំង ក្នុងប៉ុន្មានថ្ងៃមិនដាច់ ហើយជួនកាលមានទាំងឈាមស្រស់ ហើយលាមកស្អុយខ្លាំងណាស់ ។

ក្នុងមាត់នៅជើងធ្មេញ និង គៀនអណ្ដាត មានដំបៅពណ៌លឿងស ឬ ក៏លឿងប្រផេះ ។

**ប្រដាប់ដកដង្ហើម :**

រលាករន្ធច្រមុះ ហៀរទឹកសំបោរខាប់ ជួនទៅជុំវិញរន្ធច្រមុះមានដំបៅរលាក ។ ជ្រូកក្អក ពិបាកដកដង្ហើម ចង្វាក់ដង្ហើមប្រែប្រួល ទម្លាក់កន្ទុយ ខ្នងកោង អង្គុយដូចឆ្កែអង្គុយ ដកដង្ហើមឮសូរឃូសខស ហើយច្រើនស្លាប ។

**ប្រពន្ធ័សរសៃប្រសាទ :**

ដោយសារវីរុសរាតត្បាត បណ្តាលឱ្យរលាកខួរ ចេញឈាមក្រោមស្រោមខួរ បណ្តាលឱ្យជ្រូកកន្ត្រាក់ខ្លួន ( ពិសេសពេលយើងស្ទាបវា ) ។ ជ្រូកស្ពឹកជើង ដើរល្វៃល្វៃ ក្នុងករណីជំងឺធ្ងន់អាចមានដំបៅពេញខ្លួន ។ ជំងឺប៉េស្តអាចបណ្តាលឱ្យមេជ្រូករលូតកូន ។

**នៅលើស្បែក :**

មានចំណុចក្រហមតូចៗ ពិសេសនៅចន្លោះភ្លៅទាំងពីរ និង នៅពោះ ជួនកាលក្រហមទាំងផ្ទាំងតែម្តង ។

ទីចុងបំផុតជ្រូកលែងស៊ីចំណី រាគ ដេកស្ពឹកមួយកន្លែង កំដៅខ្លួនចុះជាបណ្តើរៗ ញ័រញាក់ រួចហើយងាប់តែម្តង ។

ជំងឺច្រើនបន្ទាយពេលពី ៥-១៥ ថ្ងៃ អត្រាងាប់អាចមានពី៩០ % ឡើងទៅ ។ ជួនក្នុងលក្ខណៈធ្ងន់ធ្ងរមែនទែន ជំងឺនេះអាចសំលាប់ជ្រូកតែក្នុងរយះពេលមួយថ្ងៃ ដោយគ្មានរោគសញ្ញាច្បាស់លាស់ ។

ជួនក្នុងលក្ខណៈខ្លះ ជំងឺមានសភាពស្រាលជាងខាងលើ ហើយរោគសញ្ញារបស់វាក៏ស្រាលជាង ក្តៅតិចៗ ស៊ីតិច ភ្នែកស្រអាប់មានអាចម៍ភ្នែក លាមកជួនរឹង ជួនរាវ ។ ជំងឺនេះអាចបន្ទាយពេលពី ១-២ ខែ ។

ជូនក៏មានជ្រូកខ្លះជា ប៉ុន្តែក្លាយជាជ្រូកក្រិន ហើយជ្រូកនេះគ្រោះថ្នាក់ណាស់ ព្រោះអាចពាំជំងឺ និង សាបព្រោះជំងឺរហូតដល់ពេលបីខែក្រោយ។

**ខ. ការពារ :**

ចាក់ថ្នាំការពារជាការសំខាន់ណាស់ ។ ប៉ុន្តែគប្បីយកចិត្តទុកដាក់លើបញ្ហាមួយចំនួនដូចតទៅនេះ :-

- ថែរក្សាឱ្យជ្រូកមានសុខភាពល្អ អនុវត្តអនាម័យឱ្យបានត្រឹម ត្រូវ ត្រូវត្រួតពិនិត្យចំពោះការដឹកជញ្ជូនជ្រូកពីតំបន់មួយទៅតំបន់មួយ និង ត្រូវត្រួតពិនិត្យគ្រប់ទីសត្តឃាដ ។

- ត្រូវចាក់ថ្នាំការពារតាមពេលកំណត់ ចាក់លើកទី ១ នៅពេលផ្តាច់ដោះ ( អាចការពារបានមួយឆ្នាំ ) ។

## ២. ជំងឺសារទឹកជ្រូក ( Pasteurellose Porcine )

ជំងឺនេះបង្កឡើងដោយមេរោគឈ្មោះ Pasteurella Mutocida ជាជំងឺឆ្លងមួយ ហើយច្រើនកើតរាត់រាយ ។ ជ្រូកដែលកើតជំងឺនេះ មានរោគសញ្ញារលាកស្លួត និង មានចំណុចក្រហមនៅលើស្បែក ។

### ក. រោគសញ្ញា :

ជំងឺនេះអាចកើតមាននៅគ្រប់រដូវ ពិសេសនៅតំបន់ទំនាប (ដែលសើមខ្លាំង ) ។ គេចែកជំងឺនេះជាបីកំរិត : ធ្ងន់ មធ្យម និង ស្រាល ។ ហើយកើតច្រើនជាងគេ គឺកំរិតមធ្យម ។

**កំរិតធ្ងន់ :**

បណ្តាលឱ្យជ្រូកហេវហត់ ស៊ីតិច ឬក៏មិនស៊ី ចូលចិត្តដេក ក្តៅដល់ ៤១-៤២°C ផឹកទឹកច្រើន ក មុខ និង ច្រមុះហើមលិប ។ ពិបាកដកដង្ហើម ដង្ហើមឮសូរឃ្លូសខស។ ក្បាលសំយ៉ុង ច្រមុះកំរើកចុះឡើងតាមចង្វាក់ដង្ហើម ជំងឺនេះរាតត្បាតរហ័សណាស់ ជ្រូកអាចងាប់ក្នុងកំឡុងពី ១-២ ថ្ងៃ ។

**កំរិតមធ្យម :**

រយៈពេលដែលមេរោគសម្ងំក្នុងខ្លួន អាចមានពី ៣-៤ ថ្ងៃ ឬក៏អាច ៧-១០ ថ្ងៃ ។

ជ្រូកស្រពាប់ស្រពោន ស៊ីតិច ឬក៏មិនស៊ី ក្តៅខ្លាំង ហើយមានរោគសញ្ញាដូចតទៅនេះ :-

**- ផ្លូវដង្ហើម :**

រលាកស្លួត ក្អកស្ងួត ពេលក្អកម្តងៗរួញខ្លួន ហៀរទឹកមាត់ ហើយទឹកសំបោរខាប់ ហើមបំពង់កដែលរឹតតែបណ្តាលឱ្យពិបាកដកដង្ហើម ។

- **ស្បែក** :

មានចំណុចក្រហម ឬ ផ្ទាំងពណ៌ខៀវនៅកន្លែងស្បែកស្តើង ដូចជា ក ទ្រូង ពោះ និង កៀនភ្លៅ ។

- **ក** :

ហើម ជួនកាលរាលជិតដល់ជើងខាងមុខ ។

- **ប្រដាប់រំលាយអាហារ** :

ដំបូងលាមករឹង ក្រោយមករាគ ហើយមានលាយឈាមផង ។

**ករិតស្រាល** :

សួតរលាកក្នុងករិតស្រាល ហើមគន្លាក់ជើង ដើរបាំងខ្ញិច ។ ស្បែកក្រហម ជួនក៏របកទាំងផ្ទាំងៗ ។ជំងឺបន្លាយពេលដល់ ៥-៦ អាទិត្យ ទីបំផុតជ្រូកអស់កំលាំង ហេវហត់ ហើយងាប់ ។

**ខ. ព្យាបាល** :

ព្យាបាលដោយអង់ទីប៊ីយ៉ូទីក ( Antibiotique ) ស៊ុលហ្វាមីដ (Sulfamide ) ឬក៏សេរ៉ូម ( Serum ) សុទ្ធតែបានលទ្ធផលល្អ ។

- Serum Pasteurella ចាក់សើស្បែក ឬ សរសៃ ឬក៏ចាក់សើស្បែកពាក់កណ្តាល ហើយពាក់កណ្តាលទៀតចាក់សរសៃ 0.២៥-0.៥0ml ក្នុងទំងន់ជ្រូក ១ គក្រ ។

- អោយផឹកស៊ុលហ្វាមីដ ( Sulfamerazine. Sulfametazine. Sulfathiazol ) 0.១៥ ក្រ ក្នុងទំងន់ជ្រូក ១ គក្រ ចែកជាពីរ មួយថ្ងៃឱ្យផឹកពីរដង ប្រើក្នុងរយៈពេល ៣-៤ ថ្ងៃ ។ ប្រើថ្នាំនេះត្រូវឱ្យជ្រូកផឹកទឹកឱ្យបានគ្រប់គ្រាន់ ។ អាចឱ្យផឹកទឹកអំបិលលាយម្រេច ។

- ចាក់ Streptomycine ចាក់សាច់ ២០-៤០ មក្រ ក្នុងទំងន់ជ្រូក ១ គក្រ ។

គ. ការពារ :

ត្រូវប្រតិបត្តិកិច្ចការអនាម័យខាងថែទាំ ស៊ីចុក ផឹកជញ្ជូន និងសំអាតទ្រុងឱ្យបានស្អាត ។

- ត្រូវចាក់ថ្នាំការពារឱ្យជ្រូកដែលទើបនឹងទិញមកចិញ្ចឹម ។

- មួយឆ្នាំត្រូវចាក់ថ្នាំការពារពីរដង នៅដើមរដូវភ្លៀងម្តង និងនៅចុងរដូវភ្លៀងម្តង ។

## ៣. ជំងឺរាគកូនជ្រូក ( Salmonellose Porcine ) :

ជំងឺនេះជាជំងឺឆ្លង ហើយច្រើនកើតមាននៅលើកូនជ្រូក ។ លក្ខណៈពិសេសនៃជំងឺនេះ គឺបណ្ដាលឱ្យជ្រូករាគ ហើយលាមកស្អុយខ្លាំង ( ងាយឱ្យយើងច្រឡំនឹងជំងឺប៉េស្ដ ) ។

### ក. រោគសញ្ញា :

ជំងឺច្រើនកើតក្នុងករិតមធ្យម ។ រយៈពេលដែលមេរោគសម្ងំក្នុងខ្លួន គឺ ៣-៥ ថ្ងៃ ។

- ចាប់ផ្ដើមដំបូងកូនជ្រូកលែងលៅ លែងស៊ីចំណី ក្ដៅខ្លាំង ពីដំបូងទល់លាមក ហើយក្អួត ( រយៈពេលខ្លី បើមិនយកចិត្តទុកដាក់មិនដឹងទេ ) បន្ទាប់មករាគ លាមកពណ៌លឿង ផ្ទុនមានឈាម ហើយស្អុយណាស់ ពេលជុះម្ដងៗច្រើនស្រែក ព្រោះឈឺពោះខ្លាំង ។

- ពិបាកដកដង្ហើម

- នៅត្រចៀក ពោះ ចន្លោះភ្លៅ និង ទ្រូង មានចំណុចក្រហម ហើយប្រែជាខៀវបន្តិចម្ដងៗ ។

- ជ្រូករាគរហូតដល់អស់កំលាំង ហើយអាចងាប់ក្នុងរង្វង់ពី ២ ទៅ ៤ ថ្ងៃ អត្រាងាប់ ៩៥ % ។

- សាកសពជ្រូកងាប់នៅជាមដោយស្នាមក្រហម ត្រួច និង ចំណែកខ្លួនខាងក្រោយ ប្រឡាក់លាមកពាសពេញ ។ ពោះវៀនធំរលាកដំលៅក្រហម ហើយគ្រឿងក្នុងទាំងអស់សុទ្ធតែកកឈាម ។

**ប្រយ័ត្ន :**

ជំងឺនេះងាយច្រឡំនឹងជំងឺប៉េស្តណាស់ បើយើងមិនទាន់កំណត់បាន ថាជាជំងឺរាគកូនជ្រូកទេ ត្រូវព្យាបាលដូចជំងឺប៉េស្ត ។

**ខ. មូលហេតុ :**

ជំងឺនេះបណ្តាលមកពីមេរោគពីរយ៉ាងគឺ :

១- Salmonella Choleraesuis

២- Salmonella Typhisuis

នៅប្រទេសយើង ជំងឺនេះកើតមាននៅសព្វទីសទី មានឥទ្ធិពលខ្លាំងបំផុតទៅលើកូនជ្រូក នៅដើមរដូវភ្លៀងធ្លាក់ ។ មនុស្សយើងក៏អាចនឹងកើតជំងឺនេះ ដោយសារហូបសាច់ជ្រូកឈឺ ។

**គ. ព្យាបាល :**

បើព្យាបាលបានទាន់ពេលវេលាអាចមានប្រសិទ្ធិភាព ។ ទុកជំងឺឱ្យធ្ងន់ពិបាកព្យាបាលណាស់ ។ បច្ចុប្បន្ននេះក្រៅពីសេរ៉ូម មិនទាន់មានថ្នាំណាមានប្រសិទ្ធិភាពចំពោះជំងឺនេះទេ ។

- Serum Salmonellose ចាក់សើស្បែក ( S/C) ចំពោះជ្រូកអាយុ ១៥-៣០ ថ្ងៃ : ៣០-៦០ មល ។ ជ្រូកអាយុច្រើនជាង ៣០ថ្ងៃ ៥០-៨០ មល ។
- អាចប្រើថ្នាំអង់ទីប៊ីយ៉ូទីក ដូចជា Terramycine, Auréomycine 40 mg ក្នុងទំងន់ជ្រូក ១ គក្រ ។

- អាចប្រើប្រភេទថ្នាំស៊ុលហ្វាមីដ ដូចតទៅនេះ : Guanidan, Sulfathiazol, Sulfamérazine 0,2 g ក្នុងទំងន់ជ្រូក ១ គក្រ ប្រើក្នុង រយៈពេល ៣-៤ ថ្ងៃ ។

បើជ្រូករាគខ្លាំងត្រូវចាក់សេរ៉ូមផ្អែម ឬ សេរ៉ូមប្រៃ ហើយឱ្យស៊ីចំណីដែលសំបូរជីវជាតិ ឬ ក៏ឱ្យផឹក Polyvitamin ។

**ឃ. ការពារ :**

ត្រូវអញ្ជើញភ្នាក់ងារបសុពេទ្យនៅតាមជនបទ ចាក់ថ្នាំការពារឱ្យកូនជ្រូក ។

## ៤. ជំងឺកញ្ជ្រិល ( Rouget du porc )

ជំងឺកញ្ជ្រិលជាជំងឺឆ្លងមួយដែលបណ្ដាលមកពីមេរោគ Erysipelothrix Rhusiopathiae ។ ចំណុចសំខាន់នៃជំងឺនេះ គឺមានស្នាមក្រហមនៅលើស្បែក ជំងឺនេះអាចឆ្លងដល់មនុស្ស ។

### ក. រោគសញ្ញា :

គេចែកជំងឺនេះជាបីកំរិត : ធ្ងន់ មធ្យម និង ស្រាល ។

**កំរិតធ្ងន់ :**

រាតត្បាតរហ័សអាចសម្លាប់ជ្រូកក្នុងរយៈពេល ២៤ ម៉ោង ។ ជ្រូកក្ដៅខ្លាំង មិនស៊ីចំណី ភ្នែកឡើងក្រហម ឆ្កួតវក់វី ងោកក្បាលនឹងជញ្ជាំងទ្រុង ក្អួតឈាមងាប់ ។ ក្នុងកំរិតនេះរោគសញ្ញានៅលើស្បែកចេញមិនទាន់ទេ ។

**កំរិតមធ្យម :**

បណ្ដាលឱ្យជ្រូកងាប់ច្រើនណាស់ក្នុងកំរិតនេះ ។

- ដំបូងជ្រូកស្រពាប់ស្រពោន ស៊ីតិច ឬក៏មិនស៊ី ច្រើនដេកថ្ងូរ។ ក្ដៅខ្លាំងក្នុងរយៈពេល ២-៣ ថ្ងៃ ស្បែកស្ងួត លាមកខ្មៅដុំ មានសំបោរពទ្ធ័ជុំវិញ ។

- ភ្នែកក្រហម ឬ ខៀវជាំ ហៀរទឹកភ្នែក

- ពិបាកដកដង្ហើម ហៀរសំបោរ

២-៣ ថ្ងៃក្រោយមកនៅខ្នង ទ្រូង ពោះ ភ្លៅ មានស្នាមក្រហមរាងមូល រាងពងក្រពើ ឬ រាងបួនជ្រុង ។ ស្នាមក្រហមនេះលេចចេញច្បាស់ណាស់ ដំបូងស្នាមពណ៌ផ្កាឈូក បន្ទាប់មកក្រម៉ៅបន្តិចម្ដងៗ ហើយពេលជ្រូកងាប់ស្នាមនេះក៏ក្លាយជាខៀវជាំ ។

៣-៤ ថ្ងៃក្រោយមកទៀត ស្នាមក្រហមនេះស្ងួតទៅវិញ ក្លាយជាក្រមររបកចុះ ។ ៥-១០ ថ្ងៃ ទើបក្រមររបកអស់ ប៉ុន្តែនៅស្នាម ។ ២-៣ ខែក្រោយមក ទើបកន្លែងនោះដុះរោមវិញ ។

ក៏មានករណីខ្លះ កន្លែងដែលមានស្នាម ក្លាយទៅជាដំបៅ ហៀរទឹកពណ៌លឿង ។

ជំងឺបន្ទាយពេល ៣-៥ ថ្ងៃ ជ្រូកខ្សោយទៅៗ ហើយកំដៅខ្លួនចុះខ្លាំង ក្នុងកំរិតនេះជ្រូកអាចងាប់ពី ៥០-៦០% ។

**កំរិតស្រាល :**

ក្នុងកំរិតនេះរោគសញ្ញាមិនច្បាស់ដូចកំរិតទី ២ ទេ ។ ជ្រូកឈឺស្រពាប់ស្រពោន ស៊ីតិច ខ្វះឈាម ចុះស្គម ។ ហើមគ្រប់សន្លាក់ឆ្អឹង ជ្រូកដើរបាំងខ្ញើចៗ ។ ស្បែកខ្នង ពោះ ស្មា ក្បាល ច្រមុះ ត្រចៀក ហើមក្រហម ទាំងផ្ទាំងៗ រលាកចេញទឹកស្អុយរលួយ ងាយបណ្តាលឱ្យមេរោគនានារាតត្បាត មានករណីខ្លះស្បែកស្ងួត របកជាក្រមរទាំងផ្ទាំង ។

**ខ- ព្យាបាល :**

មានថ្នាំពីរប្រភេទដែលមានប្រសិទ្ធិភាព គឺសេរ៉ូមកញ្ជ្រិល និង Pénicilline ។

- Serum antirouget : ចាក់សើស្បែក ១-២មល ក្នុងទំងន់ជ្រូកមួយគីឡូក្រាម ។ អាចចាក់ពាក់កណ្តាលសើស្បែក ពាក់កណ្តាលចាក់សរសៃ ។

- Penicilline : ចាក់សាច់ ២០០០០-៤០០០០UI ក្នុងទំងន់ជ្រូកមួយគីឡូក្រាម មួយថ្ងៃចាក់៣ ដង រហូតដល់កំដៅចុះ និង ស៊ីចុកធម្មតា

- មុជទឹកសាប៊ូឱ្យជ្រូកក៏មានលទ្ធផលដែរ ។ ពេលជំងឺទើបកើតដំ

បួង លាយសាប៊ូក្នុងទឹកក្តៅឧណ្ហៗ ( លាយឱ្យខាប់ ) យកក្រណាត់ជ្រលក់ទឹកសាប៊ូនេះជូតសព្វខ្លួនប្រាណជ្រូក មួយម៉ោងក្រោយជូតម្តងទៀត ធ្វើរបៀបនេះ ២-៣សារ ។

**ប្រយ័ត្ន :**

ជំងឺនេះអាចឆ្លងដល់មនុស្ស កាលណាយើងប៉ះពាល់ជ្រូកឈឺ ។ មនុស្សដែលឆ្លងជំងឺនេះ ក្តៅខ្លួន ហូបមិនឆ្ងាញ់ ចុកចាប់ពេញខ្លួន ពិសេសសន្លាក់ដៃជើង ។ ស្បែកកន្លែងឆងមេរោគហើម ឈឺ រមាស់ឡើងក្រហម។ កាលណាយើងអេះ វានឹងងាយឆ្លងទៅកន្លែងដទៃទៀត ។ ជួបលក្ខណៈបែបនេះត្រូវប្រើ Pénicilline ដើម្បីព្យាបាល ។

**គ. ការពារ :**

- រាល់ឆ្នាំត្រូវចាក់វ៉ាក់សាំងការពារ ពីរដង ។
- ទ្រុងត្រូវស្អាតបាត បានខ្យល់អាកាសចេញចូល ។

# II - ជំងឺរបស់មេជ្រូកពេលមានកូន

ការពារ និង ព្យាបាលជំងឺឱ្យមេជ្រូក មុន និង ក្រោយពេលកើត ជាការសំខាន់ ។ បើធ្វើកិច្ចការនេះមិនបានល្អទេ នឹងមានឥទ្ធិពលអាក្រក់ដល់កូន ហើយអាចបណ្តាលឱ្យមេជ្រូកងាប់ ឬ ក៏មិនអាចបង្កើតកូនបានទៀតផង ។

បើការចិញ្ចឹមមិនបានល្អ ចំណីខ្វះជីវជាតិ នោះក្នុងរយៈពេលពរពោះ មេជ្រូកមានជំងឺកាន់តែច្រើន ។

## ១. ជំងឺរលូតកូន :

ជំងឺរលូតកូនអាចកើតមានឡើងនៅគ្រប់ខែ គ្រប់រដូវ បណ្តាលឱ្យកូនជ្រូកងាប់ ឬ ក៏រស់ទាំងល្ងាក់ល្ងើ ។

មូលហេតុដែលបណ្តាលឱ្យមានជំងឺនេះ គឺស្មុគស្មាញណាស់ ផ្នែកបសុព្យាបាល បែងចែកការរលូតកូនជាច្រើនប្រភេទ ដែលតម្រូវឱ្យមានវិធានការការពារ និង ព្យាបាលឱ្យបានសមស្រប ។

**ក.** រលូតដោយការប៉ះទង្គិច ជួល ឬដោយការហេវហត់ខ្លាំង ។

ជួលក្នុងពេលដែលកូនក្នុងពោះធំហើយ ឧទាហរណ៍ : ការដឹកជ្រូកធើមដោយរថយន្ត មិនត្រឹមត្រូវតាមក្បួនបច្ចេកទេស ពេលឡានរលាក់ ឬ ចាប់ហ្វ្រាំង អាចទ្រោលកិនគ្នា ខាំគ្នា ។

ខ. វលូតដោយចំណីខ្វះជីវជាតិ និង ស៊ីមិនគ្រប់គ្រាន់ ។ ដូចជាកង្វះវីតាមីន A, E និង កង្វះជាតិសាច់ ជាតិរ៉ែក្នុងចំណី ។ ល ។ នៅបណ្តាប្រទេសជឿនលឿនមួយចំនួន មានកន្លែងខ្លះមានជំងឺរលូតកូនដោយខ្វះវីតាមីន របៀតដល់ ១៥ % នៃចំនួនមេជ្រូកកើតកូន ។ ជំងឺនេះច្រើនកើតនៅលើមេក្មេង កូនដំបូង ចំណែកមេជ្រូកចាស់មិនសូវមានជំងឺនេះទេ ។ កូនដែលរលូតច្រើនមានអាយុពី ពីរខែឡើងទៅ ជួនក៏ជិតដល់ពេលកើត កូនដែលរលូតច្រើនងាប់ ។

គ. មេជ្រូកស៊ីចំណីមានជាតិពុល ដូចជាថ្នាំដែលគេបាញ់សំលាប់ស្មៅ សំលាប់ដង្កូវ និង ថ្នាំសំលាប់ព្រូនគ្រប់បែបយ៉ាង ។ ល ។ សុទ្ធតែអាចបណ្តាលឱ្យរលូតកូន ។

ការពារការរលូតកូន ដោយមូលហេតុមិនមែនមកពីជំងឺឆ្លង ពុំមែនមិនអាចធ្វើបាននោះទេ ។

- ទ្រុងសំរាប់មេជ្រូកធើមត្រូវឱ្យទូលាយ មានខ្យល់អាកាសចេញចូល ចំណីត្រូវមានបន្លែត្រកួន ឬក៏ជំពូកស្មៅខ្ចី ត្រូវធានាជាតិសាច់ជាតិរ៉ែ ដោយការបន្ថែមម្សៅត្រីក្នុងចំណី ។ បើបន្លែបាញ់ថ្នាំសំលាប់សត្វល្អិត ត្រូវរង់ចាំឱ្យផុតកំណាត់ពុល សឹមឱ្យវាស៊ី ។

**រលូតកូនដោយសារជំងឺ :**

- រលូតដោយសារមេជ្រូកមានជំងឺ Brucellosis
- រលូតដោយសារមេរោគ Leptospirosis

រលូតកូនដោយសារជំងឺមានការស្មុគ្រស្មាញច្រើន ព្រោះថាការរលូតកូននេះ គ្រាន់តែជារោគសញ្ញាមួយនៃជំងឺតែប៉ុណ្ណោះ ។ ដូចនេះកាលណាយើងឃើញជ្រូករលូតកូន ហើយមេជ្រូកមានបាតុភូតដូចជា ក្តៅខ្លាំង

ទ្វារខាងក្រៅហើម ចេញទឹករំអិលពណ៌ល្អក់ ឬ ក៏ស្បែកភ្នែកឡើងលឿង ត្រូវតែអញ្ជើញភ្នាក់ងារបសុពេទ្យ ដើម្បីជួយធ្វើអន្តរាគមន៍ ។

## ២. ជំងឺពិបាកកើតកូន :

### ក. រោគសញ្ញា :

ក្រោយពេលដែលទឹករំអិលហូរអស់ប្រហែលជា ៥-៦ ម៉ោង គឺជាពេលវេលាដែលកូនកើត ។ ប្រសិនបើដល់ពេលនោះហើយកូនមិនកើតទោះបីមេខំប្រឹងយ៉ាងណាក៏ដោយនោះ គឺមកពីមេជ្រូកមានជំងឺពិបាកកើតកូន ។ យើងត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់ ព្រោះបើទុកយូរនឹងបណ្ដាលឱ្យមេជ្រូកហេវហត់ បាក់កំលាំង បើងលែងកើត កូនក្នុងស្បូននឹងងាប់ដោយថប់ដង្ហើម ។ ហើយបើទុកយូរទៅទៀត កូនក្នុងពោះនឹងស្អុយរលួយ ឆ្លងមេរោគមានជាតិពុល បណ្ដាលឱ្យងាប់ទាំងមេជ្រូកនោះទៀតផង ។

### ខ. ព្យាបាល

ប្រសិនបើពិបាកកើត បណ្ដាលមកពីកូននៅមិនចំកន្លែង ( ដេកទទឹង ឬ បញ្ច្រាស ) នោះត្រូវតំរែតំរង់កូននោះឱ្យត្រូវចំកន្លែងធម្មតាវិញ ។ មុនពេលសង្គ្រោះអ្នកព្យាបាលត្រូវកាត់ក្រចកដៃឱ្យខ្លី . លាងដៃនឹងសាប៊ូ រួចលាងអាល់កុល ហើយបន្ទាប់មកយកប្រេងប៉ារ៉ាហ្វីន ( Paraffine ) លាបដៃឱ្យរអិល ។ ក្ដោបម្រាមទាំងប្រាំ រួចដាក់បញ្ចូលតាមទ្វារសន្សឹមៗបន្តិចម្ដងៗ រង់ចាំដល់ពេលណាមេជ្រូកឈប់ប្រឹងទើបជំរុលដៃឆ្លងមាត់ស្បូនដោយមធ្យ័ត ពេលដែលប៉ះកូន ត្រូវពិនិត្យមើល តើកូននៅចំកន្លែងរបស់វាឬទេ ? បើវានៅមិនចំកន្លែង ត្រូវរាវរក ហើយទាញជើងមុខទាំងពីរចេញមុនទាញបន្តិចម្ដងៗតាមចង្វាក់ប្រឹងរបស់មេជ្រូក មិនត្រូវទាញក្បាលចេញក្រៅមុនទេ ។

បើពិបាកកើតដោយមេជ្រូកគ្មានកំលាំងប្រឹង ត្រូវចាក់ថ្នាំជំនួយបេះ

ដូង ជំនួយកំលាំង ។ ចាក់សរសៃ Solution Glucosée 20% ពី ២០០ ទៅ ៣០០ មល លាយថែម Cafeine 1 gramme ។

ក្នុងលក្ខណៈមេជ្រូកកើតកូនមិនរួច ដោយសារកូនធំពេក ឬ ដោយសារឆ្អឹងត្រគៀកចង្អៀតពេក ឬក៏ដោយសារកូនងាប់ក្នុងស្បូន ត្រូវអញ្ជើញភ្នាក់ងារបសុពេទ្យធ្វើអន្តរាគមន៍ ។

**គ. ការពារ :**

- ត្រូវឱ្យមេជ្រូកធើមធ្វើចលនាដើរចុះឡើង ( ត្រូវមានធ្លាស្មៅ សំរាប់ឱ្យមេជ្រូកធ្វើចលនា ដើរចុះឡើងដោយសេរី ) ។
- ត្រូវឱ្យមេជ្រូកស៊ីចំណី មានជីវជាតិគ្រប់គ្រាន់ យកចិត្តទុកដាក់ជាពិសេសចំពោះជាតិ កាល់ស្យូម និង ផូស្វ័រ ( ដែលមានច្រើននៅឆ្អឹង សំបកខ្យង ខ្ចៅ លៀស គ្រំ សំបកក្តាម សំបកពងមាន់ ពងទា ។ ល ។ ) ។
- ត្រូវឱ្យមេជ្រូកស៊ីបន្លែស្រស់ឱ្យបានគ្រប់គ្រាន់ ។
- មិនត្រូវដាក់ឈ្មោលពេលដែលខ្លួនវានៅតូច មិនទាន់ធំល្មមនោះទេ ( ត្រូវចេះជ្រើសរើសពេលវេលាសមស្រប ) ។

## ៣- ជំងឺធ្លាក់សុកមិនអស់ :

តាមធម្មតាក្រោយពេលកើតកូនពី ១ម៉ោង ដល់ ៦ ម៉ោង សុកនឹងធ្លាក់ចេញអស់ ។ បើសុកធ្លាក់មិនអស់ នោះយើងឱ្យឈ្មោះថា មេជ្រូកមានជំងឺធ្លាក់សុកមិនអស់ ។ សុកដែលមិនធ្លាក់ចុះ បង្កលក្ខណៈងាយស្រួលឱ្យមេរោគរីកដុះដាល ហើយជាតិស្អុយរលួយនៃសុកជ្រាបចូលក្នុងឈាម ធ្វើឱ្យមេជ្រូកពុលងាប់ ឬក៏បណ្តាលឱ្យគ្មានទឹកដោះ ដែលជះឥទ្ធិពលអាក្រក់ដល់កូន ។

### ក- រោគសញ្ញា :

- ជាដំបូងយើងត្រូវរាប់ចំនួនសុកធ្លាក់ចុះ តើគ្រប់នឹងចំនួនកូនកើតឬទេ ? បើចំនួនសុកតិចជាងចំនួនកូន មានន័យថាសុកធ្លាក់មិនអស់ពីស្បូន ។

- ប្រសិនបើយើងគ្មានបេក្ខភាពអាចតាមដានចំនួនសុកដែលធ្លាក់ត្រូវពិនិត្យមើលមេជ្រូក ព្រោះថាមេជ្រូកដែលធ្លាក់សុកមិនអស់ នៅមិនស្ងៀម ហើយចូលចិត្តផឹកទឹកច្រើន ។

តាមធម្មតា ក្រោយពេលកើតកូនហើយ ៦ ម៉ោង កស្បូនចាប់ផ្តើមរួមឡើងវិញដូចសភាពដើម ប្រសិនបើក្រោយ ៦ ម៉ោង កស្បូននៅតែបើក ( ប្រើចំពុះទាពិនិត្យមើល ) មានន័យថាមានសុកនៅក្នុងស្បូននៅឡើយ ។

ប្រសិនបើសង្គ្រោះមិនទាន់ពេលវេលានោះ មួយ ឬ ពីរថ្ងៃក្រោយមកមេជ្រូកចាប់ផ្តើមក្តៅខ្លួន នៅទ្វារមានចេញទឹកពណ៌ក្រមៅ ទុកកាន់តែយូរទឹកដែលហូរចេញកាន់តែស្អុយខ្លាំង ហើយសុខភាពរបស់មេជ្រូកកាន់តែទ្រុឌទ្រោម ។

### ខ. មូលហេតុ :

អាចបណ្តាលមកពីមេជ្រូកមានជំងឺពិបាកកើតកូន ត្រូវប្រើកំលាំងប្រឹងយ៉ាងខ្លាំង ដល់ពេលកើតកូនរួចស្បូនគ្មានលទ្ធភាពរួមមកវិញ ឬ ក៏រួមមកវិញ តែតិចពេក មិនអាចរុញសុកឱ្យចេញក្រៅអស់ ។

ឬក៏មកពីក្នុងរយៈពេលពរពោះ ពិសេសពេលជិតកើត មេជ្រូកស៊ីចំណីខ្វះជាតិរ៉ែ ពិសេសគឺខ្វះជាតិកាល់ស្យូម និង ផូស្វ័រ ហើយមិនបានធ្វើចលនាដើរចុះឡើងឱ្យបានសមស្រប ។

- ដោយសារមេជ្រូកមានជំងឺរលាកស្បូន បណ្តាលឱ្យសុកនៅស្អិតជាប់នឹងស្បូន ។
- ដោយសារស្បូនស្ពឹក ឬ ស្រុត
- ដោយសារមេជ្រូកមានជំងឺរលូតកូន បណ្តាលមកពីជំងឺឆ្លង ។

### គ. ព្យាបាល :

បើយើងដឹងបានទាន់ពេលវេលា ពេលដែលសុកមិនទាន់រលួយ ស្អុយ យើងអាចប្រើថ្នាំជំរុញសុក Post Hypophyse ១០-៣០ UI ក្នុងមេជ្រូកមួយក្បាល ។

- ចាក់សរសៃ Gluconate de Calcium 10 % ២០-៥០ មល

ប្រសិនបើសុករលួយស្អុយហួសទៅហើយ ( ជ្រូកក្តៅ មានទឹកស្អុយចេញពីទ្វារ ) ត្រូវលាងស្បូន ហើយប្រើថ្នាំប្រឆាំងមេរោគ ដូចព្យាបាលជំងឺរលាកស្បូនដូច្នោះដែរ ។

## ៤_ ជំងឺរលាកស្បូន :

### ក_ រោគសញ្ញា :

ជំងឺនេះបណ្ដាលឱ្យមេជ្រូកស៊ីតិច ឬ ក៏មិនស៊ី ក្ដៅ ទឹកដោះចុះថយ ។ មេជ្រូកប្រឹងបន្ទោរបង់មិនឈប់ឈរ ( ពេលប្រឹងខ្នងកោងកន្ទែកជើងក្រោយទាំងពីរ ) ។

ពីរបីថ្ងៃក្រោយមក មានទឹកពណ៌ល្អក់ក្រម៉ៅ ស្អុយរលួយ ហូរចេញតាមទ្វារ ។ ជួនកាលទឹកនេះខាប់កករ មានខ្ទុះ និង បំណែកសុក ឬក៏បំណែកឆ្អឹងតូចៗរតើម ហើយស្អុយជាខ្លាំង ។

រាល់ពេលជ្រូកប្រឹង ឬ ស្រែក ទឹកស្អុយនេះហូរកាន់តែខ្លាំង ឡើង ។

### ខ_ ព្យាបាល :

បើពិនិត្យឃើញថាមានរោគសញ្ញាដូចបានរៀបរាប់ខាងលើនេះ ត្រូវប្រឹងប្រែងព្យាបាលឱ្យសកម្ម ។

- លាយ Permanganate de Potassium 1 ‰ [1 g Permanganate ក្នុងទឹកមួយលីត្រ ( ប្រើទឹកដាំពុះ តែទុកវាឱ្យនៅក្ដៅឧណ្ហៗ ) ] ប្រើទុយោលាងសំអាតស្បូនឱ្យស្អាត ( លាងរហូតដល់ពេលណាឃើញទឹកហូរចេញមកវិញមានពណ៌ខៀវ ទើបឈប់ ) ។

- អាចប្រើ Rivanol ( 2 g Rivanol លាយទឹកមួយលីត្រ ) ។

របៀបលាងគឺដូចខាងលើ ។

ពេលជំងឺមិនទាន់ជា ត្រូវលាងមួយថ្ងៃមួយដង ។

ពេលជំងឺធូរស្បើយ លាងពីរថ្ងៃម្ដង ។

- ពេលដែលទឹកលាងចេញអស់ ត្រូវទុកទុយោសិន កុំអាលដកចេញ ហើយបញ្ចូល Pénicilline តាមបំពង់នេះ (1.000.000 UI Pénicilline + ប្រេងសណ្ដែកដី ២០ មល ) ។
- ចាក់សាច់ (I.M ) 10 mg Streptomycine + 10.000 UI Pénicilline ក្នុងទំងន់ជ្រូកមួយគក្រ ។
- ដាក់ Chlorazone ក្នុងស្បូន ម្ដងមួយគ្រាប់ មួយថ្ងៃពីរដង ដាក់ក្នុងបីបួនថ្ងៃជាប់គ្នា ។

## ៥. ជំងឺរលាកដោះ :

### ក. រោគសញ្ញា :

ដោះហើមធំ ក្រហម រឹង ក្តៅ ពេលកូនបៅ ឬដើរប៉ះ មេជ្រូកស្រែក ជួនធាក់កូន ។

- ក្តៅ អន់ចំណី ឬក៏មិនស៊ី បើរលាកដោះច្រើន នោះមេជ្រូកលែងស៊ីចំណីតែម្តង ហើយដេកបែរទៅជញ្ជាំង ដើម្បីលាក់ដោះកុំឱ្យកូនបៅ

- ពេលទើបរលាកដំបូង ទឹកដោះនៅចេញ ប៉ុន្តែខះបន្តិចម្តងៗ គុណភាពទឹកដោះក៏ប្រែប្រួល ទឹកដោះមានលាយខ្ទុះ ខាប់ ពណ៌លឿង ឬខៀវ ។

ក្នុងសភាពធ្ងន់ធ្ងរ នៅក្បាលដោះមានហូរចេញទឹកពណ៌លឿងលាយខ្ទុះ និង ឈាម ។

ដោះអាចនឹងជា ហើយអាចបញ្ចេញទឹកដោះដូចធម្មតា កាលណាយើងព្យាបាលបានទាន់ពេលវេលា ។ បើទុកយូរមិនព្យាបាល នោះដោះនឹងឡើងរឹង ហើយគ្មានទឹកដោះតែម្តង ។

### ខ. មូលហេតុ :

មកពី :-

- កូនជ្រូកមានធ្មេញស្រួច ពេលបៅខាំដោះបណ្តាលឱ្យមានរបួស
- មេជ្រូកខ្នងធាក់ពោក ធាត់ពោក ពេលដើរចុះឡើង ដោះទាំងពីរជួរកកិតនឹងដី ។
- ឱ្យមេជ្រូកស៊ីចំណីសំបូរជាតិសាច់ ទឹកដោះចេញច្រើនពេក កូន

បៅមិនអស់ ទឹកដោះដែលនៅសល់ក្នុងដោះបង្កលក្ខណៈងាយស្រួលឱ្យមេរោគរីកដុះដាល ។

- មេជ្រូកកើតកូនតិច បៅមិនអស់ដោះ ដោះដែលកូនមិនសូវបៅសល់ទឹកដោះ ដូចនេះបណ្ដាលឱ្យមានជំងឺរលាកដោះ ។

**គ- ព្យាបាល :**

ពេលទើបរលាកដំបូង យកទឹកកកសង្កត់លុញចុះលុញឡើង លើដោះដែលរលាក ដើម្បីកុំឱ្យហើមធំ បើយើងបានដឹងតាំងពីថ្ងៃរលាកដំបូង ហើយយើងយកទឹកកកលុញសង្កត់លើដោះច្រើនដង នោះដោះនឹងលែងហើម ។ ប៉ុន្តែពេលដែលដោះហើមធំ ក្ដៅ និងឈឺទៅហើយ ត្រូវប្រើទឹកក្ដៅបាញ់ដាក់ដោះ ឬក៏យកកន្សែងជ្រលក់ទឹកក្ដៅស្អំដោះ មួយថ្ងៃពីរ បីដង ក្នុងមួយដង ២០-៣០នាទី ។

- យកប្រេងកូឡាលាបដោះក៏បាន ។

- មិនត្រូវឱ្យកូនជ្រូកបៅដោះរលាកនោះទេ ប៉ុន្តែត្រូវច្របាច់ទឹកដោះពីដោះដែលរលាកនោះដាក់ក្នុងចាន រួចចាក់ចោល ។ មួយថ្ងៃច្របាច់ ៣-៥ ដង ។ ពេលច្របាច់ម្ដងៗត្រូវច្របាច់ឱ្យអស់ ។

កាលណាច្របាច់ហើយ ឃើញដោះឡើងរឹង ត្រូវស្ទាបអង្អែលដោះនោះដោយថ្នមៗ ។

- ចាក់ Pénicilline I.M 20.000 UI/ ទំងន់ជ្រូក ១ គក្រ ឬក៏ចាក់ Pénicilline បាញ់បញ្ចូលក្នុងដោះដែលរលាកនោះ ក្រោយពេលដែលយើងច្របាច់ទឹកដោះអស់ហើយ ( ប្រយ័ត្ន ត្រូវប្រើម្ជុលពិសេសសំរាប់ចាក់លើដោះ បើគ្មានត្រូវសំលៀងម្ជុលឱ្យមុតស្រួច ដើម្បីកុំឱ្យដាច់សាច់ដោះ ) ។

**ឃ. ការពារ**

- មួយអាទិត្យមុនពេលកើត ត្រូវបន្ថយចំណីសំបូរជាតិសាច់
- ក្រោយពេលកើតកូនអស់ ត្រូវលាងដោះទាំងពីរជួរ និង ខ្លួនជ្រូកភាគខាងក្រោយ ជាមួយទឹកក្ដៅឧណ្ហៗ និង សាប៊ូ
- ចំពោះមេជ្រូកដែលកើតកូនតិចជាងចំនួនដោះ ត្រូវឱ្យកូនជ្រូកបៅឱ្យបានគ្រប់ដោះ បើទឹកដោះច្រើនពេកត្រូវច្របាច់ចោល ។
- កូនជ្រូកដែលកើតមក ត្រូវកាត់ធ្មេញភ្លាម
- ត្រូវលាងសំអាតទ្រុងជាប្រចាំ ( ព្រឹក ល្ងាច ) ។



# III - អំពីជំងឺកូនជ្រូក

កាលណាការចិញ្ចឹមរបស់យើងបានត្រឹមត្រូវល្អ កូនជ្រូកមិនសូវមានជំងឺទេ ។ ប៉ុន្តែកូនជ្រូកងាយនឹងទទួលឥទ្ធិពលអាក្រក់ពីកត្តាផ្សេងៗណាស់ ហេតុនេះបានជាងាយនឹងមានជំងឺ ។

## ១. ជំងឺរលាកផ្ចិត :

ជំងឺនេះច្រើនកើតនៅលើកូនជ្រូកដែលទើបនឹងកើត ដោយយើងមិនបានកាត់ទងផ្ចិត និង លាបថ្នាំការពារឱ្យបានត្រឹមត្រូវ ។

### ក. រោគសញ្ញា :

ផ្ចិតហើមធំ ទងផ្ចិតក្រហម ក្តៅ ហើយកាលណាយើងស្ទាបប៉ះទងផ្ចិត វាឈឺចាប់ខ្លាំងណាស់ ( ស្រែកញ័រខ្លួន ប៉ោងសរសៃក្រោមពោះ )

- ក្តៅ ស្រពាប់ស្រពោន មិនបៅ ដង្ហើមញាប់ ភាគអាចម៍កាលណារលាកខ្លាំង ហើយកាលណាភាគយូរបណ្តាលឱ្យស្គម ស្បែកជ្រីវជ្រួញ ស្ងួត រោមបះ បើភាគកាន់តែយូរទៅទៀត អាចបណ្តាលឱ្យហើមសន្លាក់ជើង កូនជ្រូកពិបាកដើរ ។

បើព្យាបាលមិនបានដិតដល់ទេ អាចឱ្យផ្ចិតរលួយស្អុយ មានទឹកពណ៌លឿងក្រមៅហូរចេញពីរន្ធផ្ចិត ( ស្អុយខ្លាំងណាស់ ) ។

### ខ. ព្យាបាល :

ដាំទឹកពុះទុកឱ្យត្រជាក់ លាយ Permanganate de potassium 1‰ ( 1 g permanganate លាយទឹកមួយលីត្រ ) ឬ បើគ្មានថ្នាំនេះទេ អាចលាយជាមួយអំបិល ដើម្បីលាងផ្ចិត លាងរួចទុកឱ្យស្ងួត លាបថ្នាំក្រហម រួចរោយម្សៅស៊ុលហ្វាមីដ ( Sulfamide ) ។

- ចាក់ Pénicilline ជុំវិញផ្ចិត និង ចាក់សាច់ 100.000UI Pénicilline ចាក់បីកន្លែង ជុំវិញផ្ចិត រួចហើយ 100.000UI Pénicilline ទៀត ចាក់សាច់ភ្លៅ ចាក់បីថ្ងៃជាប់គ្នា ។

- បើកូនជ្រូករាគ យើងព្យាបាលវាដូចព្យាបាលជំងឺរាគដូច្នោះដែរ ។

# ២. ជំងឺលាមកស

## ក. រោគសញ្ញា :

កូនជ្រូកចាប់ពីអាយុ ៥-២៥ ថ្ងៃ ច្រើនមានជំងឺលាមកសនេះ ។ ចំពោះកូនជ្រូកស្គម ជួនកាលដល់អាយុ ៣ ខែហើយ ក៏នៅតែកើតមានជំងឺនេះដែរ ។ ជំងឺនេះច្រើនកើតនៅកន្លែងចិញ្ចឹមប្រមូលផ្តុំ ពិសេសនៅកន្លែងចិញ្ចឹមជាឧស្សាហកម្ម ដែលមិនធានាបញ្ហាបច្ចេកទេស ។

ដើម្បីឱ្យដឹងថាកូនជ្រូកមានជំងឺនេះ ឬគ្មាន ត្រូវពិនិត្យទ្រុងនៅពេលព្រឹក ។ បើជ្រូកមានជំងឺនេះ យើងឃើញដុំលាមកតូចៗដូចគ្រាប់សណ្តែកពណ៌សនៅកៀនទ្រុង ។ នេះជាដុំលាមករបស់កូនជ្រូកដែលទើបនឹងមានជំងឺ បន្ទាប់មកលាមក រាវ ក្នុងទ្រុងប្រឡូកប្រឡាក់ដោយលាមកពណ៌ខៀវ ឬក៏លឿងតិចៗ ។ នៅគូថកូនជ្រូកក៏មានលាមកប្រតាក ។

កូនជ្រូកហេវហត់ រោមបះ នៅថ្ងៃទី ២ ឬ ទី ៣ កូនជ្រូកកាន់តែមានសភាពទន់ទៅៗ ច្រើនឈរ ឬ ដេកមួយកន្លែង ពៅតិច ឬក៏មិនពៅ ប្រឹងជុះ ហើយលាមកស្អុយជាខ្លាំង លាមកមានលាយសំបោរ ។ ឡើងកំដៅខ្លួន ឈឺពោះ ហើយជួនកាលប៉ោងពោះផង ។

## ខ. ព្យាបាល :

ត្រូវធ្វើយ៉ាងណាឱ្យកូនជ្រូកបានកក់ក្តៅ ពិសេសកូនជ្រូកទើបនឹងកើត ត្រូវបាំងទ្រុងឱ្យជិតខ្យល់ ពិសេសនៅពេលយប់ ។ ទៅតាមលទ្ធភាពដែលយើងមាន អាចកំដៅដោយអំពូលអគ្គីសនី ដោយអង្គាម ឬ ក៏ដុតអុស ធ្យូង ។ ល ។

- កាលណាកូនជ្រូកកើតជំងឺនេះ ត្រូវបន្ថយកុំឱ្យវាបៅច្រើនពេក ដើម្បីឱ្យវាស្រួលរំលាយអាហារ ។
- ឱ្យផឹកទឹកមានជាតិចត់ ( មើលក្នុងជំងឺរាគអាចម៍ )
- ឱ្យផឹក Guanidan ពីអាយុ ១-១០ ថ្ងៃ ឱ្យផឹកម្តងមួយគ្រាប់ មួយថ្ងៃពីរដង ។ ចាប់ពីអាយុ ១០ថ្ងៃឡើងទៅ ឱ្យផឹកម្តង មួយគ្រាប់កន្លះ រហូតដល់ពីរគ្រាប់ មួយថ្ងៃពីរដង ឱ្យក្នុងរយៈពេលបីថ្ងៃ ( ពេលប្រើថ្នាំនេះត្រូវឱ្យកូនជ្រូកផឹកទឹកឱ្យបានគ្រប់គ្រាន់ ) ។
- ឱ្យផឹក Streptomycine លាយ 0,5g Streptomycine ជាមួយទឹក ឱ្យផឹកគ្រប់កូនក្នុងសំបុក( ៨-១០ កូនជ្រូក ) មួយថ្ងៃឱ្យផឹកពីរដង ( ព្រឹក ល្ងាច ) ផឹកក្នុងរយៈពេលពីរថ្ងៃ ។

**ប្រយ័ត្ន :**

បើព្យាបាលបានទាន់ពេលវេលា កូនជ្រូករហ័សជា ប៉ុន្តែក៏ងាយនឹងកើតមានជំងឺនេះឡើងវិញណាស់ ប្រសិនបើយើងការពារវាមិនបានល្អ ។

**គ. ការពារ :**

ក្រៅពីរបៀបដែលបានរៀបរាប់ខាងលើ ដូចជារក្សាភាពកក់ក្តៅឱ្យកូនជ្រូក សំអាតទ្រុងកុំឱ្យសើម ត្រូវយកចិត្តទុកដាក់ជាពិសេសក្នុងការផ្តល់ជាតិដែកដល់កូនជ្រូក ។

អាចប្រើថ្នាំដូចតទៅនេះ :-

- Ferdextran ឬ Ferrodex : ចាក់កូនជ្រូកអាយុ ៣ថ្ងៃ ចាក់សាច់ភ្លៅ ១មល សំរាប់កូនជ្រូកមួយក្បាល បើមានលទ្ធភាពចាក់នៅថ្ងៃទី ១០ម្តងទៀត ។
- Sirop ferreux : ឱ្យផឹកនៅអាយុ ៣ថ្ងៃម្តង ១០ថ្ងៃ ម្តងឱ្យពី ១-៣ ស្លាបព្រាបាយ ។

បើគ្មានថ្នាំទាំងនេះទេ យកដីឥដ្ឋពណ៌លឿង ក្រហម ( ជីកក្នុងជំរៅមួយម៉ែត្រ ) ហាលឱ្យស្ងួត ដាក់នៅគៀនទ្រុងឱ្យវាលិទ្ធ ។



## ៣. ជំងឺក្រិន :

ជំងឺក្រិន ជាជំងឺរបស់សត្វដែលនៅតូចៗនៅឡើយ ។ ជំងឺនេះច្រើនកើតនៅលើជ្រូកអាយុពី ១-៥ ខែ ដោយសារទ្រុងសើមជាប់ ខ្វះពន្លឺថ្ងៃ ជ្រូកមិនបានធ្វើចលនា ( ដើរចុះឡើង ) ឬក៏មកពីចំណីអាហារមិនត្រឹមត្រូវតាមក្បួនបច្ចេកទេស ។

### ក. រោគសញ្ញា :

ក្រោយពេលជំងឺនេះរាតត្បាតអស់រយៈពេល ១-២ ខែ ទើបមានរោគសញ្ញាលេចចេញច្បាស់ ។

**ដំបូង :**

អន់ចំណី ស៊ីតែផ្តេសតែផ្តាស កកេររោមជ្រូកគ្នាឯង កកេរជញ្ជាំងបង្គោលទ្រុង ផឹកទឹកនោម ទឹកលាមក ។ ធ្វេញក្រដុះ កូនជ្រូកច្រើនកើតជំងឺរាគ ដោយសារស៊ី ផឹក តែផ្តេសតែផ្តាស ហើយជួនកាលកន្ត្រាក់ ខ្លួន ។

**បន្ទាប់មក :**

ឆ្អឹងប្រែប្រួលរាងរៅ ហើមគ្រប់សន្លាក់ឆ្អឹង ឆ្អឹងជើងកោងបណ្តាលឱ្យពិបាកដើរ មានជ្រូកខ្លះដើរលើក្បាលជង្គង់ ព្រោះខ្សោយជើងមុខទាំងពីរ ។ ខ្នងកោង ឆ្អឹងខ្នងក្រវេចក្រវក់ ទ្រូងចង្អៀត ហើមឆ្អឹងថ្គាមពិបាកដកដង្ហើម ។

លទ្ធផលចុងក្រោយគឺចិញ្ចឹមក្រធំ ហើយច្រើនមានជំងឺរាគ និងរលាកសួត ។

**ខ. មូលហេតុ :**

មកពីក្នុងទឹកដោះ និង ក្នុងចំណីអាហារខ្វះជាតិ កាល់ស្យូម ផូស ស្វ័រ វីតាមីនដេ និង ជាតិសាច់ ។ ជួនកាលក្នុងចំណីមិនខ្វះជាតិកាល់ស្យូម និង ផូស្វ័រទេ តែសមាមាត្ររបស់វាមិនសមស្រប ។

- ទ្រុងខ្វះពន្លឺថ្ងៃ ជ្រូកមិនបានធ្វើចលនានៅធ្លាខាងក្រៅ
- ដោយសារមានជំងឺរាគរូសយូរថ្ងៃ បានជាមិនអាចបឺតយកជាតិ កាល់ស្យូម និង ផូស្វ័របាន ។
- ដោយសារ Glande thyroïde មានសកម្មភាពខ្សោយ

**គ. ព្យាបាល :**

- ចំណីត្រូវមាន កាល់ស្យូម និង ផូស្វ័រគ្រប់គ្រាន់
- ទ្រុងត្រូវមានខ្យល់អាកាសចេញចូល មានពន្លឺថ្ងៃគ្រប់គ្រាន់ និង មានធ្លាសំរាប់ជ្រូកដើរ
- ឱ្យផឹកខ្លាញ់ត្រីមួយថ្ងៃ ១០ មល
- វីតាមីនដេចាក់សាច់មួយថ្ងៃម្តង 10.000UI ប្រើក្នុងរយៈពេល ៣-៥ ថ្ងៃ
- ឱ្យស៊ីកាកស្រា ឬ កាក Bière ។

# IV - ជំងឺផ្សេងៗមួយចំនួន

## ១. ជំងឺរាគ

### ក. រោគសញ្ញា :

ក្នុងទ្រុងមានលាមកប្រតេកប្រតាក ខ្លួនជ្រូកប្រឡាក់សុទ្ធតែលាមក ។ ក្នុងលាមកមានចំណីដែលមិនទាន់រលាយ ។

រាគ ១-២ ថ្ងៃ ជ្រូកចុះស្គម ស្បែកស្ងួត រោមបះ ដំណើរល្ហើយ ច្រើនដេក ។

ជួនកាលក្នុងលាមកមានជាតិរំអិល ជួនក៏មានទាំងឈាមផង ។ បើជំងឺនេះបណ្តាលមកពីជំងឺឆ្លងនោះ ខ្លួនជ្រូកឡើងកំដៅ ហើយច្រើនដេកមួយកន្លែង ។

### ខ. មូលហេតុ :

បណ្តាលមកពី :-

- ការផ្លាស់ប្តូរអាកាសធាតុរហ័សពេក
- ស៊ីដោយចំណីផុះផ្សិត ជូរ ផ្អូម
- យកទឹកលាងអង្ករ លាងចាន ទុកយូរឡើងជូរទៅឱ្យជ្រូកស៊ី
- ជ្រូកមានជំងឺប៉េស្ត និង ជំងឺរាគកូនជ្រូក ( Salmonella )
- ជ្រូកមានជំងឺប៉ារ៉ាស៊ីតគ្រប់ប្រភេទ
- ជ្រូករលាកពោះវៀន

**គ. ព្យាបាល :**

បើរាគដោយសារអាកាសធាតុត្រជាក់ នោះលាមករាគ តែមិនស្អុយទេ គ្មានឈាម គ្មានរំអិល អាចព្យាបាលដោយប្រើជាតិចត់ ។

- យកត្រួយត្របែកខ្ចី ឬ ត្រួយបណ្ដូលចេកដាក់ក្នុងទ្រុងឱ្យវាស៊ី
- យកស្លឹកត្របែកខ្ចី ៤-៥សន្លឹក ឬសំបកត្របែកដាំទឹកឱ្យវាផឹក (ត្រូវបង្អត់ទឹកវា ៤-៥ម៉ោង ឱ្យស្រេក ទើបស្រួលបញ្ចុកថ្នាំ)
- យកសំបកផ្លែមង្ឃុត ៤-៥ រំងាស់ទឹកឱ្យផឹក ដូចសំបកត្របែក ឬក៏ប្រើត្រួយពួចក៏បាន ។

ប្រសិនបើរាគដោយសារមានជំងឺរលាកពោះវៀន ( លាមកមានរំអិល និង ឈាម ) ត្រូវឱ្យផឹក Streptomycine ។

- ជ្រូកពី ១៥-៣០គក្រ : ផឹកម្ដង 0,5g Streptomycine មួយថ្ងៃ ២ ដង/ ផឹក ២ ថ្ងៃ ។
- ជ្រូកពី ៣០-១០០គក្រ : ផឹកម្ដងមួយក្រាម មួយថ្ងៃពីរដង ផឹកពីរថ្ងៃ ។
- ជ្រូកទំងន់លើសពី ១០០គក្រ : ផឹកពីរក្រាម មួយថ្ងៃពីរដង ផឹកពីរថ្ងៃ ។

**បើរាគមានរំអិល :**

យកស្លឹក Melon + សស៊ុត ។

ទៅតាមជ្រូកតូច ឬ ធំ ប្រើ ៥០-២០០ក្រ ស្លឹក Melon លាងស្អាត ចិញ្ច្រាំឱ្យល្អិតដូចសរសៃសក់ ។ យកសស៊ុត ២-៤ គ្រាប់លាយបញ្ចូលគ្នា ចៀនធ្វើជានំឱ្យជ្រូកស៊ី មួយថ្ងៃឱ្យស៊ី ពីរដង ក្នុងរយៈពេល ២-៣ ថ្ងៃ ។

- ឱ្យផឹក Guanidan ទៅតាមជ្រូកតូច ឬ ធំ ។

ឱ្យផឹកពី ១-១០ក្រ ក្នុងមួយថ្ងៃ ចែកជាពីរពេល ឱ្យក្នុងរយៈពេលបីថ្ងៃ ប៉ុន្តែត្រូវឱ្យជ្រូកផឹកទឹកឱ្យច្រើន ប្រសិនបើរាគផង ក្តៅផង ត្រូវចាក់ Antibiotique និង អញ្ជើញភ្នាក់ងារបសុពេទ្យឱ្យជួយព្យាបាល ។

## ២. ជំងឺទល់លាមក

### ក. រោគសញ្ញា :

តាមធម្មតាលាមកជ្រូកច្រើនទន់ជ្រាយ ហើយក្នុងមួយថ្ងៃមួយយប់ជ្រូកជុះលាមកពី ១-៣គគ្រ ។ កាលណាទល់លាមក ជ្រូកប្រឹងជុះដោយពិបាក ចំកោងខ្នង កន្ទែកជើងក្រោយទាំងពីរ ជួនបង្ហាញនូវសភាពឈឺចាប់យ៉ាងខ្លាំង ។ ក្នុងសភាពខ្លាំង ពេលប្រឹងជុះ ត្រសាល់គូថលៀនចេញក្រៅ ។ ពេលជុះម្តងៗ លាមកតិច ដុំតូចៗផ្តុំគ្នាដូចលាមកពពែ ហើយជួនកាលមានសំបោរពណ៌សពទ្ធ័ជុំវិញដុំលាមក ។

ជ្រូកនោមតិចជាងធម្មតា ទៅតាមលក្ខណៈធ្ងន់ ឬស្រាល ទឹកនោមមានពណ៌លឿង ឬលឿងទុំ ( កន្លែងដក់ទឹកនោមមានពណ៌ដូចទឹកតែចាស់ ) ។

ក្នុងលក្ខណៈទល់លាមកដោយសារជំងឺឆ្លង ជ្រូកក្តៅខ្លួន ជួនឡើងដល់ **៤០-៤១°C** ( កាលណាគ្រុនក្តៅ ជ្រូកអន់ចំណី ឬក៏មិនស៊ីចំណី ស្បែកក្រហមជាងធម្មតា ភ្នែកក្រហម )

### ខ. ការពារ និង ព្យាបាល :

ត្រូវឱ្យជ្រូកស៊ីចំណីមានជីវជាតិគ្រប់គ្រាន់ ហើយលាយថែមអំបិលបន្តិច ដើម្បីឱ្យជ្រូកស៊ីឆ្ងាញ់ ។ ត្រូវឱ្យស៊ីបន្លែស្រស់ ( ត្រកួន ) ។ ទ្រុងត្រូវមានខ្យល់អាកាសចេញចូល ហើយមានធ្លាសំរាប់ឱ្យជ្រូកធ្វើចលនាដើរចុះឡើង ។

- ក្នុងលក្ខណៈស្រាល អាចព្យាបាលដោយគ្រាន់តែឱ្យស៊ីបន្លែស្រស់ឱ្យច្រើន និង ផ្តល់ទឹកផឹកឱ្យបានគ្រប់គ្រាន់ ក៏អាចជា ។

- បើដុំលាមកស្ងួតខ្លាំង ត្រូវបញ្ចូលទឹកក្តៅឧណ្ហៗទៅក្នុងពោះវៀនឱ្យលាមកចេញក្រៅ ។ ប្រើទឹកពុះ ទុកឱ្យនៅក្តៅឧណ្ហៗ បញ្ចូលតាមបាតរហូតដល់ដុំលាមករឹងចេញអស់ ( ទៅតាមជ្រូកតូច ឬធំ អាចប្រើទឹកបញ្ចូលពី ១-៣លីត្រ ) ។

- ឱ្យផឹកថ្នាំបញ្ចុះ : $Na_2SO_4$ ឬ $MgSO_4$ ពី ៥០-១០០ក្រ ក្នុងមួយថ្ងៃ ។ ថ្នាំទាំងពីរមុខនេះជាថ្នាំម្សៅ ត្រូវដាក់ទឹកបន្តិចឱ្យថ្នាំរលាយសឹមឱ្យជ្រូកផឹក ។

- អាចឱ្យជ្រូកផឹកប្រេងល្ហុងខ្វង ( Oleum ricini ) ពី ៣០-៦០ក្រ បើជ្រូកខ្ជិលស៊ីចំណី យើងយកទឹកខ្មេះ ១-២ ស្លាបព្រាបាយ លាយជាមួយទឹកស្ករបន្តិចឱ្យវាផឹក ។

ក្នុងលក្ខណៈទល់លាមកផង ក្តៅផង ព្រមទាំងមិនស៊ីទៀត ត្រូវអញ្ជើញភ្នាក់ងារបសុពេទ្យ ជួយធ្វើអន្តរាគមន៍ ។

ប្រសិនបើគ្មានភ្នាក់ងារបសុពេទ្យនៅជិតនោះទេ អាច :-

- ចាក់ Streptomycine ឬ Pénicilline ឬ ក៏លាយថ្នាំទាំងពីរមុខនេះចូលគ្នា ចាក់ក្នុងរយៈពេលបីថ្ងៃ ។

**កំរិតប្រើ :**

Pénicilline 20.000UI/ ទំងន់ជ្រូក ១ គក្រ

Streptomycine 20mg/ ទំងន់ជ្រូក ១ គក្រ

មួយថ្ងៃចាក់ពីរដង ព្រឹក ល្ងាច ។

៙ ប្រសិនបើជ្រូកទល់លាមក ហើយក្តៅខ្លាំង ល្ងិតល្ងៃ ភ្នែកក្រហម ហើយមានចេញអាចម៍ភ្នែក នោះត្រូវសង្ស័យថាមានជំងឺប៉េស្តជ្រូក ។

# ៣‑ ជំងឺរលាកសួត

## ក‑ រោគសញ្ញា :

ជំងឺនេះច្រើនកើតនៅលើជ្រូកអាយុ ២-៣ អាទិត្យ និង កូនជ្រូកក្រិនក្រធំធាត់ ។

កាលណាមានជំងឺនេះ ជ្រូកក្តៅ ដំណើរទោរទន់ ចូលចិត្តដេករោមបះ ជួនឈរញាក់មួយកន្លែង មិនស៊ីចំណី ។

ពិបាកដកដង្ហើម ដង្ហើមញាប់ ជួនមានដល់ ១០០ចង្វាក់ក្នុងមួយនាទី ។ នៅច្រមុះមានហៀរទឹកសំបោរ ហើយទឹកសំបោរនេះតិចទៅៗ រួចខះមានពណ៌លឿង ឬ ខៀវ ។ ជួនកាលក៏មានសំបោរស្ងួតកកជាក្រមរនៅរន្ធច្រមុះ ។

ជ្រូកឈឺ ច្រើនក្អកនៅពេលព្រឹកព្រលឹម ឬ ពេលធ្វើលឈ្បូរធរ រត់ជាន់គ្នា ។ បើទុកឱ្យជំងឺនេះបន្ទាយពេលវែង នោះនឹងបណ្តាលឱ្យជ្រូកចុះស្គម ដេលស្តីកមួយកន្លែង ត្របកភ្នែកឡើងខៀវជាំ ញ័រខ្លួនទទ្រើត ជួនកន្ត្រាក់ ។ បេះដូងដើរញាប់ពីដំបូង រួចបន្ទាប់មកយឺតទៅៗ រហូតដល់ផុតដង្ហើម ។

បើជំងឺមានលក្ខណៈធ្ងន់ ហើយព្យាបាលមិនទាន់ពេលវេលានោះ ជ្រូកឈឺអាចងាប់ក្នុងកំឡុងពី ២-៣ ថ្ងៃ ។ ជួនកាលជំងឺស្រាល តែបើព្យាបាលមិនបានត្រឹមត្រូវ នឹងក្លាយជាជំងឺរ៉ាំរ៉ៃ នាំឱ្យរីតតែពិបាកព្យាបាល។ ជួនក៏អាចនាំឱ្យរលាកស្រោមសួត ឬ ក៏រលាកសួតមានខ្ទុះ ងាយនឹងបណ្តាលឱ្យជ្រូកងាប់ ។

**ខ. មូលហេតុ :**

ជំងឺនេះច្រើនកើតនៅលើជ្រូកចិញ្ចឹមខ្វះលក្ខណៈអនាម័យ ។ ទ្រុងមិនស្អាត លាមក និង ទឹកនោមនៅកកកុញក្នុងទ្រុង ជះក្លិនពិបាកដកដង្ហើម ។

- អាកាសធាតុផ្លាស់ពីក្តៅទៅត្រជាក់រហ័សពេក ក៏អាចបណ្តាលឱ្យមានជំងឺរលាកសួត ។

- ក្រៅពីនេះក៏អាចបណ្តាលមកពីជំងឺឆ្លងនានា ដូចជាជំងឺសារទឹកជំងឺរាគកូនជ្រូក ( Salmonella ) ឬ ក៏បណ្តាលមកពីមានជំងឺព្រូនចង្អេះ និង ព្រូននៅសួតជាដើម ។

**គ. ព្យាបាល :**

ដាក់ជ្រូកឈឺឱ្យនៅដោយឡែកពីជ្រូកជា ដើម្បីងាយស្រួលក្នុងការថែទាំ និង ព្យាបាល ។

- ចាក់ Pénicilline 20.000 - 40.000UI/ ទំងន់ជ្រូក ១ គក្រ មួយថ្ងៃចាក់បីដង ព្រឹក ល្ងាច យប់

- ចាក់ Streptomycine 20 - 40 mg / ទំងន់ជ្រូក ១ គក្រ មួយថ្ងៃចាក់ពីរដង ព្រឹក ល្ងាច ។

អាចលាយថ្នាំទាំងពីរមុខនេះ ចាក់បញ្ចូលគ្នាក៏បាន ។

បើជ្រូកក្តៅខ្លាំង ឱ្យផឹក Aspirine ឬ APC ទៅតាមជ្រូកតូច ឬធំ អាចឱ្យពីកន្លះគ្រាប់ដល់ពីរគ្រាប់ ។

បើជ្រូកពិបាកដកដង្ហើម ចាក់ Cafein សើស្បែក ។

## ៤. ជំងឺព្រូនចង្អើះ ( Ascaris Suum )

ព្រូនចង្អើះមានរាងមូលដូចចង្អើះ មានប្រវែងពី ១៥-៣០ សម។

### ក. រោគសញ្ញា :

ជំងឺនេះបណ្ដាលឱ្យជ្រូកក្រធំ ចុះស្គម ខ្សោយ ជួនបណ្ដាលឱ្យក្អក ដោយសាររលាកសួត ។ ជួនកាលក៏បណ្ដាលឱ្យរាគ ដោយសារមានវិបល្លាសក្នុងការរំលាយអាហារ ។ បើព្រូនច្រើនអាចបណ្ដាលឱ្យស្ទះពោះវៀន ចុកពោះ ជួនកាលក្អួតចេញព្រូន ។

### ខ. មូលហេតុ :

បណ្ដាលមកពីយើងឱ្យជ្រូកស៊ីបន្លែមិនស្អាត ។

### គ. ព្យាបាល :

ត្រូវបញ្ចុះព្រូនឱ្យជ្រូក :-

១- Dipterex : 0,15 g / ទំងន់ជ្រូក ១ គក្រ ។

យកថ្នាំនេះទៅលាយជាមួយចំណី ហើយឱ្យវាស៊ីនៅពេលព្រឹក ។ មុនពេលឱ្យជ្រូកស៊ីចំណីលាយថ្នាំ ត្រូវបង្អត់វា ១២ ម៉ោងសិន ។

២- យកស្លាក្រៀម កិនឱ្យហ្មត់ ឱ្យស៊ី ៥-២០ក្រ ទៅតាមមាឌជ្រូកតូច ឬ ធំ ។

### ឃ. ការពារ :

ត្រូវឧស្សាហ៍បញ្ចុះព្រូន ពិសេសចំពោះជ្រូកដែលទើបនឹងទិញយកមកចិញ្ចឹម ហើយនឹងមេជ្រូកមុនពេលដាក់ឈ្មោល ។ ត្រូវលាងបន្លែឱ្យស្អាត មុននឹងយកទៅឱ្យជ្រូកស៊ី ។ ហើយត្រូវបោសសំអាតទ្រុងជាប្រចាំ។

# ៥. ជំងឺរមាស់

## ក. រោគសញ្ញា :

ជ្រូកដែលកើតរមាស់ ត្រដុសមិនឈប់ វាត្រដុសនឹងសរសរទ្រុង នឹងជញ្ជាំង ដែលអាចបណ្ដាលឱ្យរលាត់ស្បែក ។ កន្លែងកើតរមាស់ រង្គោះរោម ស្បែកគគ្រើម ។ ជ្រូកកើតរមាស់ស៊ីតិច ដេកតិច ក្រធំ ។

## ខ. ព្យាបាល :

យកកន្ត្រៃកាត់រោមកន្លែងកើតរមាស់ រួចដុសលាងសាប៊ូ រួសវាឱ្យរបើកក្រមរ ។ ត្រូវដុសលាងកន្លែងមិនកើតរមាស់មុន សឹមលាងកន្លែងកើតរមាស់ជាក្រោយ ។ ដុសលាងស្អាតបាតហើយ សឹមដាក់ថ្នាំរមាស់ ។ បើកន្លែងកើតរមាស់ធំពេក លាបថ្នាំម្ដងមួយផ្នែកបានហើយ កុំលាបទាំងអស់ ព្រោះអាចបណ្ដាលឱ្យជ្រូកពុល ។

**ប្រើប្រេងម៉ាស៊ីន :**

យកក្រណាត់រុំចុងចង្កឹះ ជ្រលក់ប្រេងម៉ាស៊ីន លាបចំកន្លែងកើតរមាស់ដែលយើងបានដុសលាងស្អាតហើយ ។

មួយថ្ងៃលាបម្ដង ។ មិនអាចលាបម្ដង $\frac{1}{3}$ នៃខ្លួនវាទេ ។

**លាយថ្នាំ :**

| | |
|---|---|
| - ស្ពាន់ធ័រ ៥០ក្រ<br>- ម្សៅ DDT ៥ក្រ<br>- ប្រេងម៉ាស៊ីន ១លីត្រ | លាយបញ្ចូលគ្នាឱ្យសព្វ |

មុនពេលប្រើ យកដបថ្នាំនេះជ្រលក់ទឹកក្ដៅសិន ។

បើជំងឺរមាស់ខ្លាំង :

- ស្ពាន់ធ័រ ១០០ ក្រ
- កំបោររស់ ៥០ ក្រ
- ទឹក ៥ លីត្រ

លាយបញ្ចូលគ្នាឱ្យសព្វ មួយអាទិត្យលាបពីរដង ។

# ៦. ជំងឺចុងអង្ករ

ជំងឺចុងអង្ករបណ្ដាលមកពីពងព្រូន Taenia Solium របស់ មនុស្ស ។ គ្រាប់អង្ករដែលយើងឃើញក្នុងសាច់នោះ គឺជាពង Cysticercus Cellulosae នៃព្រូន Taenia Solium ។

## ក. រោគសញ្ញា :

គ្មានរោគសញ្ញាច្បាស់លាស់ទេ វាទៅតាមកន្លែងដែលមានចុងអង្ករ ។ បើមាននៅលើអណ្ដាត វាបណ្ដាលឱ្យអណ្ដាតស្ពឹក បើកើតនៅលើជើង វាបណ្ដាលឱ្យពិបាកដើរ ។ បើកើតមានសព្វទីកន្លែង វាអាចបណ្ដាលឱ្យរលាកពោះវៀន រលាកថ្លើម និង រលាកសាច់ដុំ ពេលនោះរោគសញ្ញារបស់វាគឺមិនស៊ី រាគ ចុះស្គម ស្ពឹកស្រពន់ ហើយអាចងាប់ ។

ជំងឺចុងអង្ករច្រើនកើតនៅលើអណ្ដាត ក ស្មា សាច់ប្រឡោះឆ្អឹងជំនី និង បេះដូង ។

## ខ. ការពារ :

មិនត្រូវឱ្យជ្រូកស៊ីលាមកមនុស្ស ។

## គ. ព្យាបាល :

គ្មានថ្នាំព្យាបាលជ្រូកកើតជំងឺចុងអង្ករទេ ។

# ៧. ជំងឺពុលដំឡូងមី

**ក. រោគសញ្ញា :**

ពុលដោយសារស៊ីដំឡូងមីច្រើន ក៏ដូចជាពុលដោយសារស៊ីចំណីដទៃទៀតដែរ គឺបណ្តាលឱ្យជ្រូកហោវហត់ ក្អួតចង្អោរ ដើរវិលវល់ ដង្ហើមញាប់ ។ បើពុលខ្លាំង ហើយព្យាបាលមិនទាន់ពេលវេលា អាចបណ្តាលឱ្យជ្រូកងាប់ ។

**ខ. ការពារ :**

មិនត្រូវឱ្យស៊ីដំឡូងមីច្រើនពេកទេ ពិសេសដំឡូងមីស្រស់ ។ ត្រូវបង្ហាត់ជ្រូកឱ្យស៊ីបន្តិចម្តងៗ ហើយត្រូវស្ងោរឱ្យឆ្អិន ឬ ក៏ត្រាំទឹក ១២ម៉ោងមុនពេលឱ្យជ្រូកស៊ី ។

**គ. ព្យាបាល :**

យកវាទៅដាក់នៅកន្លែងដែលមានខ្យល់អាកាស រួចលាងក្រពះឱ្យវា គឺធ្វើយ៉ាងណាឱ្យវាក្អួត រួចហើយឱ្យផឹកទឹកក្រូចឆ្មាលាយស្ករ បន្ទាប់មកឱ្យផឹកទឹកសណ្តែកបាយ ។

# ៨. ជំងឺពុលអំបិល

ពុលដោយសារស៊ីអំបិល ( NaCl ) ច្រើនពេក ។ ជំងឺនេះយើងជួបប្រទះច្រើននៅលើជ្រូក ។

## ក. រោគសញ្ញា :

**ពុលខ្លាំង :**

ញ័រខ្លួនទទ្រើក ដើរវិលវល់ កន្ត្រាក់ខ្លួន ។ បើខ្លាំងមែនទែនវាអាចសន្លប់ ហើយពីរ បីថ្ងៃក្រោយមកងាប់ ។

**ពុលតិច :**

ស្រេកទឹក រមាស់ ទល់លាមក ២-៣ ថ្ងៃក្រោយមក ជ្រូកហេវហត់ មានសភាពដូចជាថ្លង់ និង ងងឹតភ្នែក ។ មិនស៊ី ដេកកន្ត្រាក់ជើង រឹងថ្គាម កំដៅខ្លួនឡើង ជួនធម្មតា ។ កន្ត្រាក់ខ្លួនក្នុង ១០ នាទីម្តង ។ ៥-៦ ថ្ងៃក្រោយមកងាប់ ។

- ចំនួនអំបិល អាចឱ្យជ្រូកពុលគឺ ៣,៧ក្រ/ទំងន់ជ្រូក ១គក្រ ។

## ខ. ការពារ :

ប្រយ័ត្នក្នុងចំណីមានអំបិលច្រើន

- ចំពោះជ្រូកធំ មួយថ្ងៃឱ្យ ១៥ក្រ អំបិល
- ចំពោះជ្រូកតូច មួយថ្ងៃឱ្យ ៥ក្រ អំបិល ។

### គ. ព្យាបាល

- ចាក់ Gluconate de Calcium 20 - 40 cc / ចាក់សរសៃ
- ចាក់ សេរ៉ូមផ្អែម 50 - 100 ml / ចាក់សរសៃ
- ចាក់ Sulfate de Magnésium 5 - 10 ml / ចាក់សាច់
- ឱ្យផឹក $CuSO_4$ 0,5 - 1 g
- ចាក់ Cafein 2,5ml / ចាក់សាច់ ។





ចេញផ្សាយហើយ !

រឿង មហារាជនីក្រហម

ជាស្នាដៃប្រែសំរួលដោយ

បណ្ឌិត ជា ណេង

# មាតិការឿង


**ភាគ I ផ្នែកចិញ្ចឹមជ្រូក** ទំព័រ

I សភាពការណ៍ចិញ្ចឹមជ្រូក ១

II ពូជជ្រូក និង របៀបបង្កាត់ពូជ ៤

III ចំណីសំរាប់ជ្រូក ២០

IV របៀបចិញ្ចឹមមេជ្រូក ៤១

A - មេជ្រូកមុនពេលដាក់ឈ្មោល ៤១

B - មេជ្រូកធើម ៤៨

C - មេជ្រូកបំបៅកូន ៥៨

V របៀមចិញ្ចឹមកូនជ្រូកបៅដោះ ៦៤

VI របៀបចិញ្ចឹមជ្រូកសាច់ ៧៦

VII របៀបចិញ្ចឹមជ្រូកបា ៨៣

VIII របៀបជ្រើសរើសជ្រូកទុកធ្វើពូជ ៨៥

IX អំពីទ្រុង និង កិច្ចការមួយចំនួន ផ្នែកចិញ្ចឹមសត្វ និង បសុព្យាបាល ៨៧

**ភាគ II ផ្នែក បសុព្យាបាល**

I **ជំងឺឆ្លង** ៩៣

១ - ជំងឺប៉េស្ត ៩៣

២ - ជំងឺសារទឹក ៩៦

៣ - ជំងឺរាគកូនជ្រូក ៩៩

៤ - ជំងឺកញ្ជ្រិល ១០២

II ជំងឺមេជ្រូក ១០៥
១ - ជំងឺរលូតកូន ១០៥
២ - ជំងឺពិបាកកើតកូន ១០៨
៣ - ជំងឺធ្លាក់សុកមិនអស់ ១១០
៤ - ជំងឺរលាកសួន ១១២
៥ - ជំងឺរលាកដោះ ១១៤
III ជំងឺកូនជ្រូក ១១៧
១ - ជំងឺរលាកថ្វីត ១១៧
២ - ជំងឺលាមកស ១១៩
៣ - ជំងឺក្រិន ១២២
IV ជំងឺផ្សេងៗមួយចំនួន ១២៤
១ - ជំងឺភាគ ១២៤
២ - ជំងឺទល់លាមក ១២៧
៣ - ជំងឺរលាកសួត ១៣០
៤ - ជំងឺព្រូនចង្កើះ ១៣២
៥ - ជំងឺរមាស់ ១៣៣
៦ - ជំងឺចុងអង្ករ ១៣៥
៧ - ជំងឺពុលជំឡូងមី ១៣៦
៨ - ជំងឺពុលអំបិល ១៣៧

ឧបត្ថម្ភការបោះផ្សាយដោយ

ឯកឧត្តម **ឈា សុខ**
រដ្ឋលេខាធិការ ក្រសួង កសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ

ឆ្នាំ ១៩៩៦

3000 ₫